# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រ
# កម្មសិទ្ធិនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ១៣ ខែ សីហា  ឆ្នាំ២០២២


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **អ៊ុង សុខលីន**

**នួន ចាន់កាន្និកា**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ហេង ច័ន្ទបូលីន**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រ
# កម្មសិទ្ធិនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២២


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **អ៊ឹង សុខលីន**
**នួន ចាន់កាន្និកា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ហេង ច័ន្ទមុលីន**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **អ៊ឹង សុខលីន** និង **នួន ចាន់ភានិកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រគណនេយ្យ ឆ្នាំទី៤ ជំនាន់ទី ១៧ ក្រុម A4C2 ឆ្នាំសិក្សា ២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមលំឱនកាយសម្តែងនូវកតញ្ញូតាធំមយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

- **លោកឪពុក** និង **អ្នកម្តាយ** ដែលបានផ្តល់កំណើតដល់កូន និងខិតខំជំនះរាល់ឧបសគ្គទាំងឡាយ ដើម្បីថែរក្សាដល់កូន អប់រំទូន្មាន ឧបត្ថម្ភ ព្រមទាំងផ្តល់នូវកម្លាំងកាយ កម្លាំងចិត្ត ទាំងផ្នែកស្មារតី ថវិកា និងសម្ភារៈ សម្រាប់ទំនុកបម្រុងការសិក្សាតាំងពីកុមារភាព រហូតដល់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។
- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រី ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រី សាស្រ្តាចារ្យ ព្រមទាំងបុគ្គលិកការិយាល័យស្រាវជ្រាវ និងការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែង លះបង់កម្លាំងកាយចិត្ត អប់រំណែនាំដោយព្រហ្មវិហារធម៌ ដឹកនាំ គ្រប់គ្រង បង្ហាត់បង្រៀន ផ្តល់ចំណេះដឹង ចែករំលែកបទពិសោធន៍ ដោយគ្មានចិត្តលំអៀងដល់យើងខ្ញុំរហូតដល់ពេលនេះ។
- លោកស្រីសាស្រ្តាចារ្យ **ហេង ច័ន្ទបូលីន** ដែលជាសាស្រ្តាចារ្យដឹកនាំបានចំណាយពេលដ៏មានតម្លៃក្នុងការណែនាំ បង្ហាត់បង្រៀន កែលំអក្នុងការសរសេរសារណាបញ្ចប់នេះ រហូតទទួលបានលទ្ធផលល្អប្រសើរ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សូមលើកដៃបួងសួង លំឱនកាយវាចាចិត្តថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណដល់លោកអ្នកទាំងអស់ជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពមាំមួន ព្រមទាំងប្រកបការងារគ្រប់បែបយ៉ាងទទួលបានជោគជ័យ ជានិច្ចនិរន្តរ៍។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាអស់រយៈពេលជាងបួនឆ្នាំកន្លងមក នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំពិតជាមានភាពរីករាយជាខ្លាំង ដែលមានកិត្តិយសបានចូលរួមរៀបចំចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង ក្នុងគោលបំណងអភិវឌ្ឍន៍នូវចំណេះដឹងបន្ថែម និងឲ្យកាន់តែស៊ីជម្រៅ។ មូលបត្រកម្មសិទ្ធិគឺវាតំណាងឲ្យភាពជាម្ចាស់ទ្រព្យ។ នៅពេលដែលក្រុមហ៊ុនមួយដល់ដំណាក់កាលត្រូវពង្រីកខ្លួន ឬត្រូវការទុនបន្ថែម ដើម្បីប្រើប្រាស់ក្នុងគម្រោងថ្មី គេនឹងធ្វើការសិក្សាពីលទ្ធភាពក្នុងការបោះផ្សាយមូលបត្រកម្មសិទ្ធិដើម្បីលក់ទៅឲ្យសាធារណៈជន ក្នុងគោលដៅយកប្រាក់ពីសាធារណៈជនមកប្រើប្រាស់។ អ្នកទិញភាគហ៊ុន នឹងទទួលបានភាគលាភមកវិញ អាស្រ័យលើចំនួនហ៊ុនដែលមាន និងប្រាក់ចំណេញមូលធននៅពេលដែលថ្លៃភាគហ៊ុនកើន។

ដោយចាប់អារម្មណ៍លើមូលបត្រកម្មសិទ្ធនៅកម្ពុជា ទើបយើងខ្ញុំមានគោលបំណងក្នុងការស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹងមូលបត្រកម្មសិទ្ធិនៅកម្ពុជា សម្រាប់ធ្វើជារបាយការណ៏ស្រាវជ្រាវបញ្ចប់ការសិក្សា ហើយបានជ្រើសយកប្រធានបទ ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធនៅកម្ពុជា ដើម្បីចងក្រងទុកជាឯកសារសម្រាប់សិស្សប្អូនជំនាន់ក្រោយ។

យើងខ្ញុំជឿជាក់ថា សារណាបញ្ចប់ការសិក្សានេះ នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ តែទោះបីយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាមិត្តអ្នកអានទាំងអស់ ពិតជាមានការអធ្យាស្រ័យរាល់កំហុសខុសឆ្គងដែលកើតមានឡើងដោយអចេតនា។ យើងខ្ញុំសូមទទួលយកមតិរិះគន់ក្នុងន័យស្ថាបនា កែលំអដោយក្តីសោមនស្សរីករាយ ដើម្បីទុកជាបទពិសោធន៏ សម្រាប់ការស្រាវជ្រាវក្រោយៗកាន់តែមានលក្ខណៈប្រសើរឡើងថែមមួយកម្រិតទៀត។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណដល់មិត្តនិស្សិតអ្នកអាន និងសូមឲ្យមិត្តនិស្សិតទទួលជោគជ័យក្នុងការសិក្សា មានសុខភាពល្អ ដើម្បីបន្តជាសសរទ្រូងនៃប្រទេសជាតិយើង និងប្រើប្រាស់សារណាស្រាវជ្រាវនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅប្រទេសកម្ពុជា ។

# មាតិកា

ទំព័រ

បញ្ជីតារាង.....vi

បញ្ជីរូបភាព.....vii

បញ្ជីក្រាហ្វិច.....viii

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ.....១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.....២

៣. កម្មវត្ថុនៃការស្រាវជ្រាវ.....២

៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.....៣

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ.....៣

៦. សារៈសំខាន់ការស្រាវជ្រាវ.....៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៤

## ជំពូកទី១

## រំលឹកទ្រឹស្តី

១.១. មូលបត្រ.....៦

១.១.១. និយមន័យមូលបត្រ.....៦

១.១.២. ប្រភេទនៃមូលបត្រ.....៦

១.១.២.១. មូលបត្រកម្មសិទ្ធិ.....៦

១.១.២.២. មូលបត្របំណុល.....៦

១.១.២.៣. ឧបករណ៍និស្សន្ទ.....៧

១.២. ប្រភេទនៃមូលបត្រកម្មសិទ្ធិ.....៧

១.២.១. ភាគហ៊ុនធម្មតា ..... ៧
១.២.២. ភាគហ៊ុនបុរិមា ..... ៨
១.៣. ទីផ្សារមូលត្រ ..... ៨
១.៣.១. និយមន័យទីផ្សារមូលបត្រ ..... ៨
១.៣.២. ប្រវត្តិទីផ្សារមូលបត្រ ..... ៨
១.៣.៣. ប្រភេទទីផ្សារមូលបត្រ ..... ៩
១.៣.៣.១. ទីផ្សារដំបូង ..... ៩
១.៣.៣.២. ទីផ្សារបន្ទាប់ ..... ៩
១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ ..... ១០
១.៤.១. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន ..... ១០
១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ ..... ១១
១.៤.៣. អត្ថប្រយោជន៍ទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ ..... ១៣
១.៥. គុណវិបត្តិទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច ..... ១៤

## ជំពូកទី២

## ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

២.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ..... ១៥
២.១.១. ប្រវត្តិសង្ខេបរបស់និយ័តករមូលបត្រកម្ពុជា ..... ១៥
២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា ..... ១៥
២.១.៣. ចក្ខុវិស័យ និងបេសកកម្ម ..... ១៦
២.១.៤. គោលដៅ និងគោលបំណងទូទៅនៃនិយ័តកាមូលបត្រកម្ពុជា ..... ១៧
២.១.៥. មុខងាររបស់និយ័តករមូលបត្រកម្ពុជា ..... ១៧
២.១.៦. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា ..... ១៨
២.១.៧. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា ..... ១៨

២.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ១៩
២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ១៩
២.២.២. ចក្ខុវិស័យ ........ ២០
២.២.៣. បេសកកម្ម ........ ២០
២.២.៤. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា ........ ២០
២.២.៥. ព័ត៌មានទូទៅនៃការទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ២១
២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ........ ២១
២.២.៧. ក្រុមប្រឹក្សាភិបាល ........ ២២
២.៣. តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ ........ ២៣
២.៣.១. និយ័តករមូលបត្រកម្ពុជា ........ ២៣
២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ........ ២៣
២.៣.៣. ក្រុមហ៊ុនមូលបត្រ ........ ២៣
២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ ........ ២៥
២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) ........ ២៥
២.៣.៤.២. កំពង់ផែស្វយ័តក្រុងភ្នំពេញ(PPAP)) ........ ២៦
២.៣.៤.៣. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល(GTI) ........ ២៧
២.៣.៤.៤. ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP) ........ ២៨
២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS) ........ ២៩
២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC) ........ ៣០
២.៣.៤.៧. ក្រុមហ៊ុន ផេកចិក (ខេមបូឌា) ម.ក.(PEPC) ........ ៣១
២.៣.៤.៨. ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក.(DBD) ........ ៣២
២.៣.៥. វិនិយោគិន ........ ៣៣
២.៣.៦. តួអង្គចូលរួមដទៃទៀត ........ ៣៣

# ជំពូកទី៣

# ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា

៣.១. ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដំបូង ..............................៣៦

៣.១.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង..........................................៣៦

៣.១.២. លក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ..........................................................................................................៣៦

៣.១.៣. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ......................................................៣៨

៣.១.៤. ការចំណាយក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ............ ៤០

៣.១.៥. យន្តការទីផ្សារដំបូង ...........................................................................................................៤២

៣.២. ដំណើរការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្មសិទ្ធិ ..................................៤២

៣.២.១. ដំណាក់កាលដំបូងមុននឹងការចាប់ផ្តើមជួញដូរមូលបត្រ ...................................................៤៣

៣.២.១.១. ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន .................................................៤៣

៣.២.១.២. ការបើកគណនីជួញដូរមូលបត្រ គណនីសាច់ប្រាក់ និងគណនីមូលបត្រ........ ៤៥

៣.២.២. ប្រតិបត្តិការទីផ្សារ ........................................................................................................... ៤៦

៣.២.២.១. ថ្ងៃ និងម៉ោងជួញដូរ........................................................................... ៤៦

៣.២.២.២. ប្រភេទបញ្ជា..........................................................................................៤៧

៣.២.២.៣. ការដាក់បញ្ជា ....................................................................................... ៤៨

៣.២.២.៤. ព័ត៌មានលម្អិតនៃបញ្ជា ......................................................................... ៤៨

៣.២.២.៥. ឯកតាគម្លាតថ្លៃ....................................................................................... ៤៩

៣.២.២.៦. ថ្លៃមូលដ្ឋាន .......................................................................................... ៤៩

៣.២.២.៧. ថ្លៃពិសេស ............................................................................................ ៤៩

៣.២.២.៨. វិធីសាស្រ្តជួញដូរមូលបត្រកម្មសិទ្ធិ ........................................................ ៥១

៣.២.២.៩. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ .................................................៥២

៣.២.៣. ប្រតិបត្តិការផាត់ទាត់ និងទូទាត់ ....................................................................................................៥៣
៣.២.៣.១. ប្រព័ន្ធផាត់ទាត់ និងទូទាត់ ....................................................................៥៣
៣.២.៣.២. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់ ....................................៥៤
៣.២.៣.៣. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ .....................................៥៥
៣.២.៤. ប្រតិបត្តិការនៃការរក្សាទុកមូលបត្រ ..................................................................................................... ៥៦
៣.៣. ទិដ្ឋភាពទូទៅនៃការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិ .....................................៥៧
៣.៣.១. ចំនួនក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីឆ្នាំ ២០១២ដល់ឆ្នាំ ២០២១ ..៥៧
៣.៣.២. តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈ .................................................................................... ៥៨
៣.៣.៣. ទិន្នន័យសំខាន់ៗទាក់ទងការជួញដូរមូលបត្រកម្មសិទ្ធិ ...................................................................... ៥៩
៣.៣.៣.១. ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ................................ ៥៩
៣.៣.៣.២. ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស) ..........................៦០
៣.៣.៣.៣. ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល)....................៦១
៣.៣.៣.៤. ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ ...........................៦២

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ..................................................................................................៦៤
២. ការផ្តល់អនុសាសន៍..............................................................................................៦៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

ទំព័រ

តារាង២.១៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPWSA ២៧

តារាង២.២៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPAP ២៨

តារាង២.៣៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងGTI ២៩

តារាង២.៤៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPSP ៣០

តារាង២.៥៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPAS ៣១

តារាង២.៦៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងABC ៣២

តារាង២.៧៖ លទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPEPC ៣៣

តារាង៣.១៖ លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ៤២

តារាង៣.២៖ លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ៤៣

តារាង៣.៣៖ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក. ៤៦

តារាង៣.៤៖ ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក. ៤៦

តារាង៣.៥៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ៤៧

តារាង៣.៦៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ៤៧

តារាង៣.៧៖ ពេលវេលានៃការជួញដូរ ៥៣

តារាង៣.៨៖ ថ្លៃពិសេសនៃសំណើលក់ ៥៦

តារាង៣.៩៖ ថ្លៃពិសេសនៃសំណើទិញ ៥៦

តារាង៣.១០៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង ៦៤

# បញ្ជីរូបភាព

ទំព័រ

រូបភាព២.១. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា ១៦
រូបភាព២.២. រចនាសម្ព័ន្ធគ្រប់គ្រងរបស់និយ័តករមូលបត្រកម្ពុជា ១៩
រូបភាព២.៣. ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ២១
រូបភាព២.៤. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ២២
រូបភាព២.៥. ក្រុមប្រឹក្សារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ២៣
រូបភាព២.៦. ស្លាកសញ្ញា PWSA ២៦
រូបភាព២.៧. ស្លាកសញ្ញា PPAP ២៧
រូបភាព២.៨. ស្លាកសញ្ញា GTI ២៨
រូបភាព២.៩.ស្លាកសញ្ញា PPSPC ២៩
រូបភាព២.១០. ស្លាកសញ្ញា PAS ៣០
រូបភាព២.១១. ស្លាកសញ្ញា ABC ៣១
រូបភាព២.១២. ស្លាកសញ្ញា PEPC ៣២
រូបភាព២.១៣. ស្លាកសញ្ញា DBD ៣៣
រូបភាព៣.១. យន្តការទីផ្សារដំបូង ៤៨
រូបភាព៣.២. ការជួញដូរមូលបត្រនៅទីផ្សារបន្ទាប់ ៤៩
រូបភាព៣.៣. ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ ៥៨
រូបភាព៣.៤. ដំណើរការនៃប្រព័ន្ធជាត់ទាត់ និងទូទាត់ ៦០
រូបភាព៣.៥. ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ ៦០
រូបភាព៣.៦. ការទូទាត់សាច់ប្រាក់អន្តរធនាគារ ៦១
រូបភាព៣.៧. ដំណើរការនៃប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ៦១

# បញ្ជីក្រាហ្វិច

ទំព័រ


ក្រាហ្វិចទី១៖ក្រុមហ៊ុនបោះផ្សាយនិងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីឆ្នាំ ២០១២ ដល់២០២១......៦៣

ក្រាហ្វិចទី២៖ តម្លៃបោះផ្សាយលក់ និងចំនួនមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង................៦៤

ក្រាហ្វិចទី៣៖ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ឆ្នាំ២០២១.............................៦៥

ក្រាហ្វិចទី៤៖ ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស) ឆ្នាំ២០២១.........................៦៦

ក្រាហ្វិចទី៥៖ ការជួញដូរតាមប្រភេទវិនិយោគិន(រូបវន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២១................៦៧

ក្រាហ្វិចទី៦៖ ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ ឆ្នាំ២០២១........................៦៨

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលក្នុងនោះរាជរដ្ឋាភិបាលបាននឹងកំពុងតែអនុវត្តន៍នូវគោលនយោបាយ និងយុទ្ធសាស្រ្តជាច្រើន ដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសមានកំណើនទៅមុខជាលំដាប់។ ទន្ទឹមនឹងនេះដែរ ប្រព័ន្ធហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍ និងដើម្បីធានាបាននូវកំណើនសេដ្ឋកិច្ចនៅកម្ពុជា។ ប្រភពហិរញ្ញប្បទាននៅកម្ពុជាមាន២សំខាន់ គឺប្រព័ន្ធធនាគារ និងទីផ្សារមូលបត្រ។ សម្រាប់ប្រព័ន្ធធនាគារ ជាប្រភពហិរញ្ញប្បទានមួយដែលមានភាពចាស់ទុំ និងដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់ជាកម្ចីដល់អ្នកដែលត្រូវការនូវទុនសម្រាប់ធ្វើការវិនិយោគ។ ដោយឡែកសម្រាប់ទីផ្សារមូលបត្រ គឺជាប្រភពហិរញ្ញប្បទានមួយដែលថ្មី និងបំពេញបន្ថែមទៅលើប្រព័ន្ធធនាគារ ឬអាចនិយាយម្យ៉ាងទៀតថា ជាជម្រើសថ្មីនៃហិរញ្ញប្បទានសម្រាប់សហគ្រាសដែលត្រូវការទុន។ ជាក់ស្តែងនៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួនម្ចាស់អាជីវកម្មជាពិសេសសហគ្រាសធុនតូច និងមធ្យម ជានិច្ចកាលអាចប្រឈមបញ្ហាខ្វះខាតទុនសម្រាប់ធ្វើការវិនិយោគបន្ថែម និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ ដើម្បីទទួលបានទុនបន្ថែមនេះ ម្ចាស់អាជីវកម្មមានលទ្ធភាពបង្កើនទុនតាមរយៈការដាក់បញ្ចូលមូលធនបន្ថែមពីសមាជិកភាគហ៊ុន ការខ្ចីពីដៃគូអាជីវកម្ម ឬកម្ចីពីគ្រឹះស្ថានធនាគារជាដើម។ ក្រៅពីជម្រើសដូចបានរៀបរាប់នេះ ម្ចាស់អាជីវកម្មក៏អាចប្រើប្រាស់នូវជម្រើសហិរញ្ញប្បទានផ្សេងទៀត ដូចជាតាមរយៈការលក់ភាគហ៊ុននៅលើទីផ្សារមូលបត្រ។ ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គឺជាហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនធ្វើការប្រកាសលក់ភាគហ៊ុនរបស់ខ្លួនជាសាធារណៈ ដើម្បីកៀរគរមូលធនពីសាធារណៈជន។

ដើម្បីឲ្យដំណើរការទីផ្សារមូលបត្រកម្ពុជា ប្រព្រឹត្តិទៅដោយរលូន រាជរដ្ឋាភិបាលបានបង្កើតឡើងនូវនិយ័តករមូលបត្រកម្ពុជា ដែលមានតួនាទីយ៉ាងសំខាន់ ក្នុងការតាក់តែងច្បាប់ស្តីពីនីតិវិធីក្នុងការបោះផ្សាយលក់មូលបត្រ ក៏ដូចជានីតិវិធីផ្សេងទៀតពាក់ព័ន្ធនឹងវិស័យមូលបត្រ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ( ផ.ម.ក.) ក៏ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។ យើងសង្កេតឃើញថា បច្ចុប្បន្ននេះ វិស័យមូលបត្រនៅក្នុងប្រទេសកម្ពុជា កំពុងក្លាយជាទីចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់សាធារណៈជន ព្រមទាំងវិនិយោគិន និងក្រុមហ៊ុនឯកជននានាជាច្រើនផងដែរ។ ដែលជាហេតុផលធ្វើឲ្យក្រុមហ៊ុនឯកជន វិនិយោគិន ក៏ដូចជាសាធារណៈជន ចង់ដឹង និងស្វែងយល់ពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង និងដំណើរការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ។ ហេតុនេះហើយការរីកលូតលាស់នៃវិស័យមូលបត្រ គឺជាកត្តាចាំបាច់ដែលត្រូវយកចិត្តទុកដាក់។ ដោយឡែកនៅប្រទេសកម្ពុជា ទោះបីជាមានការជ្រោមជ្រែងពីសំណាក់រាជរដ្ឋាភិបាល ក្នុងការជំរុញនូវវិស័យមូលបត្រក៏ពិតមែន ក៏យើងសង្កេតឃើញថា ធនធានមនុស្សក្នុងវិស័យនេះនៅមានកម្រិត ស្ថាប័នពាក់ព័ន្ធនៅខ្វះបច្ចេកវិទ្យាក្នុងការគ្រប់គ្រងឲ្យកាន់តែមានប្រសិទ្ធភាព ពីព្រោះវិស័យមូលបត្រនេះ ទើបតែបង្កើតឲ្យដំណើរការ ដូចនេះហើយវិស័យនេះ មិនទាន់រីកចំរើនខ្លាំងនៅឡើយ។ ជាក់ស្តែង ទីផ្សារមូលបត្រមានវិធានស្មុគស្មាញជាច្រើន ដែលទាមទារឱ្យក្រុមហ៊ុន វិនិយោគិន និងសាធារណៈជនត្រូវមានចំណេះដឹង ជំនាញ និងបទពិសោធន៍ទាក់ទងវិស័យនេះ។ ក្រុមហ៊ុន វិនិយោគិន និងសាធារណៈជន មួយចំនួនពុំទាន់បានយល់ឲ្យស៊ីជម្រៅ អំពីដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ក៏ដូចជាការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជានៅឡើយ។ ដោយមើលឃើញចំណុចខ្វះខាតទាំងនេះ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទ ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា នេះមកធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងយល់ និងបកស្រាយឲ្យកាន់តែច្បាស់បន្ថែមទៀតទៅលើបញ្ហាទាំងនេះ។ ដើម្បីសម្រេចបាននូវគោលបំណងនៃការស្រាវជ្រាវនេះ របាយការណ៍របស់យើងខ្ញុំនឹងឆ្លើយតបនូវសំណួរដូចខាងក្រោម៖

- តើក្រុមហ៊ុនត្រូវបំពេញនូវលក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះ ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង?
- តើលក្ខខណ្ឌតម្រូវអ្វីខ្លះដែលវិនិយោគិនត្រូវបំពេញដើម្បីធ្វើការវិនិយោគនៅផ្សារមូលបត្រកម្ពុជា?
- តើការទិញ លក់មូលបត្រកម្មសិទ្ធនៅលើផ្សារមូលបត្រកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្តេច?
- តើទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ពីឆ្នាំ២០១២ ដល់ ឆ្នាំ ២០២១ និងការជួញដូរមូលបត្រកម្មសិទ្ធិមានស្ថានភាពយ៉ាងដូចម្តេចនៅឆ្នាំ ២០២១?

## ៣. គម្មវត្ថុនៃការស្រាវជ្រាវ

ការស្រាវជ្រាវនៃសារណាបញ្ចប់ការសិក្សានេះ គឺផ្តោតសំខាន់លើប្រធានបទ "ដំណើរការបោះផ្សាយនិងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា" ដោយមានគោលបំណងសំខាន់ៗ ដូចខាងក្រោម៖

- ស្វែងយល់ពីលក្ខខណ្ឌ និងនីតិវិធីដែលក្រុមហ៊ុនត្រូវបំពេញ ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។
- ស្វែងយល់ពីលក្ខខណ្ឌតម្រូវ ដែលវិនិយោគិនត្រូវបំពេញដើម្បីធ្វើការវិនិយោគនៅផ្សារមូលបត្រកម្ពុជា។
- ស្វែងយល់អំពីប្រតិបត្តិការ និងនីតិវិធីក្នុងការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា។

- ស្វែងយល់អំពីទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ពីឆ្នាំ ២០១២ ដល់ ឆ្នាំ ២០២១ និងការជួញដូរមូលបត្រកម្មសិទ្ធ នៅឆ្នាំ ២០២១។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

នៅសព្វថ្ងៃនេះ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលត្រូវបានបោះផ្សាយ និងជួញដូរនៅក្នុងផ្សារមូលបត្រកម្ពុជា ប៉ុន្តែនៅក្នុងសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ គឺផ្តោតសំខាន់តែទៅលើដំណើរការបោះផ្សាយ និងប្រតិបត្តិការជួញដូរ ប្រតិបត្តិការផាត់ទាត់ និងទូទាត់ និងប្រតិបត្តិការរក្សាទុកមូលបត្រកម្មសិទ្ធនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាតែប៉ុណ្ណោះ។ ម្យ៉ាងទៀត ការសិក្សានេះប្រើប្រាស់តែទិន្នន័យនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងទិន្នន័យ ចំនួន៤ត្រីមាសនៃឆ្នាំ២០២១ ទាក់ទងនឹងទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ការជួញដូរតាមប្រភេទវិនិយោគិន និងចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនចុះបញ្ជី។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការសរសេរទៅលើដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា គឺធ្វើតាមវិធីសាស្ត្របែបពណ៌នា ដោយរៀបរាប់ពីយន្តការ និងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងប្រតិបត្តិការជួញដូរ ប្រតិបត្តិការផាត់ទាត់ និងទូទាត់ និងប្រតិបត្តិការរក្សាទុកមូលបត្រកម្មសិទ្ធនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ចំពោះទិន្នន័យដែលយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ គឺទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់ដែលមានប្រភពចេញពី៖

- ច្បាប់ បទប្បញ្ញត្តិ ប្រកាស គោលការណ៍ណែនាំរបស់ និយ័តករមូលបត្រកម្ពុជា និងវិធានរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ឯកសារបោះពុម្ពជាភាសាខ្មែរ ដែលទាក់ទងនឹងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ។
- ទិន្នន័យផ្សេងៗដែលមាននៅក្នុងគេហទំព័រផ្លូវការរបស់និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

## ៦. សារៈសំខាន់ការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអំពី ប្រធានបទដែលទាក់ទងទៅនឹង ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា គឺមានសារៈសំខាន់ និងបានផ្តល់ផលប្រយោជន៍ដូចជា៖

- ➢ ទទួលបានចំណេះដឹងបន្ថែមមួយកម្រិតទៀតទាក់ទងទៅនឹងវិស័យមូលបត្រនៅកម្ពុជា ដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តីដែលបានរៀនកន្លងមក។
- ➢ ជំនួយស្មារតីដល់និស្សិតប្អូនជំនាន់ក្រោយ ដែលមានបំណងស្វែងយល់បន្ថែមអំពីដំណើរការបោះផ្សាយ និងប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រនៅកម្ពុជា។
- ➢ ផ្តល់ជាឯកសារ និងចំណេះដឹងសម្រាប់ក្រុមហ៊ុន និងសាធារណៈជនដែលមានបំណងចង់ទទួលបានហិរញ្ញប្បទានតាមរយៈទីផ្សារមូលបត្រ និងស្វែងយល់ពីដំណើរការនៃការជួញដូរ និងនីតិវិធីផ្សេងៗទៀត មុននឹងធ្វើការសម្រេចចិត្តវិនិយោគលើភាគហ៊ុន។
- ➢ ទទួលបានព័ត៌មានទាក់ទងនឹងទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១ និងសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ នៅក្នុងត្រីមាសនីមួយៗ នៃឆ្នាំ ២០២១។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍នេះត្រូវបានចែកជា ៣ ជំពូកដូចខាងក្រោម៖

- **សេចក្តីផ្តើម៖** ក្នុងផ្នែកនេះ នឹងបង្ហាញអំពីលំនាំបញ្ហា ចំណោទបញ្ហានៃការស្រាវជ្រាវ កម្មវត្ថុ ដែនកំណត់ និងវិសាលភាព វិធីសាស្ត្រ និងសារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទនេះ។
- **ជំពូកទី១៖ ការរំលឹកទ្រឹស្តី**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីការលើកឡើងនូវទ្រឹស្តីផ្សេងៗ ដែលទាក់ទងនឹងប្រធានបទដូចជា មូលបត្រ ប្រភេទនៃមូលបត្រកម្មសិទ្ធិ ទីផ្សារមូលបត្រ អ្នកចូលរួមសំខាន់ៗក្នុងទីផ្សារមូលបត្រ អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយ ព្រមទាំងគុណវិបត្តិនៃទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច។
- **ជំពូកទី២៖ ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញអំពីប្រវត្តិនៃការបង្កើតនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចក្ខុវិស័យ បេសកកម្ម នាមករណ៍ និងផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រ និងតួអង្គពាក់ព័ន្ធក្នុងនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។
- **ជំពូកទី៣៖ ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា**

  ក្នុងជំពូកនេះ នឹងធ្វើការបង្ហាញពីដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា ទិដ្ឋភាពទូទៅនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងទិន្នន័យសំខាន់ៗទាក់ទងការជួញដូរមូលបត្រកម្មសិទ្ធិសម្រាប់ឆ្នាំ ២០២១។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

# រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១

# រំលឹកទ្រឹស្តី

# ជំពូកទី១

# រំលឹកទ្រឹស្តី

## ១.១. មូលបត្រ

### ១.១.១. និយមន័យមូលបត្រ

មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុមួយប្រភេទ តែមានលក្ខណៈប្លែកពីគេ និងតម្លៃរបស់វាមិនមានទំនាក់ទំនងទៅនឹងទ្រង់ទ្រាយ ឬរូបរាងរបស់វាឡើយ ប៉ុន្តែវាអាស្រ័យទៅនឹងសិទ្ធិកាន់កាប់នូវផលប្រយោជន៍នាពេលអនាគត និងមិនមានតម្លៃប្រើប្រាស់ ដូចជា ម៉ូតូ រថយន្ត ដី....នោះទេ។[1]

តែបើយោងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម "មូលបត្រ ជាគំរូបណ្ណដែលអាចដោះដូរបានជាសាធារណៈ ឬលើទីផ្សារមូលបត្រ"។ មូលបត្រ ជាភាគហ៊ុនដែលអាចជាចលនទ្រព្យរូបិយ ឬអរូបិយ។ សព្វថ្ងៃនេះនៅកម្ពុជា មូលបត្រមានទម្រង់ជាអរូបិយ ដែលបានរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រ (CSD)។

❖ **ចំណុចពិសេសមូលបត្រនៅក្នុងទីផ្សារមូលបត្រ**

មូលបត្រ នៅក្នុងទីផ្សារមូលបត្រមានចំណុចពិសេសដូចជា[2]៖

- គឺជាបណ្ណាក្រដាសបញ្ជាក់ពីតម្លៃទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ
- គឺជាឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម និងវែង
- ត្រូវបានការពារពីច្បាប់មូលបត្រ
- ត្រូវបានអនុញ្ញាតដោះដូរផ្ទេរកម្មសិទ្ធិនៅលើទីផ្សារមូលបត្រ មានន័យថា Liquidity ខ្ពស់។

### ១.១.២. ប្រភេទនៃមូលបត្រ

#### ១.១.២.១. មូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិពីសាធារណៈជន ហើយមានសិទ្ធិក្នុងការទទួលបានភាគលាភនៅក្នុងអង្គភាពមួយ។[3]

#### ១.១.២.២. មូលបត្របំណុល

មូលបត្របំណុល ឬសញ្ញាបណ្ណ គឺជាមូលបត្រដែលបញ្ជាក់ពីបំណុលរយៈពេលវែង របស់អ្នកបោះផ្សាយ ហើយអ្នកបោះផ្សាយសញ្ញាបណ្ណ ត្រូវមានមុខងារសងការប្រាក់ និងតម្លៃសញ្ញាបណ្ណដល់ម្ចាស់កម្មសិទ្ធិសញ្ញាបណ្ណ

---

[1] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ទំព័រ ៣៤-៣៥

[2] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ ទំព័រ ៣៥-៣៦

[3] បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ ទំព័រ ៣៥-៣៦

នៅពេលដល់កាលកំណត់របស់សញ្ញាបណ្ណនោះ។[4]

សញ្ញាបណ្ណអាចបែងចែកជាច្រើនប្រភេទខុសគ្នា ប៉ុន្តែប្រសិនបើផ្អែកទៅលើអ្នកបោះផ្សាយសញ្ញាបណ្ណ រួមមានពីរប្រភេទគឺ សញ្ញាបណ្ណសាជីវកម្ម និងសញ្ញាបណ្ណរដ្ឋ។

- **សញ្ញាបណ្ណសាជីវកម្ម៖** គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម ក្នុងគោលដៅប្រមូលមូលធន ដើម្បីបន្ថែមលើមូលធនបណ្តោះអាសន្នបម្រើឲ្យការវិនិយោគបន្ថែមទៀតសម្រាប់ក្រុមហ៊ុន។ សញ្ញាបណ្ណសាជីវកម្ម អាចបោះផ្សាយជាប្រភេទសញ្ញាបណ្ណដូចជា៖ Mortgage Bonds, Convertible Bond, Income Bond, Zero Coupon Bond…. ។
- **សញ្ញាបណ្ណរដ្ឋ៖** គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយរដ្ឋាភិបាល ដើម្បីប្រមូលថវិកាចូលរដ្ឋ ក្នុងគោលបំណងកសាងហេដ្ឋារចនាសម្ព័ន្ធស្ថាប័នសាធារណៈដូចជា មន្ទីរពេទ្យ ស្ពាន ថ្នល់ សាលារៀន ជាដើម។ សញ្ញាបណ្ណប្រភេទនេះ ជាទូទៅមានសុវត្ថិភាពបំផុត ពីព្រោះមូលធនត្រូវបានរដ្ឋាភិបាលជាអ្នកធានា ហើយអ្នកទិញវាភាគច្រើនត្រូវបានរួចពន្ធលើប្រាក់ចំណូល។ សញ្ញាបណ្ណរដ្ឋ អាចបោះផ្សាយតាមរយៈពេលនៃប្រភេទសញ្ញាបណ្ណដែលមាន ដូចជា៖ Treasury Bonds, Municipal Bond, State Bonds,…។

#### ១.១.២.៣. ឧបករណ៍និស្សន្ទ

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ សំដៅដល់កិច្ចសន្យាដែលផ្តល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឲ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់សិទ្ធិនេះក៏ដោយ។[5]

## ១.២. ប្រភេទនៃមូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិ គឺជាមូលត្រដែលបានបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ ដើម្បីគៀងគរមូលនិធិឯកជន ហើយមានសិទ្ធិក្នុងការទទួលបានភាគលាភនៅក្នុងអង្គភាពមួយ។ ប្រភេទនៃមូលបត្រកម្មសិទ្ធិរួមមាន[6]៖

### ១.២.១. ភាគហ៊ុនធម្មតា

គឺជាមូលបត្រទ្រព្យមិនមានរយៈពេលកំណត់ វាបិតបេរទៅតាមការបិតបេររបស់ក្រុមហ៊ុនដែរ និងភាគលាភត្រូវសងនៅចុងឆ្នាំ។ ជាទូទៅម្ចាស់កាន់កាប់ភាគហ៊ុនធម្មតានេះ មានសិទ្ធិក្នុងការចូលរួមបោះឆ្នោតនានានៅក្នុងក្រុមហ៊ុន ដូចជា ការបោះឆ្នោតជ្រើសរើសគណៈគ្រប់គ្រង ជាដើម ហើយទទួលបានភាគលាភមានការប្រែប្រួល និងទទួលបានបន្ទាប់ពីការបែងចែកទៅឲ្យភាគហ៊ុនបុរិមា។

[4] សួន ចំរើន (២០១៧) ទីផ្សារ និងស្ថានប័នហិរញ្ញវត្ថុ១ ទំព័រ ៤០-៤៣

[5] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន សទ្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ (២០០៧) ទំព័រ ៩

[6] បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ ទំព័រ ៣៥-៣៦

#### ១.២.២. ភាគហ៊ុនបុរិមា

មានលក្ខណៈដូចគ្នាទៅនឹងភាគហ៊ុនធម្មតាដែរ តែអ្នកកាន់កាប់ភាគហ៊ុននេះនៅពេលបែងចែកភាគលាភភ្លាមគឺទទួលបានមុនគេ ហើយភាគលាភត្រូវបានកំណត់ជាក់លាក់ពីដំបូងលើទឹកប្រាក់កំណត់មួយ។ បន្ថែមពីនេះអ្នកកាន់កាប់ភាគហ៊ុនបុរិមាពុំមានសិទ្ធិបោះឆ្នោតផ្សេងៗក្នុងក្រុមហ៊ុនទេ។

### ១.៣. ទីផ្សារមូលបត្រ

#### ១.៣.១. និយមន័យទីផ្សារមូលបត្រ

ផ្សារមូលបត្រជាកន្លែងដែលមូលបត្រ ដូចជាភាគហ៊ុន និងសញ្ញាបណ្ណត្រូវបានទិញនិងលក់។ យោងតាមនិយមន័យចែងនៅក្នុងច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬធ្វើការទិញ-លក់មូលបត្រ ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។[7]

#### ១.៣.២.ប្រវត្តិទីផ្សារមូលបត្រ

វាមានឯកសារជាច្រើនស្តីអំពី ប្រវត្តិនៃការកកើតទីផ្សារមូលបត្រ ដែលជាក់ស្តែងទីផ្សារភាគហ៊ុនមានតាំងពីយូរយារណាស់មកហើយ ប៉ុន្តែមានប្រទេសជាច្រើននៅតែប្រើប្រាស់ពាក្យ "**ទីផ្សារភាគហ៊ុន**"។ ទស្សនៈសម័យទំនើបស្តីពីការបង្កើតទីផ្សារមូលបត្រ បានចាប់ផ្តើមតាំងពីចុងសតវត្សទី១៦។ ទីផ្សារភាគហ៊ុន បានផ្តើមនៅពេលបណ្តាប្រទេសនៅទ្វីបអាមេរិក (The New World) បានចាប់ផ្តើមធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀតមានដូចជា ហូឡង់ ព័រទុយហ្គាល់ និងអេស្ប៉ាញ។ ខណៈពេលដែលឈ្មួញធំៗនៅអឺរ៉ុប មានបំណងចាប់ផ្តើមអាជីវកម្មទំហំធំ ដែលទាមទារឲ្យមានចំនួនទឹកប្រាក់ច្រើន ពុំមានឈ្មួញណាម្នាក់មានទឹកប្រាក់ច្រើនសន្ធឹកសន្ធាប់ សម្រាប់ចាប់ផ្តើមអាជីវកម្មដ៏ធំបានតែម្នាក់ឯងនោះទេ។ ជាលទ្ធផល វិនិយោគិនបានយកប្រាក់សន្សំរបស់ពួកគេទៅដាក់ទុនរួម ហើយបានក្លាយជាដៃគូអាជីវកម្ម និងសហកម្មសិទ្ធិជាមួយនឹងចំណែកភាគហ៊ុនរបស់ខ្លួន នៅក្នុងអាជីវកម្មមួយដែលមានទម្រង់រួមទុន។ ក្រុមហ៊ុនរួមទុន ដែលមានដើមកំណើតនៅប្រទេសហូឡង់បានក្លាយជាគំរូអាជីវកម្មមួយ សម្រាប់អាជីវកម្មមួយដែលកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ ។ នៅក្នុងឆ្នាំ ១៦០២ ក្រុមហ៊ុនឌី ខាចហ៍ អីស ឥណ្ឌា (The Dutch East India Co.) បានបោះផ្សាយក្រដាសតំណាងភាគហ៊ុន មានភាពងាយស្រួលក្នុងការទិញលក់ និងធ្វើការជួញដូរភាគហ៊ុនរបស់ខ្លួនជាមួយនឹងម្ចាស់ភាគហ៊ុនផ្សេងៗ និងវិនិយោគិនដទៃទៀត។

គំនិតនេះទទួលបានជោគជ័យ ដោយការលក់ភាគហ៊ុនបានរីករាលដាល ដល់ប្រទេសមហាអំណាចដែនសមុទ្រផ្សេងទៀតដូចជា ប្រទេសព័រទុយហ្គាល អេស្ប៉ាញ និងបារាំង។ នៅទីបំផុតការអនុវត្តគំនិតនេះ ក៏បានរីករាលដាល

[7]http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

ដល់ចក្រភពអង់គ្លេស។ ឧស្សាហកម្មដ៏ទៃទៀត ក្នុងកំឡុងពេលបដិវត្តន៍ឧស្សាហកម្ម បានចាប់ផ្តើមប្រើប្រាស់ការលក់ភាគហ៊ុនជាវិធីមួយ ដើម្បីប្រមូលមូលធនសម្រាប់ធ្វើអាជីវកម្ម។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍន៍នៃពិភពលោកថ្មី (The New World) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឲ្យមានការបង្កើតទីកន្លែងច្បាស់លាស់មួយសម្រាប់ជួញដូរ។ ជាលទ្ធផលពាណិជ្ជករភាគហ៊ុន បានសម្រេចចិត្តទៅជួបគ្នា នៅហាងកាហ្វេមួយនៅទីក្រុងឡុងដ៍។ ក្រោយមកហាងកាហ្វេនោះត្រូវបានពាណិជ្ជករភាគហ៊ុនទិញយក ហើយប្រែឈ្មោះក្លាយជាទីផ្សារភាគហ៊ុនដែលមានការរៀបចំ និងគ្រប់គ្រងត្រឹមត្រូវនៅក្នុងឆ្នាំ ១៧៧៣។

ទីផ្សារភាគហ៊ុនទីក្រុងឡុងដ៍ (The London Stock Exchange) ជាទីផ្សារភាគហ៊ុនផ្លូវការដំបូងគេ។ គំនិតនៃការរៀបចំបែបនេះ ក៏បានហូរចូលទៅក្នុងប្រទេសអាមេរិក ហើយក៏បានចាប់ផ្តើមនៅទីក្រុង ភីឡាដែលភីយ៉ា (Philadelphia) ក្នុងឆ្នាំ ១៧៩០។[8]

### ១.៣.៣. ប្រភេទទីផ្សារមូលបត្រ

ជាទូទៅ ទីផ្សារមូលបត្រត្រូវបានបែងចែកជាពីរ គឺទីផ្សារដំបូង និងទីផ្សារបន្ទាប់។

#### ១.៣.៣.១. ទីផ្សារដំបូង

ទីផ្សារដំបូង គឺជាកន្លែងដែលមូលបត្រត្រូវបានបោះចេញដោយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ លក់ទៅឲ្យសាធារណៈជន ដើម្បីទទួលបាននូវហិរញ្ញប្បទាន ឬមូលធនយកទៅវិនិយោគ។ នៅក្នុងដំណាក់កាលទីផ្សារដំបូងនេះហើយដែលក្រុមហ៊ុន ឬសហគ្រាស ធ្វើការប្រមូលទុនពីសាធារណជន ឬវិនិយោគិនដែលបានចូលរួមទិញមូលបត្រដែលបោះចេញដោយក្រុមហ៊ុន។ ដំណើរការដែលក្រុមហ៊ុនលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនេះ ត្រូវបានហៅថា "ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង" ឬជាភាសាអង់គ្លេសហៅថា "Initial Public Offering (IPO)។ នៅក្នុងដំណាក់កាលនៃទីផ្សារដំបូង វិនិយោគិនអាចទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។ រាល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជា ត្រូវទទួលបានការអនុញ្ញាតជាមុនពីនិយ័តករមូលបត្រកម្ពុជា **(ន.ម.ក.)** ដែលជានិយ័តករតែមួយគត់ក្នុងវិស័យមូលបត្រ។

#### ១.៣.៣.២. ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ គឺជាកន្លែងដែលមូលបត្រត្រូវបានជួញដូរបន្តរវាងអ្នកទិញ និងអ្នកលក់ ដែលជាវិនិយោគិន។ មានន័យថាវិនិយោគិនដែលបានទិញមូលបត្ររួចក្នុងទីផ្សារដំបូង អាចលក់ចេញវិញបានទៅឲ្យវិនិយោគិនមួយផ្សេងទៀត។ ដោយឡែកប្រាក់ដែលបានមកពីសកម្មភាពជួញដូរលើទីផ្សារបន្ទាប់ គឺបានទៅលើអ្នកកាន់កាប់មូលបត្រ មិន

[8] គណៈកម្មការមូលបត្រកម្ពុជា ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ២ ខែមករា ឆ្នាំ២០១៧ ទំព័រ ១២

មែនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រឡើយ ពោលគឺក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ មិនទទួលផលប្រយោជន៍សេដ្ឋកិច្ចពីការជួញដូរលើទីផ្សារបន្ទាប់ឡើយ។ សម្រាប់ប្រទេសកម្ពុជា អ្នកដែលផ្ដល់កន្លែងសម្រាប់ជួញដូរមូលបត្រនៅលើទីផ្សារបន្ទាប់ គឺក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលជាប្រតិបត្តិករទីផ្សារមូលបត្រទទួលបានការអនុញ្ញាតពីគណៈកម្មការមូលបត្រកម្ពុជា។[9]

ទីផ្សារបន្ទាប់អាចប្រតិបត្តិការតាមរយៈ ៖

- ទីផ្សារមូលបត្រ (Organized Exchange)៖ សំដៅលើការជួញដូរមូលបត្រ តាមរយៈទីផ្សារមូលបត្រ ដែលមានទីកន្លែងជួញដូរជាក់លាក់មួយ មានវិធានទីផ្សារ និងមានប្រព័ន្ធជួញដូរ ដើម្បីគ្រប់គ្រងដំណើរការជួញដូរ។
- ទីផ្សារមូលបត្រក្រៅប្រព័ន្ធ (Over-the-counter - OTC)៖ សំដៅលើការជួញដូរមូលបត្រក្រៅប្រព័ន្ធទីផ្សារមូលបត្រ ដែលពុំមានទីកន្លែងជួញដូរជាក់លាក់ និងមិនផ្លូវការនោះទេ។ វិនិយោគិនអាចជួញដូរមូលបត្រ ដោយការចរចារតាមរយៈទូរស័ព្ទ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ។ ភាគច្រើននៃទីផ្សារនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ជាអ្នកដាក់នូវការកំណត់ថ្លៃទិញ-លក់ជូនអតិថិជន និងក្រុមហ៊ុនពាណិជ្ជករដទៃទៀត។ បច្ចុប្បន្ននៅប្រទេសកម្ពុជាយើង មានតែទីផ្សារមូលបត្រ (Organized Exchange) ដែលដំណើរការពុំមានទីផ្សារ OTC នោះទេ។

## ១.៤. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

### ១.៤.១.អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះវិនិយោគិន

មានមតិមួយចំនួនលើកឡើងថា ការជួញដូមូលបត្រប្រៀបបានទៅនឹងការលេងល្បែងស៊ីសង។ ប៉ុន្តែបើយើងវិភាគឲ្យបានច្បាស់ ការវិនិយោគ និងការលេងល្បែងស៊ីសងមានលក្ខណៈខុសគ្នាទាំងស្រុង ។ ការលេងល្បែងពឹងលើព្រេងសំណាងដែលគ្មានអ្វីមកបញ្ជាក់ថាឈ្នះនោះទេ។ ដោយឡែកការវិនិយោគទៅលើវិស័យមូលបត្រ គឺអាស្រ័យលើការរកស៊ីរបស់ក្រុមហ៊ុន ហើយមុនពេលជ្រើសរើសទិញមូលបត្ររបស់ក្រុមហ៊ុនណាមួយ គឺគេបានមើលពីស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពក្រុមហ៊ុនរួចហើយ។ វិនិយោគិនអាចទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីការជួញដូរមូលបត្រនៅទីផ្សារមូលបត្រដូចជា៖

**ក. ឱកាសវិនិយោគ និងប្រាក់ចំណេញ៖** ជំនួសឲ្យ ឬបន្ថែមលើការបើកអាជីវកម្មផ្ទាល់ខ្លួន ការកាន់កាប់ភាគហ៊ុនផ្ដល់ឲ្យវិនិយោគិននូវឱកាស ដើម្បីចូលរួមក្នុងអាជីវកម្មដោយមិនចាំបាច់មានជំនាញ និងបទពិសោធន៍ជាក់លាក់ ឬ

[9] គណៈកម្មការមូលបត្រកម្ពុជា មគ្គុទេសក៍ស្ដីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧ ទំព័រទី ៤

ការគ្រប់គ្រងដោយផ្ទាល់នោះទេ។ ទន្ទឹមនឹងនេះ ការកាន់កាប់ភាគហ៊ុនអាចផ្ដល់ផលចំណេញខ្ពស់ ដែលបានមកពីការបែងចែកភាគលាភ និងការចំណេញពីការជួញដូរភាគហ៊ុន។

**ខ. ផ្ដល់លទ្ធភាពសម្រាប់វិនិយោគិនតូចៗ៖** ទីផ្សារភាគហ៊ុនអនុញ្ញាតឲ្យនិយោគិន ដែលមានប្រាក់សមល្មម អាចវិនិយោគលើក្រុមហ៊ុនធំ ហើយទទួលបានផលចំណេញមកវិញដូចទៅនឹងបុគ្គល ឬស្ថាប័នដែលមានប្រាក់ច្រើន ដោយផ្អែកលើចំនួនភាគហ៊ុនដែលពួកគេកាន់កាប់។

**គ. ការធ្វើពិពិធកម្មការវិនិយោគ៖** ក្រៅពីប្រភពចំណូលសំខាន់ៗ របស់អ្នកដូចជាប្រាក់ខែ ឬប្រាក់ចំណេញពីអាជីវកម្ម និងប្រាក់ចំណូលបន្ថែមផ្សេងទៀត ដូចជា ការប្រាក់ពីប្រាក់បញ្ញើសន្សំនៅធនាគារ ការជួលផ្ទះ ឬការវិនិយោគលើអចលនទ្រព្យ អ្នកអាចវិនិយោគនៅក្នុងផ្សារហ៊ុនដើម្បីធ្វើពិពិធកម្មវិនិយោគ។

**ឃ. មានទីផ្សារដែលអាចទិញលក់ប្រចាំថ្ងៃ៖** ការវិនិយោគលើភាគហ៊ុនមានលក្ខណៈពិសេសជាង ការវិនិយោគលើទ្រព្យសកម្មដទៃ ដោយហេតុថាទីផ្សារភាគហ៊ុនមានរចនាសម្ព័ន្ធពេញលេញ ដែលអនុញ្ញាតឲ្យវិនិយោគិន ទិញលក់ បានប្រចាំថ្ងៃ។ ក្នុងន័យនេះ វិនិយោគិនអាចបង្វែរភាគហ៊ុន ទៅជាសាច់ប្រាក់បានយ៉ាងងាយ តាមរយៈការជួញដូរ ដែលធ្វើឡើងជារៀងរាល់ថ្ងៃ។ ផ្ទុយទៅវិញការវិនិយោគដោយផ្ទាល់ទៅក្នុងអាជីវកម្ម ឬអចលនទ្រព្យ មិនបានផ្ដល់លក្ខណៈងាយស្រួល ក្នុងការបង្វែរជាសាច់ប្រាក់ ដូចការវិនិយោគលើភាគហ៊ុនឡើយ។

**ង. ការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធន៖** អ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក ៥០ (ហាសិប) ភាគរយលើការប្រាក់ និង/ឬភាគលាភដែលបានមកពីការកាន់កាប់ និង/ឬការទិញ-លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធនចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬមូលបត្របំណុល សម្រាប់រយៈពេល៣ (បី)ឆ្នាំ គិតចាប់ពីថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០២២។[10]

### ១.៤.២. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

**ក. ទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង៖** នៅពេលគិតគូរអំពីគម្រោងពង្រីកអាជីវកម្មរបស់ខ្លួន សហគ្រាសខ្នាតតូច និងមធ្យម ជានិច្ចកាលតែងជួបប្រទះបញ្ហាខ្វះខាតទុនសម្រាប់វិនិយោគ និងសម្រាប់ប្រើប្រាស់ជាទុនបង្វិល។ សហគ្រាសជាទូទៅមានប្រភពហិរញ្ញប្បទានច្រើនពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ប៉ុន្តែភាគច្រើននៃប្រភពហិរញ្ញប្បទានទាំងនោះ ជាហិរញ្ញប្បទានរយៈពេលខ្លី ដែលអាចជារនាំងនៃការអភិវឌ្ឍផែនការអាជីវកម្មរយៈពេលវែងរបស់ក្រុមហ៊ុន។ ផ្ទុយទៅវិញ ជាមួយនឹងទីផ្សារមូលបត្រ សហគ្រាសទាំងនេះ អាចទទួលបានហិរញ្ញប្បទានរយៈពេលវែង តាមរយៈការបោះផ្សាយភាគហ៊ុន និងលក់ទៅឲ្យសាធារណៈជន ហើយទទួលបាននូវមូលនិធិសម្រាប់រួមចំណែកក្នុងការអនុវត្ត

[10] http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

ផែនការអាជីវកម្មរយៈពេលវែងរបស់សហគ្រាស ដោយសហគ្រាសគ្រាន់តែទូទាត់ត្រឡប់ទៅវិនិយោគិនវិញជាភាគលាភ ដែលអាស្រ័យទៅតាមផលចំណេញជាក់ស្តែងរបស់សហគ្រាស និងលទ្ធភាពក្នុងការដកសាច់ប្រាក់។

**ខ. ទទួលបានការលើកទឹកចិត្តពន្ធ៖** ក្រុមហ៊ុនទាំងអស់ដែលទទួលបានការអនុញ្ញាតពី ន.ម.ក. បោះផ្សាយលក់មូលបត្រជាសាធារណៈ និងចុះបញ្ជីលក់នៅ ផ.ម.ក. នឹងទទួលបានការកាត់បន្ថយពន្ធលើប្រាក់ចំណូលតាមទំហំនៃការបោះផ្សាយមូលបត្រ ដូចមានចែងក្នុងអនុក្រឹត្រស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ លេខ ៤២ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ក្នុងរយៈពេលបីឆ្នាំ។ ស្របពេលជាមួយគ្នានេះដែរ ក្រុមហ៊ុនក៏ទទួលបានការអនុគ្រោះបំណុលពន្ធ ដែលរួមបញ្ចូលពន្ធលើប្រាក់ចំណូលទាំងស្រុង ពន្ធកាត់ទុក អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ។ ការបោះផ្សាយមូលបត្រកម្មសិទ្ធ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ និងចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត មិនតម្រូវឲ្យមានការធ្វើសវនកម្មពេញលេញជាមុនពីអគ្គនាយកដ្ឋានពន្ធដារនោះទេ។ សម្រាប់ការស្នើសុំបោះផ្សាយក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈ ត្រូវផ្តល់ជូន ន.ម.ក. នូវវិញ្ញាបនបត្របញ្ជាក់កាតព្វកិច្ចពន្ធចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដែលជាលិខិតសម្រាប់បញ្ជាក់ពីការប្រកាស និងបង់ពន្ធជាប្រចាំដោយមិនទាន់រងការធ្វើសវនកម្មពីអគ្គនាយកដ្ឋានពន្ធដារ។

**គ. ទទួលបាននិរន្តរភាពអាជីវកម្ម ជាមួយនឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងដែលរឹងមាំជាងមុន៖** ការបង្កើតសហគ្រាសអាជីវកម្មមួយ គឺត្រូវប្រឈមនឹងបញ្ហាជាច្រើន ប៉ុន្តែការរក្សាអាជីវកម្មឲ្យមានចេរភាព គឺរឹតតែជាការងារដ៏លំបាកមួយ និងជាការប្រឈមដ៏ធំសម្រាប់ម្ចាស់អាជីវកម្ម។ សហគ្រាសខ្នាតតូច និងមធ្យម តែងតែជាកម្មវត្ថុនៃការបារម្ភនានា អំពីអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន។ យ៉ាងណាមិញនៅពេលដែលសហគ្រាសទាំងនោះ បានក្លាយជាក្រុមហ៊ុនចុះបញ្ជី ពួកគេនឹងអាចធ្វើឲ្យប្រសើរឡើងនូវអភិបាលកិច្ចសាជីវកម្ម តាមរយៈការរៀបចំឲ្យមានរចនាសម្ព័ន្ធក្រុមប្រឹក្សាភិបាល ដែលមានតួនាទីពិនិត្យលើការបំពេញមុខងាររបស់ថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន។ បន្ថែមលើនេះទៀត ម្ចាស់អាជីវកម្ម អាចពង្រឹងយន្តការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុន ដែលអាចកាត់បន្ថយការអនុវត្តការងារមិនត្រឹមត្រូវ ឬការគៃបន្លំផ្សេងៗក្នុងដំណើរការអាជីវកម្មប្រចាំថ្ងៃ។ ជាលទ្ធផលអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងផ្ទៃក្នុង នឹងជួយដល់សហគ្រាសខ្នាតតូច និងមធ្យមឲ្យមានការរីកចម្រើន ប្រកបដោយនិរន្តរភាព។ ការទទួលយកការអនុវត្តអភិបាលកិច្ចសាជីវកម្ម និងអាចជួយដល់ការត្រៀមខ្លួន របស់សហគ្រាសខ្នាតតូច និងមធ្យមក្នុងការប្រកួតប្រជែងជាមួយគូប្រកួតប្រជែងក្នុងតំបន់អាស៊ាន ។

**ឃ. ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន៖** ក្រុមហ៊ុនចុះបញ្ជីមួយ ជាទូទៅទាក់ទាញចំណាប់អារម្មណ៍របស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស តាមរយៈប្រព័ន្ធព័ត៌មានវិទ្យា និងសាធារណជន ហើយកិច្ចប្រតិបត្តិការអាជីវកម្ម ឬហិរញ្ញវត្ថុ តែងត្រូវបានផ្សព្វផ្សាយតាមរយៈកាសែត ទូរទស្សន៍ និងគេហទំព័រផ្សេងៗ ព្រមទាំងត្រូវបានលើកឡើងទាំងក្នុង និងក្រៅប្រទេសផងដែរ។ ប្រការនេះ អាចជួយកែលម្អនូវរូបភាព និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន ដែលអាចឲ្យសាធារណជនស្គាល់កាន់តែច្រើនអំពីផលិតផល និងសេវាកម្មរបស់ក្រុមហ៊ុន។ តាមរយៈនេះ

ក្រុមហ៊ុនក៏អាចពង្រឹងនូវឧត្តមភាពប្រកួតប្រជែងរបស់ខ្លួនចំពោះដៃគូប្រកួតប្រជែង ដែលមិនមែនជាក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅក្នុង បរិបទនៃសេដ្ឋកិច្ចសកលភាវូបនីយកម្ម ដែលពោពេញទៅដោយការប្រកួតប្រជែងនេះ។

**ង. ការត្រៀមខ្លួនជាមុនចំពោះបទបញ្ញត្តិរបស់រាជរដ្ឋាភិបាលៈ** ក្រុមហ៊ុនទាំងអស់ កំពុងតែត្រូវបានឃ្លាំមើលដោយរាជរដ្ឋាភិបាល អំពីការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេ ដែលរួមទាំងការអនុវត្តពន្ធ ការកាន់បញ្ជីគណនី និងការធ្វើសវនកម្មជាដើម។ សេរីភាពដែលកំពុងចមចយនេះ នឹងជម្រុញឲ្យចាប់ផ្តើមអនុវត្តឲ្យបានឆាប់នូវកាតព្វកិច្ចច្បាប់នានា និងការក្លាយខ្លួនជាក្រុមហ៊ុនចុះបញ្ជីនៅក្នុងទីផ្សារមូលបត្រ។[11]

### ១.៤.៣. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ

ទីផ្សារមូលបត្រជាឧបករណ៍វាស់ស្ទង់សេដ្ឋកិច្ច មានន័យថា ទីផ្សារមូលបត្រត្រូវបានគេចាត់ទុកជាជីពចរនៃសេដ្ឋកិច្ច ឬជាកញ្ចក់ដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ត្បិតទីផ្សារមូលបត្រជាសូចនាករសេដ្ឋកិច្ចសំខាន់ ដែលជាជំនួយសម្រាប់វិនិយោគិន ក្នុងការរៀបចំ និងសម្រេចចិត្តវិនិយោគឲ្យបានត្រឹមត្រូវ ហើយទីផ្សារមូលបត្រក៏អាចជួយពង្រីកចំណេះដឹងរបស់ប្រជាជន អំពីស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសផងដែរ។ បន្ថែមពីនេះ ទីផ្សារមូលបត្រដើរតួនាទីយ៉ាងសំខាន់ ក្នុងសេដ្ឋកិច្ចរបស់ប្រទេសមួយ ដោយវាអនុញ្ញាតឲ្យក្រុមហ៊ុនសាជីវកម្ម សហគ្រាសសាធារណ និងរាជរដ្ឋាភិបាល អាចប្រមូលទុនដោយផ្ទាល់ពីសាធារណជន មកប្រើប្រាស់ដើម្បីពង្រីកអាជីវកម្ម ឬអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។ ម្យ៉ាងវិញទៀត អ្នកដែលមានប្រាក់សល់ពីការចំណាយ មានជម្រើសក្នុងការធ្វើពិពិធកម្មសំណុំវិនិយោគរបស់ខ្លួន ឬធ្វើការសន្សំ (ជាមួយមូលបត្រដែលមានហានិភ័យទាប) នៅក្នុងទីផ្សារមូលបត្រ។ នៅពេលដែលសាច់ប្រាក់ហូរពីអ្នកមាន ឬអ្នកដែលមានសាច់ប្រាក់លើសតម្រូវការ ទៅអ្នកដែលត្រូវការប្រកបដោយប្រសិទ្ធិភាព ពេលនោះសកម្មភាពសេដ្ឋកិច្ចដូចជា ផលិតកម្ម និងពាណិជ្ជកម្ម នឹងរីកលូតលាស់ទៅតាមនោះដែរ ព្រមទាំងបង្កើតឲ្យមានឱកាសសការងារតាមរយៈការវិនិយោគបន្ថែម និងបង្កើនទ្រព្យសម្បត្តិសម្រាប់ប្រជាជនទូទៅ។ បន្ថែមពីនេះទៀត ការកើនឡើងនៃទីផ្សារមូលបត្រកម្ពុជា អាចធ្វើឲ្យមានការទាក់ទាញវិនិយោគិនមកប្រទេសកម្ពុជា ពីព្រោះថាក្រុមហ៊ុនបរទេសធំៗ ដែលមានបំណងមកវិនិយោគនៅកម្ពុជា អាចបោះផ្សាយលក់មូលបត្រ នៅទីផ្សារមូលបត្រកម្ពុជា និងវិនិយោគនៅកម្ពុជាតែម្តង។ នៅពេលមានទីផ្សារនេះ អាចជួយជំរុញឲ្យក្រុមហ៊ុនត្រូវប្រកាន់ខ្ជាប់អភិបាលកិច្ចល្អ តម្លាភាពដោយផ្តល់នូវទំនុកចិត្តដល់សាធារណៈជន ដែលករណីនេះបង្កើតបានបរិយាកាសប្រកួតប្រជែងរវាងក្រុមហ៊ុនដែលមានអភិបាលកិច្ចល្អ មានតម្លាភាព និងក្រុមហ៊ុនដែលមិនមានអភិបាលកិច្ចល្អ និងគ្មានតម្លាភាព។ ដូច្នេះទីផ្សារមូលបត្រ មានសារៈសំខាន់សម្រាប់ជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចលនារស់រវើក និងជាការពង្រីកនូវប្រភពហិរញ្ញវត្ថុសម្រាប់កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសកម្ពុជា។[12]

[11] http://csx.com.kh/kh/product/blisting.jsp?MNCD=3010 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

[12] http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

## ១.៥. គុណវិបត្តិទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច

បើទោះបីជាទីមូលបត្រមានគុណសម្បត្តិដ៏សំខាន់ សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ក៏ដោយក៏មានគុណវិបត្តិមួយចំនួនដែរ ជាពិសេសសម្រាប់បណ្តាប្រទេសមានប្រព័ន្ធច្បាប់ទន់ខ្សោយ ដែលតែងតែជួបប្រទះនូវបញ្ហាដូចខាងក្រោម ៖

**ក. ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់ (Speculation)៖** គឺជាការជួញដូរមួយដែលមានការគិតគូរយ៉ាងហ្មត់ចត់ ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់នេះ អាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានាពេលអនាគត នឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាសកេងចំណេញក្នុងការទិញ-លក់របៀបនេះ វានឹងបង្កឲ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើឲ្យមានភាពងាយស្រួល នៅពេលពួកគេត្រូវរ៉ូវគ្នាក្នុងការជួញដូរ ដែលនាំឲ្យស្ថានភាពនៅលើទីផ្សារ មានពេលខ្លះធ្វើឲ្យភាគហ៊ុនខ្វះ ឬលើស ហើយធ្វើឲ្យមានចលនាឡើងចុះតម្លៃ នៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ។

**ខ. ការជួញដូរផ្ទៃក្នុង៖** មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជី ឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុន ដើម្បីធ្វើការជួញដូរភាគហ៊ុន ស្វែងរកប្រាក់ចំណេញរបស់ខ្លួន ដែលមានឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ។

**គ. ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ៖** គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេសមិនធ្វើសកម្មភាព ដែលបណ្តាលឲ្យ ឬអាចបណ្តាលឲ្យមានលក្ខណៈក្លែងបន្លំ ឬនាំឲ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការ ធ្វើផែនការជួញដូដែលមានលក្ខណៈសិប្បនិម្មិតទាក់ទងនឹងមូលបត្រ នៅលើទីផ្សារមូលបត្រ។

**ឃ. សេចក្តីថ្លែង ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ៖** ឬដែលនាំឲ្យមានការយល់ខុសធ្ងន់ធ្ងរ ដែលបណ្តាលឲ្យសាធារណជនទិញ-លក់មូលបត្រ ឬបណ្តាលឲ្យមានការកើនឡើង ឬថយចុះ ឬនៅថេរ ចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

**ង. ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រ៖** តម្រូវឲ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចសាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។[13]

[13] http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនា ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២)

# ជំពូកទី២
# ស្ថានភាពទូទៅ
# នៃនិយ័តករមូលបត្រកម្ពុជា
# និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ២.១. និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)

### ២.១.១. ប្រវត្តិសង្ខេបរបស់និយ័តករមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជាត្រូវបានហៅកាត់ថា (គ.ម.ក.) ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំនិងការប្រព្រឹត្តទៅនៃ គ.ម.ក. ត្រូវបានធ្វើឡើងដោយអនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជាដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។[14] គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានសម្ពោធជាផ្លូវការ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។[15]

គណៈកម្មការមូលបត្រកម្ពុជា ត្រូវបានប្តូរឈ្មោះទៅជា និយ័តករមូលបត្រកម្ពុជា អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/00៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។[16] និយ័តករមូលបត្រកម្ពុជា តម្រូវឲ្យអនុវត្តមុខងារទាំងស្រុងរបស់គណៈកម្មការមូលបត្រកម្ពុជា ដែលបានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រប្រកបទៅដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។[17]

### ២.១.២. ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា



រូបភាពទី ២.១៖ ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា

---

[14] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

[15] https://www.serc.gov.kh/khmer/m10.php?pn=1(ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

[16] ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ លេខ នស/រកម/០១២១/00៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ មាត្រា ១៦

[17] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

និយ័តករមូលបត្រកម្ពុជាមានទីតាំងនៅ អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ និយ័តករមូលបត្រកម្ពុជា មានព័ត៌មានសម្រាប់ទំនាក់ទំនងដូចខាងក្រោម៖

- **ទូរស័ព្ទលេខ:** (៨៥៥) ២៣ ៨៨ ៥៦ ១១ / (៨៥៥) ១៦ ៨១៩ ៩៩១ (វិចិត្រ-admin) / (៨៥៥) ០១ ៧៧៦ ៧៨៥ (តី-webmaster)
- **ទូរសារ:** (៨៥៥) ២៣ ៨៨ ៥៦ ២២
- **អ៊ីម៉ែល:** INFO@SERC.GOV.KH ។[18]

## ២.១.៣. ចក្ខុវិស័យ និងបេសកកម្ម

### ក. ចក្ខុវិស័យ

និយ័តករមូលបត្រកម្ពុជា មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។[19]

### ខ. បេសកកម្ម

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងបំពេញនូវបេសកកម្មដូចខាងក្រោម៖[20]

- ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- លើកកម្ពស់ទីផ្សារមូលបត្រឲ្យមានប្រសិទ្ធិភាព និងជំរុញឲ្យមានការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ជ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

[18] https://www.serc.gov.kh/khmer/m19.php?pn=1 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

[19] https://www.serc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

[20] https://www.serc.gov.kh/khmer/m11.php?pn=1 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

### ២.១.៤. គោលដៅ និងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) មានគោលដៅ និងគោលបំណងដូចខាងក្រោមៈ[21]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ រួមទាំងទីផ្សារមូលបត្ររដ្ឋនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា
- បង្កើត និងរក្សាទំនុកចិត្តអ្នកវិនិយោគ ដោយការពារសិទ្ធិរបស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវ
- ជម្រុញការអភិវឌ្ឍន៍ទីផ្សារមូលបត្រ
- ដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- បង្ការ និងដាក់ទណ្ឌកម្មចំពោះបទល្មើសនានាដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

### ២.១.៥. មុខងាររបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជាមានមុខងារដូចខាងក្រោមៈ[22]

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ
- ដាក់ឲ្យអនុវត្តនូវគោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់
- ដើរតួនាទីជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ា ចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណដែលប៉ះពាល់ដល់ប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬអ្នកវិនិយោគ
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បំពេញការងារផ្សេងទៀតដែលមានចែងនៅក្នុងអនុក្រឹត្យ។

[21] https://www.serc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២)

[22] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៧

### ២.១.៦. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា

សមាជិករបស់ ន.ម.ក. មានអាណត្តិ ៥ ឆ្នាំ។ ក្នុងរយៈពេលនៃការបំពេញមុខងាររបស់ខ្លួន សមាជិកអាចត្រូវបានដកហូត ឬផ្លាស់ប្តូរភារកិច្ច។ សមាជិក ន.ម.ក. អាចត្រូវបានតែងតាំងសារជាថ្មីទៀតបាន ទៅតាមសំណើររបស់ប្រធាន ន.ម.ក. នៅពេលផុតអាណត្តិ។[23] និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ រូប (ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) និងសមាជិក ៨ រូប ដែលតែងតាំងដោយអនុក្រឹត្យ ដែលមានដូចខាងក្រោម៖[24]

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
- តំណាងធនាគារជាតិនៃកម្ពុជា ១ រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១ រូប
- តំណាងក្រសួងយុត្តិធម៌ ១ រូប
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
- អគ្គនាយកនៃ ន.ម.ក ១ រូប
- អ្នកជំនាញដែលមានបទពិសោធន៍ក្នុងវិស័យមូលបត្រ ២ រូប ដែលមានស្ថានភាពអព្យាក្រឹត្យ ព្រមទាំងជ្រើសរើស និងស្នើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២.១.៧. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា[25]




រូបភាពទី ២.២ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់និយ័តករមូលបត្រកម្ពុជា

[23]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៥

[24]ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ មាត្រា៦

[25] https://www.serc.gov.kh/khmer/m14.php?pn=1 (ចូលទស្សនាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២)

## ២.២ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ២.២.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ឬអាចហៅខ្លីថា ផ្សារមូលបត្រកម្ពុជា គឺជាផ្សារមូលបត្រទី១ ដំបូងគេបង្អស់ជាប្រវត្តិសាស្ត្ររបស់កម្ពុជា។ នៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសបើកឲ្យដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅខែកញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្ដីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា" ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែមីនា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ដើម្បីបង្កើតផ្សារមូលបត្រ "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" ស្របតាមច្បាប់ស្ដីពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានចុះក្នុងបញ្ជីពាណិជ្ជកម្ម នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១០។ ស្របតាមកិច្ចព្រមព្រៀងក្រុមហ៊ុនចំរុះ (Joint Venture) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន ៥៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ហើយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ កាន់កាប់ភាគហ៊ុនចំនួន ៤៥% នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានទទួលអាជ្ញាបណ្ណជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** ស្របតាមច្បាប់ស្ដីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

ក្រោមដំណើរការជាច្រើនដំណាក់កាល នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ គឺជាថ្ងៃប្រវត្តិសាស្ត្រដ៏សំខាន់មួយនៃវិស័យហិរញ្ញវត្ថុ និងជាមោទនភាពជាតិមួយសម្រាប់កម្ពុជា ដែលនៅទីបំផុត ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange) បានឈានដល់ដំណាក់កាលចុងក្រោយ ដែលត្រូវបានសម្ពោធដាក់ឲ្យដំណើរការ និងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានអនុវត្តការជួញដូរមូលបត្រកម្មសិទ្ធិជាលើកដំបូង។[26]

[26] http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនា ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១)

### ២.២.២. ចក្ខុវិស័យ

វិស័យមូលបត្រ គឺជាផ្នែកមួយក្នុងការធ្វើឲ្យវិស័យហិរញ្ញវត្ថុកាន់តែមានសន្ទុះកើនឡើងជាលំដាប់។ ហេតុនេះ ដើម្បីឲ្យដំណើរការនៃវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា កាន់តែរីកចម្រើនប្រកប ដោយប្រសិទ្ធិភាព និងប្រសិទ្ធិផល ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានកំណត់នូវចក្ខុវិស័យរបស់ខ្លួនយ៉ាងច្បាស់លាស់ក្នុងការជួយគាំទ្រនូវវិស័យហិរញ្ញវត្ថុ កម្ពុជានោះគឺ ដើម្បីកសាងនូវ "**មហាវិថី**" ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

### ២.២.៣. បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ក្រុមហ៊ុនផ្សារមូលបត្រ បានដាក់ចេញនូវបេសកកម្មមួយចំនួនដូចខាង ក្រោម៖

- ដើម្បីសម្រួលក្នុងការកៀងគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយ ដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៏ដឹកនាំ របស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.២.៤. នាមករណ៍ និងផ្លាកសញ្ញារបស់ផ្សារមូលបត្រកម្ពុជា

**ក. នាមករណ៍**

នាមករណ៍ក្រុមហ៊ុនមាននាមជាភាសាខ្មែរថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលហៅកាត់ថា (ផ.ម.ក.) និងជាភាសាអង់គ្លេសថា (Cambodia Securities Exchange) ហៅកាត់ថា (CSX)។[27]

**ខ. ផ្លាកសញ្ញា**

ផ្សារមូលបត្រកម្ពុជា CSX

រូបភាពទី ២.៣ ៖ ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

[27] http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២)

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានអត្ថសញ្ញាណដូចខាងក្រោម៖

- ផ្នែកខាងលើមានសរសេរអក្សរពណ៌ខៀវថា ផ្សារមូលបត្រកម្ពុជា ដែលជាឈ្មោះតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ក្រោមអក្សរផ្នែកខាងស្តាំ មានរូបហង្សពណ៌មាសមួយ ដែលឈរបែរមុខទៅខាងស្តាំ
- ក្រោមអក្សរផ្នែកខាងឆ្វេង មានឈ្មោះរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ជាអក្សរកាត់ភាសាអង់គ្លេស ដែលមានពណ៌ខៀវ (CSX)។

### ២.២.៥.ព័ត៌មានទូទៅនៃការទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

**អាសយដ្ឋាន៖** អាគារ ធ.ម.ក. វិថីព្រះមហាក្សត្រយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

**ទូរស័ព្ទ** ៖ (៨៥៥) ២៣ ៩៥៨ ៨៨៨ / ២៣ ៩៥៨ ៨៨៥

**ទូរសារ៖** (៨៥៥) ២៣ ៩៥៥ ៥៥៨

**គេហទំព័រ៖** www.csx.com.kh

### ២.២.៦. រចនាសម្ព័ន្ធនៃការគ្រប់គ្រង




រូបភាពទី ២.៤ ៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ២.២.៧.ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃផ.ម.ក. រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល (ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ ចំណែកឯអនុប្រធានក្រុមប្រឹក្សាភិបាល គឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ សមាជិកចំនួន ៤ រូបផ្សេងទៀត គឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ ២ រូប ត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ [28]



r Cj Rf[ WQ Rb [illegible] c yW

ប្រធានក្រុមប្រឹក្សាភិបាល រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



Mr. KIM KYEONGHACK

អនុប្រធានក្រុមប្រឹក្សាភិបាល

អគ្គនាយករងនៃផ្សារមូលបត្រកម្ពុជា



ឯកឧត្តម ហុង សុហួរ

សមាជិក

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃផ្សារមូលបត្រកម្ពុជា



ឯកឧត្តម អ៊ូ ចាន់តារា

សមាជិក

អគ្គលេខាធិការនៃធនាគារជាតិនៃកម្ពុជា



ឯកឧត្តម ហ៊ឹម ហ៊ាន

សមាជិក

ទីប្រឹក្សាក្រសួងពាណិជ្ជកម្



Mr. YI BUYEON

សមាជិក



Mr. WE SAE YOUN

សមាជិក

រូបភាពទី ២.៥ ៖ ក្រុមប្រឹក្សារបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

[28] http://www.csx.com.kh/kh/about/director.jsp?MNCD=10303 (ចូលទស្សនា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១)

## ២.៣. តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ

### ២.៣.១.និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា ជានិយ័តករមូលបត្រតែមួយគត់ ដែលគ្រប់គ្រងវិស័យមូលបត្រ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរគរមូលធនពីសាធារណៈជន ឬវិនិយោគិនមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគនៅកម្ពុជា។ បេសកកម្មរបស់ **ន.ម.ក.** រួមមាន៖ ១.បង្កើត និងរក្សាឲ្យមានទំនុកចិត្តពីអ្នកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ ២.លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ ៣.ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ៤.ជំរុញឲ្យមានការធ្វើវិនិយោគទុនពីបរទេស ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[29]

### ២.៣.២. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ត្រូវបានបង្កើតឡើង ដើម្បីដាក់ឲ្យដំណើរការប្រព័ន្ធជួញដូរមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រព័ន្ធរក្សាទុកមូលបត្រ ស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ប្រកាសស្ដីពីការផ្ដល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ **ផ.ម.ក.** ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសការជំរុញ និងការលើកទឹកចិត្តដល់វិនិយោគិន និងក្រុមហ៊ុនក្នុងស្រុក តាមរយៈការបង្កើតឲ្យមានសន្ទនីយភាពទីផ្សារ និងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។

### ២.៣.៣. ក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការទិញលក់មូលបត្រ ក្នុងទីផ្សារមូលបត្រកម្ពុជា តាមរយៈការដើរតួជាអន្តរការី។ ជាទូទៅក្រុមហ៊ុននេះដើរតួនាទីជាអន្តរការី ឬជាអ្នកសម្របសម្រួលប្រតិបត្តិការមូលបត្រនៅក្នុងទីផ្សារ។ ក្រុមហ៊ុនមូលបត្រ គឺជាតួអង្គសំខាន់មួយនៅក្នុងដំណើរការទីផ្សារ ព្រោះក្រុមហ៊ុនមូលបត្រត្រូវបាន

[29] http://www.csx.com.kh (ចូលទស្សនា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១)

ចាត់ទុកជាអ្នកជំនាញក្នុងវិស័យមូលបត្រ ដែលមានតួនាទីយ៉ាងសំខាន់ ដើម្បីជួយក្រុមហ៊ុនបោះផ្សាយក្នុងដំណើរការលក់មូលបត្រ នៅលើទីផ្សារទទួលបានជោគជ័យ។ លើសពីនេះទៀត ក្រុមហ៊ុនមូលបត្រក៏មានតួនាទីជួយដល់វិនិយោគិនមូលបត្រនៅក្នុងដំណើរការជួញដូរមូលបត្រ (ការទិញ លក់មូលបត្រ) នៅក្នុងទីផ្សារផងដែរ ព្រោះវិនិយោគិនមិនអាចធ្វើការជួញដូរមូលបត្រដោយផ្ទាល់ នៅលើទីផ្សារមូលបត្រដោយខ្លួនឯងបាននោះទេ។ រាល់ការជួញដូរមូលបត្ររបស់វិនិយោគិន ត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលជាឈ្មួញជើងសារ។ ជារួមក្រុមហ៊ុនមូលបត្រត្រូវបានចាត់ទុកជាអន្តរការីមូលបត្រដែលមិនអាចខ្វះបាននៅក្នុងទីផ្សារ ទាំងក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ និងក្នុងដំណើរនៃការជួញដូរមូលបត្ររបស់វិនិយោគិន។ បច្ចុប្បន្ននៅកម្ពុជាមានក្រុមហ៊ុនមូលបត្រចំនួន ១២(ដប់ពីរ) ដែលមានសកម្មភាពអាជីវកម្ម ដូចជា៖[30]

### ក. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ មានតួនាទីក្នុងការទិញយកមូលបត្រ ដែលនៅសល់ទាំងអស់ ឬមួយផ្នែកទៅតាមលក្ខខណ្ឌនៃកិច្ចសន្យារវាងក្រុមហ៊ុនធានាទិញមូលបត្រ និងក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្នុងករណីដែលមូលបត្រដែលបោះផ្សាយនោះមិនបានលក់អស់ក្នុងដំណាក់កាលបរិវិសកម្ម។ ក្នុងការបោះផ្សាយជាសាធារណៈលើកដំបូង (Initial Public Offering/IPO) ក្រុមហ៊ុនធានាទិញមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងការទិញយកមូលបត្រដែលនៅសល់ និងផ្តល់ជាការប្រឹក្សាដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ការប្រឹក្សាក្នុងការបោះផ្សាយជាសាធារណៈលើកដំបូងនេះមានដូចជា ការកំណត់ទំហំទឹកប្រាក់ ការកំណត់ថ្លៃមូលបត្រ ការកំណត់ចំនួនមូលបត្រ និងការកំណត់ពេលវេលាក្នុងការបោះផ្សាយ។ ក្រុមហ៊ុនដែលធានាទិញមូលបត្រមានដូចជា៖

១. យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី / Yuanta Securities (Cambodia) Plc.

២. អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យួរីធី ម.ក / RHB Indochina Securities PLC.

៣. កាណា ស៊ីឃ្យួរីធី អិលធីឌី / Cana Securities Ltd.

៤. កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី / Campu Securities Plc.

៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី / SBI Royal Securities Plc.

៦. ភ្នំពេញ ស៊ីឃ្យួរីធី ភីអិលស៊ី / Phnom Penh Securities Plc.

៧. ខេមបូឌា ស៊ីឃ្យួរីធី ម.ក / Cambodia Securities Plc.

[30] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ លេខ ០០៩ គ.ម.ក ចុះថ្ងៃទី១៩ វិច្ឆកា ២០០៩

**ឃ. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ**

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរមូលបត្រ (ទិញ-លក់) ក្នុងទីផ្សារមូលបត្រ។ ដូចនេះ តម្រូវឲ្យក្រុមហ៊ុនពាណិជ្ជករមូលបត្រ មានគណនីផ្ទាល់ខ្លួនសម្រាប់ធ្វើការជួញដូរមូលបត្រ។ ក្នុងការជួញដូរនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចទទួលបានផលចំណេញពីមូលបត្រ ហើយក៏ត្រូវប្រឈមមុខនឹងហានិភ័យក្នុង ការជួញដូរមូលបត្រផងដែរ។ ក្នុងនាមជាក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចមានសិទ្ធិធ្វើអាជីវកម្មជួញដូរមូលបត្រ អាជីវកម្មឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ គឺ ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី / Golden Fortune (Cambodia) Securities Plc.

**ខ. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ**

ក្រុមហ៊ុនមូលបត្រដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ មានតួនាទីជាអ្នកទទួលទិញ ឬលក់មូលបត្រ តាមបញ្ជារបស់អតិថិជនរបស់ខ្លួន។[31] ក្នុងន័យនេះ សាធារណៈជនមិនអាចធ្វើការទិញលក់ មូលបត្រដោយផ្ទាល់ នៅលើទីផ្សារមូលបត្របានទេ ប្រតិបត្តិការទាមទារឲ្យឆ្លងកាត់អន្តរការីដែលជាក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ទទួលបានកម្រៃជើងសារពីការទទួលបញ្ជាទិញ ឬលក់ពីអតិថិជនរបស់ខ្លួន។ ក្រុមហ៊ុនទាំងនេះរួមមានដូចជា ៖

១. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី / ACLEDA Securities Plc.

២. ខេប ស៊ីឃ្យូរីធី លីមីធីត / CAB Securities Limited.

៣. ខេមបូឌាវៀតណាម ស៊ីឃ្យូរីធី ឯ.ក / Cambodia-Vietnam Securities Co., Ltd.

៤. ភីភី លីង ស៊ីឃ្យូរីធី ឯ.ក / PP Link Securities Co., Ltd

### ២.៣.៤. ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធិ

#### ២.៣.៤.១. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ( PWSA )

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) ត្រូវបានបង្កើតឡើង ជាគ្រឹះស្ថានសាធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ **រ.ទ.ស.ភ.** បានចុះបញ្ជីជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ចំនួន ១៣.០៤៥.៩៧៥ ភាគហ៊ុន ដែលស្មើនឹង ១៥% នៃចំនួនភាគហ៊ុនធម្មតាសរុប។[32]

*រូបភាព ២.៦៖ ស្លាកសញ្ញា PWSA*

[31] http://www.secc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនា ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២)

[32] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004 (ចូលទស្សនា ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២២)

| **តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង** | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | រដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ១៣.០៤៥.៩៧៥ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ដល់ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១២ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ពី៤.០៥០រៀល ដល់៦.៣៥០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១២ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៦.៣០០រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | គុងយ៉ាង ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង ២.១. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPWSA*

### ២.៣.៤.២. កំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP)

កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) គឺជាប្រតិបត្តិករមួយ ក្នុងចំណោមប្រតិបត្តិករកំពង់ផែកុងតឺន័រអន្តរជាតិ២នៅកម្ពុជា ហើយក៏ជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេបំផុត និងជាអាជ្ញាធរគ្រប់គ្រងផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ មណ្ឌលអាជីវកម្មផែមានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំទៅដល់ព្រំប្រទល់ កម្ពុជា-វៀតណាម នៅឯក្អមសំណ។ នៅឆ្នាំ២០១៥ ក.ស.ភ. ទទួលបានសិទ្ធផ្តាច់មុខជាប្រតិបត្តិករកំពង់ផែនៅក្នុងមណ្ឌលអាជីវកម្មផែ។ ក.ស.ភ. មានចំណតផែចម្បងៗចំនួន៤ គឺ៖ ទី១. ចំណតផែកុងតឺន័រ LM១៧,ទី២.ចំណតផែពហុបំណង TS៣, ទី៣. ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១,ទី៤.ចំណតផែទន្លេបិទ UM២។[33]

*រូបភាព ២.៧៖ ស្លាកសញ្ញា PPAP*

[33] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004_(ចូលទស្សនា ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តភ្នំពេញ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ៤.១៣៦.៨៧៣ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៩ ដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៤.៤០៥ រៀល ដល់ ៦.៣២០ រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី១២ ដល់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.១២០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | យាន់តា ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី |

*តារាង ២.២. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPAP*

### ២.៣.៤.៣. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (GTI)

*រូបភាព ២.៨៖ ស្លាកសញ្ញា GTI*

ក្រុមហ៊ុន ហ្គ្រេនធ្វីនអ៊ីនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី គឺជាក្រុមហ៊ុនផលិតសម្លៀកបំពាក់ ដែលបានបង្កើតឡើងក្នុងឆ្នាំ២០០៧។ នៅឆ្នាំ២០០៨ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយ ក្នុងចំណោមរោងចក្រកាត់ដេរធំៗដំបូងបង្អស់ដែលបានធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០។ ក្រុមហ៊ុន ហ្គ្រេនធ្វីន គឺជារោងចក្រម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុនហ្គ្រេនធ្វីន រួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗ ដូចជាម៉ាក Adidas, Reebok, Taylor Made, Salomon, New Balance (NB), Kohls, Nautica, North Face,។ល។[34]

[34] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004_(ចូលទស្សនា ថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនធម្មតា |
| **ភាគហ៊ុនបោះផ្សាយ** | ៨.000.000 |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១៤ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៧.៤00 រៀល ដល់ ១៤.000 រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី២ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៩.៦៤0 រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី |

*តារាង ២.៣. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងGTI*

### ២.៣.៤.៤. ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

ក្រុមហ៊ុន ភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងជាប្រតិបត្តិករនៃតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ("PPSEZ") និង ប៉ោយប៉ែត ភីភី អេសអ៊ីហ្សិត ("Poipet PPSEZ")។ នាថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស ដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ។ បច្ចុប្បន្ននេះ តំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងធ្វើប្រតិបត្តិការ នៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាដែលមានអាជីវកម្មចម្បងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់ និង/ឬ ជួល។[35]

*រូបភាព ២.៩៖ ស្លាកសញ្ញា PPSP*

[35] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000 (ចូលទស្សនា ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | ភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (ភីភីអេសភី) |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ១១.៥៧៥.000 |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី១៨ ដល់ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ២.៨00រៀល ដល់ ៤.000រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី៩ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ២.៨៦០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីយូរីធី កម្ពុ ស៊ីយូរីធី និងកាណា ស៊ីយូរីធី |

*តារាង ២.៤. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPPSP*

**២.៣.៤.៥. កំពង់ផែស្វយ័តក្រុងព្រះសីហនុ**(PAS)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ជាក្រុមហ៊ុនរដ្ឋដែលបានបង្កើតឡើង ដើម្បីធ្វើអាជីវកម្មសេវាកម្មមូលដ្ឋានលើការងារះកណ្តធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភារដល់នាវា លើកដាក់ ផ្ទេរផ្ទុកទំនិញ ស្តុកទំនិញនៅឃ្លាំង និងទីលានព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន ក.ស.ស ក៏កំពុងផ្តល់សេវាកម្មផ្សេងទៀត៖ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេស ដូចជាជួលឃ្លាំង និងថែរក្សាទំនិញ លើកដាក់ និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ **ក.ស.ស** ជាកំពង់ផែអន្តរជាតិសមុទ្រទឹកជ្រៅតែមួយគត់នៅកម្ពុជា ដែលកំពុងធ្វើអាជីវកម្មលើផ្ទៃដីទំហំប្រមាណ ១២៥ ហិចតា នៅខេត្តព្រះសីហនុ ហើយត្រូវបានតភ្ជាប់ដោយបណ្តាញដឹកជញ្ជូនចំរុះ រួមមាន បណ្តាញផ្លូវគោក បណ្តាញផ្លូវរថភ្លើង និងបណ្តាញផ្លូវអាកាស។[36]

*រូបភាព ២.១០៖ ស្លាកសញ្ញា PAS*

[36]http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009 (ចូលទស្សនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១)

| តារាងសង្ខេបលទ្ធនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| **ឈ្មោះក្រុមហ៊ុន** | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| **ប្រភេទភាគហ៊ុន** | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| **ភាគហ៊ុនបោះផ្សាយ** | ២១.៤៤២.៩៩២ |
| **កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង** | ថ្ងៃទី២៥ មេសា ដល់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ ២០១៧ |
| **ចន្លោះថ្លៃក្នុងការធ្វើប៊ុកបៀលឌីង** | ៣.៥២០រៀល ដល់ ៥.១៨០រៀល |
| **កាលបរិច្ឆេទធ្វើបរិវិសកម្ម** | ថ្ងៃទី១៧ ដល់ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ |
| **តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង** | ៥.០៤០ រៀល |
| **ក្រុមហ៊ុនធានាទិញមូលបត្រ** | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី |

*តារាង ២.៥. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPAS*

#### ២.៣.៤.៦. ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC)

*រូបភាព ២.១១៖ ស្លាកសញ្ញា ABC*

ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៣ ដែលស្ថិតក្រោមគម្រោងអង្គការពលកម្មអន្តរជាតិក្នុងយុគសម័យក្រោយសង្គ្រាមនៅកម្ពុជា។ បច្ចុប្បន្ន ធនាគារអេស៊ីលីដា មានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ ហើយ គឺជាធនាគារឈានមុខ និងធំជាងគេផ្នែកឥណទានបំណុល និងបណ្តាញចែកចាយគ្រប់ខេត្តក្រុង នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ធនាគារអេស៊ីលីដា ក៏ជាធនាគារដំបូងដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួននៅក្រៅប្រទេសដែលរួមមានប្រទេសឡាវ និងមីយ៉ាន់ម៉ា ។ អតិថិជនរបស់ធនាគារអេស៊ីលីដា រួមមានរូបវន្តបុគ្គល អាជីវកម្មតូច និងមធ្យម និងនីតិបុគ្គល។ ធនាគារ អេស៊ីលីដា ទទួលប្រាក់បញ្ញើពីអតិថិជន និងផ្តល់ដល់អតិថិជននូវផលិតផល ឥណទានច្រើនប្រភេទ ព្រមទាំងសេវាហិរញ្ញវត្ថុផ្សេងៗទៀត ដូចជាការផ្ទេរប្រាក់ ហិរញ្ញប្បទានពាណិជ្ជកម្ម ភតិសន្យាហិរញ្ញវត្ថុ សេវាណែនាំពីផលិតផលធានារ៉ាប់រង និងសេវាធនាគារអេឡិចត្រូនិច។[37]

[37] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003 (ចូលទស្សនា ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះ ក្រុមហ៊ុន | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.៣៨៤.៨៧៥ |
| កាលបរិច្ឆាទធ្វើប៊ុកបៀលឌីង | ថ្ងៃទី ០៣ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២០ |
| ចន្លោះថ្ងៃក្នុងការធ្វើប៊ុកបៀលឌីង | ១៥.០០០ រៀល ដល់ ១៧.០០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី ២៨ ខែមីនា ដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ១៦.២០០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |
| *តារាង ២.៦. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងABC* | |

### ២.៣.៤.៧. ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក.(PEPC)

*រូបភាព ២.១២៖ ស្លាកសញ្ញា PEPC*

ផេសថិក (ខេមបូឌា) បានចុះបញ្ជីនៅឆ្នាំ ២០១០ ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី ដែលផ្តល់សេវាសំខាន់លើការផ្តល់ជូនវិស្វកម្មប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសសម្រាប់៖ ការគូសប្លង់ លទ្ធកម្ម ការសាងសង់ ការដំឡើង និងការដាក់ប្រើប្រាស់នូវអនុស្ថានីយ៍មានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដី សម្រាប់ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី និងការជួញដូរបង្គុំ និងបរិក្ខារប្រព័ន្ធថាមពល ដែលជាកម្មសិទ្ធិនិងមិនមែនកម្មសិទ្ធិ។ ផេសថិក (ខេមបូឌា) មានក្រុមហ៊ុនបុត្រសម្ព័ន្ធ PESTECH (Myanmar) បង្កើតឡើងនៅឆ្នាំ ២០១៧ និងផ្តត់ផ្គង់វិស្វកម្មប្រព័ន្ធថាមពលចម្រុះ និងដំណោះស្រាយប្រព័ន្ធបច្ចេកទេសចម្រុះ សម្រាប់រចនាលទ្ធកម្ម ការសាងសង់ និងសេវាពាក់ព័ន្ធនឹងឧស្សាហកម្មអគ្គិសនី។[39]

[39] http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009 (ចូលទស្សនាថ្ងៃ១០ ខែកក្កដា ឆ្នាំ២០២២)

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង | |
|---|---|
| ឈ្មោះ ក្រុមហ៊ុន | ផេសថិក (ខេមបូឌា) ម.ក |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធិបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៣.៩៤៥.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ដល់ថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៣.១២០ រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អ អេច ប៊ីស៊ីឃ្យូធី (ខេមបូឌា) ម.ក |
| *តារាង ២.៧. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងPEPC* | |

### ២.៣.៤.៨ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក. (DBD)

ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ីនជីនារីង ម.ក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៥ ជាក្រុមហ៊ុនពហុមុខងារផ្នែកវិស្វកម្ម និងសំណង់ដែលមានបទពិសោធជាច្រើនឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា។ ឌីប៊ីឌីផ្តល់សេវាកម្មដូចជា សេវាកម្មគូរប្លង់ សាងសង់ តំឡើង និងថែទាំ ដែលសេវាកម្មទាំងនេះធ្វើឲ្យក្រុមហ៊ុនទទួលបានកេរ្តិ៍ឈ្មោះលំដាប់ជាតិ និងអន្តរជាតិ។

*រូបភាពទី ២.១៣-ស្លាកសញ្ញាឌី ប៊ី ឌី អ៊ីនជីនារីង*

ឌីប៊ីឌី ទទួលបានកំណត់ត្រាជាទីគាប់ចិត្តក្នុងការផ្តល់សេវាកម្ម និងផ្គត់ផ្គង់ផលិតផលប្រកបដោយគុណភាព ដែលស្តែងបញ្ជាក់តាមរយៈការពេញចិត្ត និងការកោតសរសើរពីសំណាក់អតិថិជនរបស់ខ្លួន។ ក្រៅពីកេរ្តិ៍ឈ្មោះក្នុងផ្នែកសំណង់ ការបំពាក់ឧបករណ៍ និងសេវាកម្មថែទាំ ដែលបានឈានមុខគេក្នុងការផ្គត់ផ្គង់ផលិតផលម៉ាកល្បីៗជាច្រើនសម្រាប់គម្រោងនានាកន្លងមក ដែលរួមមានផលិតផលម៉ាក Scheneider ម៉ាក Franklin France ម៉ាក Daikin ម៉ាក Ginde ម៉ាក LG ម៉ាក Mitsubishi ម៉ាក Kumwell ម៉ាកEVT ម៉ាក Tsurumi Pump និងខ្សែកាបម៉ាក Yazaki។[40]

[40] https://dbdengineering.com/ (ចូលទស្សនាថ្ងៃ១០ ខែកក្កដា ឆ្នាំ២០២២)

### ២.៣.៥. វិនិយោគិន

វិនិយោគិនសំដៅដល់សាធារណជនជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានលេខអត្តសញ្ញាណវិនិយោគិនពីនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) មានសិទ្ធិទិញ ឬលក់ មូលបត្រដែលបានបោះផ្សាយ។ វិនិយោគិន រួមមានវិនិយោគិនទូទៅ និងវិនិយោគិនគុណវុឌ្ឍិ។ វិនិយោគិនគុណវុឌ្ឍិ ជាវិនិយោគិនដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៣ នៃប្រកាសស្តីពីវិនិយោគិនគុណវុឌ្ឍិក្នុងវិស័យមូលបត្រ។

### ២.៣.៦. តួអង្គចូលរួមដទៃទៀត

ក្រៅពីតួអង្គសំខាន់ដែលបានរៀបរាប់ខាងលើ វិស័យមូលបត្រក៏មានតួអង្គចូលរួមដទៃទៀតដែលមានដូចជា ៖[41]

#### ក. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ជាភ្នាក់ងារដែលបានទទួលស្គាល់ពី **ន.ម.ក** ដែលគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ព័ន្ធនឹងមូលបត្រមានចំនួន ៦ គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ វិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
- ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក
- ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់

#### ខ. ភ្នាក់ងារបញ្ជិកាមូលបត្រ

ជាភ្នាក់ងារដែលទទួលស្គាល់ពី ន.ម.ក. ដែលគ្រប់គ្រងនូវដំណើរការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រកត់ត្រាបញ្ជីកម្មសិទ្ធករមូលបត្រ និងធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ។ ភ្នាក់ងារបញ្ជិកាមូលបត្រ មានចំនួន៣ គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រស៊ីឃ្យូរីធី ស៊ើវីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

[41] http://www.secc.gov.kh/khmer/m59.php?pn=6 (ចូលទស្សនាថ្ងៃ១០ ខែកក្កដា ឆ្នាំ២០២២)

**គ. ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ**

ជាភ្នាក់ងារដែលទទួលស្គាល់ពី **ន.ម.ក.** ដែលគ្រប់គ្រងបញ្ជីកម្មសិទ្ធករមូលបត្រឲ្យមានសង្គតិភាព ការផ្លាស់ប្តូរកម្មសិទ្ធករ ការធ្វើរបាយការណ៍ ស្ថិតិ និងការរៀបចំពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធករមូលបត្រ ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ និងការបង់ការប្រាក់ជាដើម។ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រមានចំនួន ៣គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រស៊ីឃ្យូរីធី ស៊ីវីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

**ឃ. ភ្នាក់ងារទូទាត់**

ជាភ្នាក់ងារដែលទទួលស្គាល់ពី **ន.ម.ក.** ដែលមានតួនាទីជាអ្នកគណនាភាគលាភ ការប្រាក់ ប្រាក់ដើមទូទាត់ជូនកម្មសិទ្ធករ ឬភាគីដែលមានការពាក់ព័ន្ធក្នុងនាមជាក្រុមហ៊ុនបោះផ្សាយ និងបញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ដល់កម្មសិទ្ធករមូលបត្រ និងទៅក្រុមហ៊ុនបោះផ្សាយ និង **ន.ម.ក.** តាមការចាំបាច់។ ភ្នាក់ងារទូទាត់មានចំនួន ៣គឺ៖

- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រស៊ីឃ្យូរីធី ស៊ីវីស ភីអិលស៊ី
- ក្រុមហ៊ុន ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី

**ង. ក្រុមហ៊ុន និងការិយាល័យមេធាវីផ្តល់សេវាផ្នែកច្បាប់នៅក្នុងវិស័យមូលបត្រ**

ជាក្រុមហ៊ុនដែលផ្តល់សេវាផ្នែកច្បាប់ ដែលបានទទួលស្គាល់ដោយនិយ័តករមូលបត្រកម្ពុជា។ ក្រុមហ៊ុនទាំងនោះរួមមានដូចជា៖

- ក្រុមហ៊ុនមេធាវី អេច ប៊ី អេស
- ការិយាល័យមេធាវី អ អេស ធី សុខអេន ហេង
- ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការី
- ការិយាល័យមេធាវី សិទ្ធិសក្តិ
- ការិយាល័យមេធាវីអាស៊ី កម្ពុជា
- ការិយាល័យមេធាវី ប៊ុន និងសហការី
- ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី
- ការិយាល័យមេធាវី ស៊ី អេស អែល និងសហភាគា
- ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន

- ការិយាល័យមេធាវី ស៊ិន & ផាតនើ
- ក្រុមមេធាវី កម្ពុជាបាយ៉េន (ស៊ី ប៊ី អិល)
- ក្រុមមេធាវី មេគង្គ
- ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ
- ក្រុមមេធាវី ស៊ី អេស ភី និង សហការី
- ការិយាល័យមេធាវី សិង្ហាល័យ

**ច. ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ**

ជាក្រុមហ៊ុនផ្តល់សេវាសវនកម្ម ដែលទទួលស្គាល់ពី **ន.ម.ក.** ដើម្បីធ្វើសវនកម្មនូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តតាមស្តង់ដារដែលបានកំណត់។ ក្រុមហ៊ុនផ្តល់សេវាម្មនៅក្នុងវិស័យមូលបត្រមានចំនួនប្រាំដូចខាងក្រោម៖

- ក្រុមហ៊ុន ប្រាយវ៉តេជ័រ ហាវខូភើស៍ (ខាមបូឌា)
- ក្រុមហ៊ុន ខេ ភី អឹម ជី ខេមបូឌា
- ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត
- ក្រុមហ៊ុន អឺនស្ទ័ អ៊ែន យ៉ាំង (ខេមបូឌា)
- ក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
- ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក
- ក្រុមហ៊ុន ឌីឡ័យធ៏ (ខេមបូឌា) ខូ អិលធីឌី
- ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក

**ឆ. ក្រុមហ៊ុនផ្តល់សេវាកម្មវាយតម្លៃនៅក្នុងវិស័យមូលបត្រ**

ជាក្រុមហ៊ុនដែលទទួលស្គាល់ដោយ **ន.ម.ក** ដើម្បីវាយតម្លៃលើទ្រព្យសកម្ម ដោយអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។ បញ្ជីឈ្មោះក្រុមហ៊ុនដែលផ្តល់សេវាកម្មវាយតម្លៃនៅក្នុងវិស័យមូលបត្រមានដូចជា៖

- ក្រុមហ៊ុន វីត្រាល់ អឺព្រេហ្សល
- ក្រុមហ៊ុន ស៊ីងឈ័រ ប្រូធឺធី ឯ.ក
- ក្រុមហ៊ុន ណាយ ហ្វ្រែង (ខេមបូឌា)ក្រុមហ៊ុ

# ជំពូកទី៣
# ដំណើរការបោះផ្សាយ
# និងជួញដូរមូលបត្រកម្មសិទ្ធិ
# នៅកម្ពុជា

# ជំពូកទី៣

# ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា

## ៣.១. ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដំបូង

### ៣.១.១. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។[42]

### ៣.១.២. លក្ខខណ្ឌតម្រូវក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ

ទីផ្សារមូលបត្រនៅកម្ពុជាបែងចែកជា២គឺ ទីផ្សារគោល និងទីផ្សារកំណើន។ ទីផ្សារគោល គឺជាផ្សារដំបូងបង្អស់ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការសម្រាប់ការចុះបញ្ជី របស់ក្រុមហ៊ុនចុះបញ្ជីសក្ដានុពល ដែលមានស្តង់ដារ និងទំហំធំ។[43] ចំណែកឯទីផ្សារកំណើន គឺជាទីផ្សារថ្មីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ត្រូវបានផ្ដួចផ្ដើមឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្ថែមនូវជម្រើសហិរញ្ញប្បទានមួយទៀត សម្រាប់ក្រុមហ៊ុនអាជីវកម្មទាំងនោះដែលមានផលរបរសរុបប្រចាំឆ្នាំលើសពី ១០ពាន់លានដុល្លារអាមេរិក និងបង្កើតការងារចំនួន ១,៣ លានផងដែរ។[44]

ដើម្បីធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងចុះបញ្ជីលក់មូលបត្រនៅទីផ្សារមូលបត្រ ក្រុមហ៊ុនត្រូវគោរពតាមលក្ខខណ្ឌដូចជាៈ[45]

**តារាង ៣.១៖ លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ**

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ១- អភិបាលកិច្ចសាជីវកម្ម | |
| ២- សកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច | |

[42] ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ប្រការ ២

[43] http://csx.com.kh/kh/product/mainboard.jsp?MNCD=30102 ((ចូលទស្សនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២)

[44] http://csx.com.kh/kh/product/growthboard.jsp?MNCD=30103 (ចូលទស្សនាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២)

[45] និយ័តករមូលបត្រកម្ពុជា មគ្គុទេសក៍ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧ ទំព័រទី ១០-១១

| | |
|---|---|
| ៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរយៈពេល ២ឆ្នាំចុងក្រោយ និងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា (ប្រសិនមាន) | ៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរយៈពេល ១ឆ្នាំចុងក្រោយ និងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា (ប្រសិនមាន) |
| ៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ | |
| ៥- ត្រូវមានឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ ន.ម.ក | |

**តារាង ៣.២៖ លក្ខខណ្ឌតម្រូវសម្រាប់ចុះបញ្ជីលក់មូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

| លក្ខខណ្ឌតម្រូវ | ទីផ្សារគោល | ទីផ្សារកំណើន |
|---|---|---|
| មូលធនភាគហ៊ុនិក | យ៉ាងតិច ៣០ពាន់លានរៀល | យ៉ាងតិច ២ពាន់លានរៀល |
| ចំណេញសុទ្ធ | យ៉ាងតិច២ពាន់លានរៀលនៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និង៣ពាន់លានរៀលសម្រាប់រយៈពេល២ឆ្នាំចុងក្រោយ | ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬមានលំហូរសាច់ប្រាក់ពីប្រតិបត្តិការអាជីវកម្មវិជ្ជមាន ជាមួយនឹងអត្រាប្រាក់ចំណេញដុលយ៉ាងតិច១០% |
| ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី១០ភាគហ៊ុនឡើងទៅ | ត្រូវមានចំនួនយ៉ាងតិច ២០០នាក់ | ត្រូវមានចំនួនយ៉ាងតិច ១០០នាក់ |
| ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% | ត្រូវមានចំនួនសរុបយ៉ាងតិច ៧% នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប | ត្រូវមានចំនួនសរុបយ៉ាងតិច ១០%នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប |
| របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម | ២ឆ្នាំចុងក្រោយ | ១ឆ្នាំចុងក្រោយ |
| មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះផ្សាយច្រើនជាងគេក្នុងរយៈពេល ១ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ | | |
| មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើរនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពីន.ម.ក | | |

### ៣.១.៣. យន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ

ការធ្វើហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈជាមធ្យោបាយមួយ ដែលអនុញ្ញាតឲ្យក្រុមហ៊ុនសំដៅធានាដល់និរន្តរភាពអាជីវកម្មរបស់ខ្លួន។ ដើម្បីឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈមានភាពរលូន ក្រុមហ៊ុនបោះផ្សាយ ក៏ដូចជាបុគ្គលពាក់ព័ន្ធគប្បីត្រូវស្វែងយល់ពីដំណើរការនេះឲ្យបានច្បាស់លាស់។ ខាងក្រោមជាយន្តការនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈដែលក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តតាម៖

**១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រជាសាធារណៈជូន ន.ម.ក.៖**

នៅក្នុងលិខិតសម្តែងឆន្ទៈ ក្រុមហ៊ុនត្រូវបង្ហាញឲ្យច្បាស់ពីគោលបំណងនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ គម្រោងពេលរំពឹងទុក និងក្រុមការងារបោះផ្សាយលក់មូលបត្រដែលរំពឹងទុក (ក្រុមការងារ IPO)។

**២. ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ៖**

ក្រុមហ៊ុនធានាទិញជាដៃគូមិនអាចខ្វះបាន របស់ក្រុមហ៊ុនបោះផ្សាយ ក្នុងការជួយសម្របសម្រួល ឲ្យដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងទទួលបានជោគជ័យ។ ក្រុមហ៊ុនបោះផ្សាយអាចស្វែងរកបញ្ជីឈ្មោះក្រុមហ៊ុនធានាទិញបានដែលមាននៅលើគេហទំព័ររបស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ។

**៣. ការបង្កើតក្រុមការងារ IPO៖**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗ ពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជា ក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (ប្រសិនមាន) ជាដើម ដែលទទួលស្គាល់ពី ន.ម.ក. ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រជាសាធារណៈស្របតាមបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយ លើការជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ (ប្រសិនមាន)។

**៤. ត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់៖**

ក្រុមហ៊ុនបោះផ្សាយមូលបត្រចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារ IPO។

**៥. ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)៖**

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ផ.ម.ក. ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពី ផ.ម.ក. ។

**៦. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក.៖**

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈមក ន.ម.ក.។ ន.ម.ក. ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័ត៌មាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយមូលបត្រ។

**៧. ការកំណត់ថ្លៃលក់មូលបត្រ៖**

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍ លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រ ពោលគឺការស្ទាបស្ទង់ថ្លៃលក់មូលបត្រជាមួយវិនិយោគិនសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

**៨. ការស្នើសុំបញ្ជាក់ការដាក់ថ្លៃមូលបត្រពី ផ.ម.ក.៖**

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំសំណើសុំការបញ្ជាក់ការដាក់ថ្លៃមូលបត្រពី ផ.ម.ក.។ ផ.ម.ក. ត្រូវបញ្ជាក់ថ្លៃលក់មូលបត្រអាចដាក់លក់នៅទីផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ។

**៩. ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងការទទួលបាននូវការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក.៖**

ក្រោយពីបញ្ចប់ការកំណត់ថ្លៃលក់មូលបត្ររួចហើយ ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់ថ្លៃមូលបត្រពីផ.ម.ក. រួចដាក់ជូន ន.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

**១០. ការធ្វើបរិវិសកម្មមូលបត្រ៖**

ការធ្វើបរិវិសកម្មមូលបត្រ សំដៅដល់ដំណើរការនៃការទិញមូលបត្រ ទៅតាមចំនួនដែលវិនិយោគិនបានព្រមព្រៀង ឬលើសពីចំនួនដែលបានព្រមព្រៀងក្នុងដំណាក់កាលប៊ុកបៀលឌីង។ ក្រោយទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី ន.ម.ក. ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ។

**១១. ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ៖**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន ន.ម.ក.។

**១២. ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា៖**

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីលក់មូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនមូលបត្រនឹងជួយក្រុមហ៊ុនបោះផ្សាយនូវរាល់ដំណាក់កាលទាំងអស់នៃដំណើរការ IPO នេះ។

### ៣.១.៤. ការចំណាយក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

ក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ បុគ្គលបោះផ្សាយត្រូវចំណាយលើថ្លៃសេវាដូចខាងក្រោម៖[46]

១. ថ្លៃសេវាលើក្រុមការងារ IPO ដែលរួមមាន ថ្លៃសេវាលើក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម មេធាវី ក្រុមហ៊ុនវាយតម្លៃ។

២. ថ្លៃសេវាលើការដាក់ពាក្យស្នើសុំ

ក- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក.

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ១២.០០០.០០០ រៀល | ៦.០០០.០០០ រៀល |

**តារាង ៣.៣៖ ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅ ន.ម.ក.**

ខ- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក.

| សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារគោល | សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីនៅទីផ្សារកំណើន |
|---|---|
| ៤.០០០.០០០ រៀល | ២.០០០.០០០ រៀល |

**តារាង ៣.៤៖ ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ ផ.ម.ក.**

[46] និយ័តករមូលបត្រកម្ពុជា មគ្គុទេសក៏ស្តីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧ ទំព័រទី ១៩-២១

គ- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.

**សម្រាប់ទីផ្សារគោល៖** ផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្ងៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ០៛ ដល់ ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ១២.០០០.០០០.០០១៛ ដល់ ៤០.០០០.០០០.០០០៛ | 0,០៣០% |
| ៤០.០០០.០០០.០០១៛ ដល់ ២០០.០០០.០០០.០០០៛ | 0,០២៥% |
| ២០០.០០០.០០០.០០១៛ ដល់ ៤០០.០០០.០០០.០០០៛ | 0,០១៥% |
| លើសពី ៤០០.០០០.០០០.០០០៛ | 0,០១០% |

**តារាង ៣.៥៖ ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.**

**សម្រាប់ទីផ្សារកំណើន៖** ៤.០០០.០០០ រៀល ឬ០,០២៥% នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្ងៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

ឃ- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ

**សម្រាប់ទីផ្សារគោល៖** ផ្អែកលើមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ០៛ ដល់ ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ១២.០០០.០០០.០០១៛ ដល់ ៤០.០០០.០០០.០០០៛ | 0,០២០% |
| ៤០.០០០.០០០.០០១៛ ដល់ ២០០.០០០.០០០.០០០៛ | 0,០១៥% |
| លើសពី ២០០.០០០.០០០.០០០៛ | 0,០០៥% |

**តារាង ៣.៦៖ ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

**សម្រាប់ទីផ្សារកំណើន៖** ៤.០០០.០០០ រៀល ឬ០,០១៥% នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាង។

### ៣.១.៥. យន្តការទីផ្សារដំបូង




*រូបភាព ៣.១៖ យន្តការទីផ្សារដំបូង*

ទីផ្សារដំបូង គឺជាទីផ្សារសម្រាប់ការជួញដូរមូលបត្ររវាងវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនអាចកៀរគរមូលធន ឬទទួលបានហិរញ្ញប្បទានបន្ថែម សម្រាប់បន្តការវិនិយោគ ឬពង្រីកអាជីវកម្មរបស់ក្រុមហ៊ុន តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈដល់វិនិយោគិន។

នៅក្នុងន័យនេះ ដើម្បីទិញមូលបត្រពីទីផ្សារដំបូង វិនិយោគិនត្រូវធ្វើការបញ្ជាទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយនៅក្នុងដំណាក់កាលប៊ុកបៀលឌីង (Book building) ឬការស្ទាបស្ទង់ថ្លៃ និង/ឬការធ្វើបរិវិសកម្ម (subscription) ឬការចុះឈ្មោះទិញ។ បន្ថែមពីនេះ លំហូរសាច់ប្រាក់នៅក្នុងទីផ្សារដំបូង គឺចេញពីវិនិយោគិន ទៅកាន់ក្រុមហ៊ុនបោះផ្សាយ ហើយវិនិយោគិនដែលបានទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយនឹងក្លាយជាភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយនោះ។

## ៣.២ ដំណើរការជួញដូរមូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គឺជាទីផ្សារបន្ទាប់សម្រាប់វិនិយោគិនក្នុងការដាក់បញ្ជាទិញ ឬលក់មូលបត្រដែលបានចុះបញ្ជី និងបានបោះផ្សាយលក់ជាសាធារណៈរួចមកហើយ។ ការជួញដូរមូលបត្រនៅទីផ្សារបន្ទាប់ត្រូវបានអនុលោមតាមវិធានប្រតិបត្តិការទីផ្សាររបស់ ផ.ម.ក. ដែលប្រកាសដាក់ឲ្យអនុវត្តដោយ **ន.ម.ក.**។

*រូបភាពទី៣.២៖ ការជួញដូរមូលបត្រនៅទីផ្សារបន្ទាប់*




## ៣.២.១ ដំណាក់កាលដំបូងមុននឹងការចាប់ផ្តើមជួញដូរមូលបត្រ

### ៣.២.១.១ ការស្នើសុំលេខអត្តសញ្ញាណវិនិយោគិន

លេខអត្តសញ្ញាណវិនិយោគិន គឺជាលេខសម្គាល់វិនិយោគិន រូបវន្តបុគ្គល ឬនីតិបុគ្គលមួយ។ សាធារណជនទូទៅដែលមានបំណងវិនិយោគលើវិស័យមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានលេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី **ន.ម.ក.**។ វិនិយោគិនអាចស្នើសុំលេខអត្តសញ្ញាណវិនិយោគិននេះដោយផ្ទាល់ពី **ន.ម.ក.** ឬតាមប្រព័ន្ធអនឡាញពី **ន.ម.ក.** ឬតាមរយៈក្រុមហ៊ុនមូលបត្រដែលបានទទួលអាជ្ញាបណ្ណពី **ន.ម.ក.**។ លេខអត្តសញ្ញាណវិនិយោគិនមានសុពលភាពរយៈពេល១០ឆ្នាំ ហើយវិនិយោគិនអាចស្នើសុំបន្តបាន មុនពេលអស់សុពលភាព៣ខែ។ វិនិយោគិនម្នាក់អាចស្នើសុំលេខអត្តសញ្ញាណវិនិយោគិនបានតែមួយប៉ុណ្ណោះ ទម្រង់លេខអត្តសញ្ញាណវិនិយោគិនមានចំនួន១២ខ្ទង់ ផ្តើមដោយអក្សរ D សម្រាប់វិនិយោគិនជនជាតិខ្មែរ និងអក្សរ F សម្រាប់វិនិយោគិនជនជាតិបរទេស។ ឧទាហរណ៍: D12345678901 សម្រាប់វិនិយោគិនជនជាតិខ្មែរ និង សម្រាប់វិនិយោគិនជនជាតិបរទេស F12345678901។

#### i. ការបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនដោយផ្ទាល់

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញពាក្យស្នើសុំទៅតាមទម្រង់ដែលបានកំណត់ដោយ ន.ម.ក និងភ្ជាប់មកជាមួយនូវឯកសារតម្រូវដូចខាងក្រោម៖[47]

[47] គោលការណ៍ណែនាំលេខ០០១ គ.ម.ក./គ.ណ.ន. ស្តីពីការផ្តល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២

- ចំពោះវិនិយោគិនជារូបវន្តបុគ្គល ត្រូវ៖
  - បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ក) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤ x ៦ មួយសន្លឹក
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាពថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ
  - លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ សម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរ
  - ប្រវត្តិរូបសង្ខេបដោយមានព័ត៌មានស្ដីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ។
- ចំពោះវិនិយោគិនជានីតិបុគ្គល វិនិយោគិនត្រូវ៖
  - បំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន (ទម្រង់ ខ) ដោយមានបិទរូបថត ដែលថតចំពីមុខ ទំហំ ៤x៦ មួយសន្លឹក របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល
  - ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖
    - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និង/ឬអាជ្ញាបណ្ណធ្វើអាជីវកម្មថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ
    - វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនបើមាន
    - ឈ្មោះអភិបាល ដោយបញ្ជាក់ពីសញ្ជាតិ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណបណ្ណសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនសម្រាប់វិនិយោគិនមិនមែនសញ្ជាតិខ្មែរថតចម្លងមានបញ្ជាក់ត្រឹមត្រូវរបស់អភិបាលនីមួយៗ
    - លិខិតផ្ទេរសិទ្ធិរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងប្រវត្តិរូបសង្ខេបរបស់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ដោយមានព័ត៌មានស្ដីពីប្រវត្តិសិក្សា និងបទពិសោធន៍ការងារ
    - បញ្ជីឈ្មោះអ្នកដែលមានសិទ្ធិ ឬចូលរួមក្នុងការសម្រេចចិត្តវិនិយោគក្នុងវិស័យមូលបត្រ។

**ii. ការបំពេញពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ**

បុគ្គលស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ ត្រូវភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ ដោយថតជារូបភាព ឬស្កែន (Scan) ឱ្យបានច្បាស់នូវឯកសារដូចខាងក្រោម៖[48]

ចំពោះវិនិយោគិនជារូបវន្តបុគ្គល

- បំពេញព័ត៌មានស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ ដោយមានភ្ជាប់មកជាមួយ រូបថត ៤ x ៦ របស់រូបវន្តបុគ្គល ថតចំពីមុខគ្មានពាក់វ៉ែនតាក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែចុងក្រោយ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវសម្រាប់វិនិយោគិនសញ្ជាតិខ្មែរ

[48] គោលការណ៍ណែនាំលេខ ០០២/២០ គ.ម.ក./គ.ណ.ន. ស្ដីពីការផ្ដល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

- លិខិតឆ្លងដែនមានសុពលភាព ថតចម្លងមានបញ្ជាក់ត្រឹមត្រូវសម្រាប់វិនិយោគិនសញ្ជាតិបរទេស
- ស្នាមមេដៃស្ដាំ ឬហត្ថលេខា និងឈ្មោះរបស់រូបវន្តបុគ្គល
- ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ក.**

➢ ចំពោះវិនិយោគិនជានីតិបុគ្គល

- បំពេញព័ត៌មានស្នើសុំលេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ ដោយមានភ្ជាប់មកជាមួយ រូបថត ៤ x ៦ របស់បុគ្គលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ថតចំពីមុខគ្មានពាក់វ៉ែនតាក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែចុងក្រោយ។
- ភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖
  - វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងអាជ្ញាបណ្ណធ្វើអាជីវកម្មរបស់នីតិបុគ្គល
  - ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ (ប្រសិនបើមាន)
  - វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ)
  - លក្ខន្តិកៈក្រុមហ៊ុន ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ
  - អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរមានសុពលភាព សម្រាប់វិនិយោគិនសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនមានសុពលភាពសម្រាប់វិនិយោគិនសញ្ជាតិបរទេសរបស់បុគ្គល មានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល ថតចម្លងមានបញ្ជាក់ត្រឹមត្រូវ
  - លិខិតផ្ទេរសិទ្ធិ ដល់បុគ្គលតំណាងចុះហត្ថលេខាក្នុងនាមនីតិបុគ្គល
  - ស្នាមមេដៃស្ដាំ ឬហត្ថលេខា និងឈ្មោះរបស់បុគ្គលតំណាង
  - ត្រាសម្គាល់នីតិបុគ្គល
  - ឯកសារពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **ន.ម.ក.** ។

iii. **ថ្លៃសេវានៃការដាក់ពាក្យស្នើសុំ ឬស្នើបន្តលេខអត្តសញ្ញាណវិនិយោគិន**

បុគ្គលដាក់ពាក្យស្នើសុំលេខអត្តសញ្ញាណវិនិយោគិន ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនៅពេលដាក់ពាក្យស្នើសុំ ឬស្នើសុំបន្តលេខអត្តសញ្ញាណវិនិយោគិននៅ **ន.ម.ក.** ដូចតទៅ៖

- ចំពោះរូបវន្តបុគ្គល ជាសាច់ប្រាក់ចំនួន ២០.០០០ (ពីរម៉ឺនរៀល)
- ចំពោះនីតិបុគ្គល ជាសាច់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺនរៀល)។

### ៣.២.១.២ ការបើកគណនីជួញដូរមូលបត្រ គណនីសាច់ប្រាក់ និងគណនីមូលបត្រ

បន្ទាប់ពីទទួលបានលេខអត្តសញ្ញាណវិនិយោគិនពី ន.ម.ក. វិនិយោគិនត្រូវធ្វើការបើកគណនីជួញដូរនៅក្រុមហ៊ុនមូលបត្រណាមួយដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. ដើម្បីធ្វើជាអ្នកតំណាងក្នុងការជួញដូរមូលបត្រ។ បន្ទាប់

ពីជ្រើសរើសក្រុមហ៊ុនមូលបត្ររួច វិនិយោគិនម្នាក់អាចបើកគណនីជួញដូរមួយនៅក្រុមហ៊ុនមូលបត្រតែមួយគត់ ដែលបានជ្រើសរើស ប៉ុន្តែវិនិយោគិនអាចបើកគណនីជួញដូរលើសពីមួយបាន ដោយជ្រើសរើសក្រុមហ៊ុនមូលបត្រផ្សេងៗទៀតដែលខ្លួនពុំទាន់បានបើកគណនីជួញដូរជាមួយ។

ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក. មានចំនួន១២ ក្នុងនោះមាន៖[49]

១. យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី / Yuanta Securities (Cambodia) Plc.

២. អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក / RHB Indochina Securities PLC.

៣. កាណា ស៊ីឃ្យូរីធី អិលធីឌី / Cana Securities Ltd.

៤. កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី / Campu Securities Plc.

៥. អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី / SBI Royal Securities Plc.

៦. ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី / Phnom Penh Securities Plc.

៧. ខេមបូឌា ស៊ីឃ្យូរីធី ម.ក / Cambodia Securities Plc.

៨. ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី / Golden Fortune (Cambodia) Securities Plc.

៩. អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី / ACLEDA Securities Plc.

១០. ខេប ស៊ីឃ្យូរីធី លីមីធីត / CAB Securities Limited.

១១. ខេមបូឌាវៀតណាម ស៊ីឃ្យូរីធី ឯ.ក / Cambodia-Vietnam Securities Co., Ltd.

១២. ភីភី លីង ស៊ីឃ្យូរីធី ឯ.ក / PP Link Securities Co., Ltd

- **គណនីសាច់ប្រាក់៖** វិនិយោគិនត្រូវដាក់តម្កល់ប្រាក់១០០% ដើម្បីធ្វើការជួញដូរមូលបត្រ។ ក្រុមហ៊ុនមូលបត្រត្រូវយកសាច់ប្រាក់ដែលអតិថិជន បានដាក់តម្កល់នោះ ដាក់ចូលក្នុងគណនីសាច់ប្រាក់អតិថិជន (Client Money Account) នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent)។
- **គណនីមូលបត្រ៖** សម្រាប់រក្សាទុកមូលបត្រនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ។ មូលបត្ររបស់វិនិយោគិនត្រូវបានរក្សាទុកនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដាច់ដោយឡែកពីទ្រព្យរបស់ក្រុមហ៊ុនមូលបត្រ។

### ៣.២.២. ប្រតិបត្តិការទីផ្សារ

#### ៣.២.២.១. ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃ ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីការងារ។ ចំពោះម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ០៨:០០ នាទី ព្រឹករហូតដល់ម៉ោង ៣:០០ រសៀល ដែល

[49] https://www.serc.gov.kh/khmer/m52.php?pn=6 (ចូលទស្សនានៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២)

បែងចែកជាបីវគ្គ ដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម៖[50]

**តារាងទី ៣.៧៖ ពេលវេលានៃការជួញដូរ**

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:00 ព្រឹក - ៩:00 ព្រឹក | ៩:00 ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:00 ព្រឹក - ១៤:៥0 រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១៤:៥0រសៀល-១៥:00 រសៀល | ១៥:00 រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនបើមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:00 នាទី ព្រឹកទេ វគ្គបើកនឹងត្រូវពន្យាពេលរហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល ។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា៖ ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៩:00 ព្រឹក ដល់ម៉ោង ១៥:00 រសៀល។

#### ៣.២.២.២. ប្រភេទបញ្ជា

បច្ចុប្បន្នមានបញ្ជាចំនួន៣ប្រភេទ ដូចខាងក្រោម៖[51]

**ក. បញ្ជាដែនកំណត់** (Limit Order)

ជាបញ្ជាដែលមានថ្លៃជាក់លាក់មួយ ដើម្បីទិញ ឬលក់មូលបត្រនៅថ្លៃជាក់លាក់នោះ ឬនៅថ្លៃប្រសើរជាងថ្លៃជាក់លាក់នោះ។ ថ្លៃប្រសើរជាងថ្លៃជាក់លាក់ គឺជាថ្លៃទាបជាងថ្លៃជាក់លាក់នោះក្នុងករណីទិញ ឬជាថ្លៃខ្ពស់ជាងថ្លៃជាក់លាក់នោះក្នុងករណីលក់។

**ខ. បញ្ជាទីផ្សារ** (Market Order)

ជាបញ្ជាដើម្បីទិញ ឬលក់មូលបត្រកម្មសិទ្ធ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូង នៃមូលបត្រចុះបញ្ជីលក់លើកដំបូង។ នៅក្នុងវគ្គនិរន្តរ៍ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

- លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចូល (Fill or Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។

[50] http://csx.com.kh/operation/market/listPosts.do?MNCD=3020 (ចូលទស្សនា ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១)

[51] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនា ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១)

- លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill)៖ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុង ឬមួយផ្នែកភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចូលភ្លាម។

**គ. បញ្ជាតាមការចរចា** (Negotiated Order)

ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

### ៣.២.២.៣. ការដាក់បញ្ជា

ក្នុងរយៈពេលយ៉ាងហោចណាស់មួយថ្ងៃ បន្ទាប់ពីបើកគណនីជួញដូររួច ទើបវិនិយោគិនអាចដាក់បញ្ជាទៅក្នុងប្រព័ន្ធជួញដូររបស់ **ផ.ម.ក.** ដើម្បីធ្វើការជួញដូរបាន។ វិនិយោគិនអាចធ្វើការដាក់បញ្ជាទិញ ឬលក់មូលបត្រទៅកាន់ក្រុមហ៊ុនមូលបត្រដែលខ្លួនបានជ្រើសរើស តាមរយៈការអញ្ជើញទៅក្រុមហ៊ុនមូលបត្រនោះដោយផ្ទាល់ ឯកសារជាលាយលក្ខណ៍អក្សរ ការហៅទូរស័ព្ទ សារជាសំឡេង អ៊ីម៉ែល ឬវិធីសាស្ត្រអេឡិចត្រូនិចផ្សេងៗទៀត ហើយជាពិសេសវិនិយោគិនអាចប្រើប្រាស់នូវប្រព័ន្ធជួញដូរចល័ត (MTS Mobile Trading System) របស់ ផ.ម.ក. បានផងដែរ។ ដើម្បីធ្វើការដាក់បញ្ជាបានសម្រេច វិនិយោគិនត្រូវភ្ជាប់មកជាមួយនូវព័ត៌មានលម្អិតនៃការដាក់បញ្ជា និងត្រូវមានសាច់ប្រាក់យ៉ាងហោចណាស់ ១០០% សម្រាប់បញ្ជាទិញ ឬមានមូលបត្រយ៉ាងហោចណាស់ ១០០% សម្រាប់ការដាក់បញ្ជាលក់។

### ៣.២.២.៤. ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ត្រូវមានព័ត៌មានលម្អិតដូចជា៖

១. ឈ្មោះមូលបត្រ

២. បរិមាណ

៣. ថ្លៃ ករណីក្រៅពីបញ្ជាទីផ្សារ

៤. លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា

៥. ការបញ្ជាក់ពីបញ្ជា៖ បញ្ជាទិញ ឬបញ្ជាលក់

៦. ប្រភេទនៃប្រតិបត្តិការ៖ ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក

៧. លេខអត្តសញ្ញាណសមាជិក

៨. លេខអត្តសញ្ញាណវិនិយោគិន

៩. លេខបញ្ជា

១០. លេខគណនីជួញដូរ

១១. ក្នុងករណីលុប ឬកែប្រែបញ្ជា ត្រូវបញ្ជាក់ថាជាការលុប ឬជាការកែប្រែ ហើយត្រូវបញ្ជាក់លេខបញ្ជាដើមផងដែរ

១២. លេខកូដវិនិយោគិន៖ ជារូបវន្តបុគ្គល ឬនីតិបុគ្គល

១៣. លេខកូដប្រទេសរបស់វិនិយោគិន។

**៣.២.២.៥. ឯកតាគម្លាតថ្លៃ**

ឯកតាគម្លាតថ្លៃ សម្រាប់ថ្លៃនៃមូលបត្រកម្មសិទ្ធិនីមួយៗត្រូវបានកំណត់ដូចខាងក្រោម៖[52]

| ថ្លៃមូលដ្ឋាន (P) | ឯកតាគម្លាតថ្លៃ | ឧទាហរណ៍ថ្លៃបញ្ជាដែលខុស | ឧទាហរណ៍ថ្លៃបញ្ជាដែលត្រឹមត្រូវ |
|---|---|---|---|
| P < 4,000 | 10 | 2,555; 3,012; 3,999 | 2,550; 2,560; 3,010; 3,020; 3,999 |
| 4,000 ≤ P < 20,000 | 20 | 4,210; 19,525 | 4,200; 4,220; 19,520; 19,540 |
| 20,000 ≤ P < 40,000 | 50 | 20,110; 35,530 | 20,100; 20,150; 35,500; 35,550 |
| 40,000 ≤ P< 100,000 | 100 | 50,720; 90,450 | 50,700; 50,800; 90,400; 90,500 |
| 100,000 ≤ P < 200,000 | 200 | 150,500; 125,300 | 150,400; 150,600; 125,200;125,400 |
| 200,000 ≤ P < 400,000 | 500 | 300,100; 350,200 | 300,000; 300,500; 350,000; 350,500 |
| P ≥ 400,000 | 1000 | 620,500; 852,100 | 620,000; 621,000; 852,00; 853,000 |

**៣.២.២.៦. ថ្លៃមូលដ្ឋាន**

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិចុះបញ្ជីលក់លើកដំបូង សំដៅដល់ថ្លៃជួញដូរដំបូងដែលត្រូវបានកំណត់នៅចន្លោះពី ៩០% (កៅសិបភាគរយ) ទៅ ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ ចំណែកឯ ថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

**៣.២.២.៧. ថ្លៃពិសេស**

ថ្លៃពិសេសសំដៅដល់ថ្លៃដូចខាងក្រោម ក្នុងករណីមូលបត្រកម្មសិទ្ធិមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទផ្សារ៖

[52] http://csx.com.kh/operation/stock/listPosts.do?MNCD=30202 (ចូលទស្សនា ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១)

➢ ថ្លៃល្អបំផុតនៃសំណើលក់ (Best Ask) ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង ឬ

➢ ថ្លៃល្អបំផុតនៃសំណើទិញ (Best Bid) ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង។

**ឧទាហរណ៍១៖**

**តារាងទី ៣.៨៖ ថ្លៃពិសេសនៃសំណើលក់**

| បញ្ជាលក់ (Ask Order) | ថ្លៃ (Price) | បញ្ជាទិញ (Bid Order) |
|---|---|---|
| ① 300 | 10,420 | |
| | 10,400 (ថ្លៃមូលដ្ឋាន) | |
| ② 200 | 10,380 | |
| | 10,360 | |
| | 10,340 | ③ 100 |

- គ្មានការជួញដូរកើតមានឡើងរហូតដល់ផ្សារបិទ
- ថ្លៃពិសេស គឺ៖ 10,380 ៛

**ឧទាហរណ៍២៖**

**តារាងទី ៣.៩៖ ថ្លៃពិសេសនៃសំណើទិញ**

| បញ្ជាលក់ (Ask Order) | ថ្លៃ (Price) | បញ្ជាទិញ (Bid Order) |
|---|---|---|
| ③ 700 | 10,420 | |
| | 10,400 | |
| | 10,380 | ① 300 |
| | 10,360 (ថ្លៃមូលដ្ឋាន) | |
| | 10,340 | ② 100 |

- គ្មានការជួញដូរកើតមានឡើងរហូតដល់ផ្សារបិទ
- ថ្លៃពិសេស គឺ៖ 10,380 ៛

### ៣.២.២.៨. វិធីសាស្ត្រជួញដូរមូលបត្រកម្មសិទ្ធិ

វិធីសាស្ត្រជួញដូរ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រចំនួនពីរគឺ វិធីសាស្ត្រដេញថ្លៃ (Auction Trading Method) និងវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

### ក. វិធីសាស្ត្រដេញថ្លៃ

វិធីសាស្ត្រដេញថ្លៃ គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាទិញ និងបញ្ជាលក់ដោយស្វ័យប្រវត្តិ តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction) ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលរាល់បញ្ជាទិញ និងបញ្ជាលក់ទាំងអស់ ត្រូវផ្គូផ្គងព្រមគ្នា និងជួញដូរនៅថ្លៃតែមួយ។
- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលរាល់បញ្ជាទិញ ឬបញ្ជាលក់មួយត្រូវបានផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗគ្នា។

❖ អាទិភាពនៃបញ្ជាតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើនត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម៖

#### ក. អាទិភាពថ្លៃ

បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

#### ខ. អាទិភាពពេលវេលា

ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុន មានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

***លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រដេញថ្លៃចំពោះមូលបត្រកម្មសិទ្ធិ៖**

- បញ្ជាអប្បបរមា៖ ១ភាគហ៊ុន
- អតិបរមា៖ មិនកំណត់
- ឯកតាគម្លាតថ្លៃ៖ 10, 20, 50, 100, 200, 500,1000 (រៀល)
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ ±10% នៃថ្លៃមូលដ្ឋាន

### ខ. វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)

គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញ និងលក់មួយគូ បន្ទាប់ពីភាគីទាំងពីបានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។ បញ្ជាជួញដូរតាមការចរចាទាំងសងខាង ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងគឺ ឈ្មោះមូលបត្រ បរិមាណ ថ្លៃ និងលេខកូដជួញដូរតាមការចរចា។

*លក្ខណៈសំខាន់ៗនៃវិធីសាស្ត្រជួញដូរតាមការចរចាចំពោះមូលបត្រកម្មសិទ្ធិ៖

- បញ្ជាអប្បបរមា៖ បញ្ជាតាមការចរចាត្រូវមានបរិមាណយ៉ាងហោច ៥០.០០០ ភាគហ៊ុន ឬតម្លៃជួញដូរ ២០០.០០០.០០០ រៀល។
- ឯកតាគម្លាតថ្លៃ៖ ១ រៀល។
- ដែនកំណត់ថ្លៃប្រចាំថ្ងៃ៖ មិនអនុវត្ត។

### ៣.២.២.៩ ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

វិនិយោគិនអាចដាក់បញ្ជាបានលុះត្រាតែមានសាច់ប្រាក់ យ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាទិញ) ដែលរួមបញ្ចូលទាំងថ្លៃសេវាឈ្មួញជើងសាមូលបត្រ ឬបរិមាណមូលបត្រយ៉ាងហោចមួយរយភាគរយ (សម្រាប់បញ្ជាលក់)។ ពេលបញ្ជាត្រូវបានបញ្ជូនចេញ សាច់ប្រាក់និងមូលបត្រទាំងនេះនឹងត្រូវបានបង្កកទុកដោយសមាជិក ក្នុងគោលបំណងដើម្បីទូទាត់ ឬបង្កកទុករហូតដល់ពេលបញ្ជានោះអស់សុពលភាព។[53]

*រូបភាពទី៣.៣៖ ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ*




(១) វិនិយោគិនបើកគណនីជួញដូរ (គណនីមូលបត្រ និងគណនីសាច់ប្រាក់) នៅក្រុមហ៊ុនមូលបត្រនៅថ្ងៃ T-1។ ក្រុមហ៊ុនមូលបត្រនឹងធ្វើការស្នើសុំលេខអត្តសញ្ញាណវិនិយោគិនជូនអតិថិជនរបស់ខ្លួនពីនិយ័តករមូលបត្រកម្ពុជា។

(២) វិនិយោគិនដាក់បញ្ជាទិញ ឬលក់នៅថ្ងៃ T+0 តាមប្រព័ន្ធជួញដូរចល័ត (MTS) ឬក្រុមហ៊ុនមូលបត្រជាលាយលក្ខណ៍អក្សរ ជាពាក្យសម្តី (ត្រូវបានថតទុកដោយអ្នកតំណាងនៅក្នុងទីផ្សារ) ឬមធ្យោបាយអេឡិចត្រូនិចនានា។

[53] http://csx.com.kh/operation/market/listPosts.do?MNCD=30201 (ចូលទស្សនានៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២)

(៣) បន្ទាប់ពីដាក់បញ្ជាមកក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. នៅថ្ងៃ T+0 បានជោគជ័យដោយមានមូលបត្រ និងសាច់ប្រាក់គ្រប់គ្រាន់ នៅក្នុងគណនីរបស់វិនិយោគិន (សាច់ប្រាក់ ឬបរិមាណមូលបត្រមួយរយភាគរយដែលពាក់ព័ន្ធនឹងបញ្ជានោះ) សាច់ប្រាក់ ឬមូលបត្រនឹងត្រូវបានបង្កកទុកសម្រាប់ទូទាត់នៅថ្ងៃ T+2។

(៤) ការបញ្ជាទាំងឡាយត្រូវបានផ្គូរផ្គងនៅក្នុងប្រព័ន្ធជួញដូររបស់ ផ.ម.ក. ទៅតាមគោលការណ៍ដេញថ្លៃដែលបានកំណត់ទុកជាមុន T+0។

(៥) **ផ.ម.ក.** ជូនដំណឹងអំពីលទ្ធផលនៃការជួញដូរទៅកាន់ក្រុមហ៊ុនមូលបត្រ នៅថ្ងៃ T+0។

(៦) ក្រុមហ៊ុនមូលបត្របញ្ជាក់អំពីលទ្ធផលនៃការជួញដូរជាមួយអតិថិជននីមួយៗរបស់ខ្លួននៅថ្ងៃT+0។

(៧) ក្នុងករណីមានកំហុសឆ្គងដែលបង្កឡើងដោយក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនមូលបត្រនោះត្រូវដាក់ពាក្យស្នើសុំមកកាន់ ផ.ម.ក. ដើម្បីកែតម្រូវអោយបានមុនពេលថ្ងៃត្រង់នៃថ្ងៃ T+1។ បន្ទាប់ពីកំហុសឆ្គង ត្រូវបានកែតម្រូវហើយ ដំណើរការក្នុងចំណុចទី៥ និងទី៦ នឹងត្រូវអនុវត្តម្តងទៀត។

(៨) វិនិយោគិនបង់ប្រាក់ ឬបញ្ជូនមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រនៅថ្ងៃ T+2។

(៩) ក្រុមហ៊ុនមូលបត្រទូទាត់ការជួញដូរក្នុងនាមជាវិនិយោគិននៅ **ផ.ម.ក.** នៅថ្ងៃ T+2។

## ៣.២.៣. ប្រតិបត្តិការផាត់ទាត់ និងទូទាត់

### ៣.២.៣.១. ប្រព័ន្ធផាត់ទាត់ និងទូទាត់

ប្រព័ន្ធផាត់ទាត់ និងទូទាត់ សំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្របំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមកបាន ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការបានយ៉ាងច្បាស់លាស់ និងធានាឲ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រឱ្យអ្នកទិញ។ ប្រព័ន្ធផាត់ទាត់ និងទូទាត់រួមមាន៖ ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ និងប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់។

+ **ប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ៖** សំដៅដល់ប្រព័ន្ធផាត់ទាត់ និងទូទាត់ ដើម្បីធ្វើការផ្លាស់ប្តូរកម្មសិទ្ធិលើមូលបត្ររវាងភាគីប្រតិបត្តិការជួញដូរមូលបត្រ។

+ **ប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់៖** សំដៅដល់ប្រព័ន្ធផាត់ទាត់ និងទូទាត់ ដើម្បីធ្វើការផ្ទេរ ឬបង្វែរសាច់ប្រាក់រវាងភាគីធ្វើប្រតិបត្តិការជួញដូរមូលបត្រ។ ក្រុមហ៊ុនមូលបត្រនីមួយៗ ត្រូវបើកគណនីដោយឡែក ចំនួនបី គឺ៖ គណនីសាច់ប្រាក់អតិថិជន គណនីសាច់ប្រាក់ផ្ទាល់ខ្លួន និងគណនីទូទាត់សាច់ប្រាក់។

+ **តួអង្គសំខាន់ៗនៅក្នុងយន្តការនៃការផាត់ទាត់ និងទូទាត់៖**

ការផាត់ទាត់ និងទូទាត់មូលបត្រមានការចូលរួមពីភាគីពាក់ព័ន្ធមួយចំនួនដូចជា៖

- CSX: ប្រតិបត្តិករទីផ្សារមូលបត្រ
- CSO: ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ
- CSD: ប្រតិបត្តិកររក្សាទុកមូលបត្រ

- SFs: ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី ន.ម.ក.
- CSAs: ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ
- NBC: ធនាគារជាតិនៃកម្ពុជា ។

**រូបភាព ៣.៤៖ ដំណើរការនៃប្រព័ន្ធជាត់ទាត់ និងទូទាត់**




(១). ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវបញ្ជូនព័ត៌មានពីការជួញដូរដែលបានបន្ទៀងផ្ទាត់ (Confirmed Trade) ទៅ CSO

- CSO ត្រូវធ្វើការបន្សុទ្ធ (Netting) សាច់ប្រាក់ និងមូលបត្រ

+បន្សុទ្ធសាច់ប្រាក់ = ផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សម្រាប់សមាជិកនីមួយៗ

+បន្សុទ្ធមូលបត្រ = ផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ

(២). CSO បញ្ជូនព័ត៌មាននៃកាលបរិច្ឆេទផាត់ទាត់និងទូទាត់ ទឹកប្រាក់ និងបរិមាណនៃមូលបត្រនីមួយៗដែលត្រូវធ្វើការទូទាត់ដោយសមាជិកផ្ទាល់ ឬក្នុងនាមអតិថិជនទៅ SF(s)

(៣). SF(s) ត្រូវដាក់ការបញ្ជាទូទាត់សាច់ប្រាក់ទៅ CSA ដែលពាក់ព័ន្ធ

(៤). SF(s) ត្រូវដាក់ការបញ្ជាទូទាត់មូលបត្រទៅ CSD

### ៣.២.៣.២. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់សាច់ប្រាក់

### ក. ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ

**រូបភាព ៣.៥៖ ការទូទាត់សាច់ប្រាក់នៅក្នុងធនាគារតែមួយ**



(១)- SF (អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២)- បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាច់ប្រាក់របស់ SF (អ្នកលក់)

**ខ. ការទូទាត់សាច់ប្រាក់អន្តរធនាគារ**

រូបភាព ៣.៦៖ ការទូទាត់សាច់ប្រាក់អន្តរធនាគារ




(១). SF (អ្នកទិញ) ត្រូវផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់ខ្លួន ទៅគណនីទូទាត់សាច់ប្រាក់របស់ CSO

(២). បន្ទាប់មក CSO ត្រូវធ្វើការផ្ទេរសាច់ប្រាក់បន្តពីគណនីទូទាត់សាច់ប្រាក់របស់ខ្លួន ទៅគណនីសាច់ប្រាក់របស់ SF (អ្នកលក់) ដែលបើកនៅក្នុង CSA2 តាមរយៈសភាផាត់ទាត់នៃ NBC ។

**៣.២.៣.៣. ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ**

រូបភាព ៣.៧៖ ដំណើរការនៃប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ




(១). SF (អ្នកលក់) ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីទូទាត់មូលបត្ររបស់ CSO។

(២). CSO ត្រូវផ្ទេរមូលបត្រ (Book-entry Transfer) ពីគណនីមូលបត្ររបស់ខ្លួន ទៅគណនីមូលបត្ររបស់ SF (អ្នកទិញ)។

### ៣.២.៤. ប្រតិបត្តិការនៃការរក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រសំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើមូលបត្រ ហើយការដាក់ផ្ញើមូលបត្រ គឺជាដំណើរការនៃការផ្ទេរកម្មសិទ្ធិករមូលបត្រ តាមរយៈការផ្ទេររវាងគណនី (Book Entry) (ការកត់ត្រាឥណទាន/ឥណពន្ធក្នុងសៀវភៅគណនីរបស់សមាជិក និងអ្នកចូលរួម) ដោយគ្មានចរន្តនៃការផ្ទេរមូលបត្ររូបវ័ន្ត។ ប្រតិបត្តិការរក្សាទុកមូលបត្រ គឺត្រូវចាប់ដំណើរការផ្ទេរមូលបត្រ (Book Entry Transfer) នៅថ្ងៃទីពីរនៃការជួញដូរ (T+២) បន្ទាប់ពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ ត្រូវបានអនុវត្តចប់រវាងក្រុមហ៊ុនមូលបត្រ និងអតិថិជន ដោយការផ្ទេរមូលបត្រ ត្រូវបានផ្ទេរតាមប្រព័ន្ធ Ledger System។

សមាជិក អ្នកចូលរួម និងអតិថិជនដែលបានដាក់ផ្ញើមូលបត្រនៅ **ផ.ម.ក.** មិនចាំបាច់ដកមូលបត្រទៅវិញនៅពេលដែលត្រូវអនុវត្តន៍សិទ្ធិកម្មសិទ្ធិករឡើយ។ បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្ររួមមាន ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ។ បុគ្គលដែលមានបំណងបើកគណនីមូលបត្រត្រូវបំពេញសំណុំបែបបទបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។ គ្រប់គណនីមូលបត្រទាំងអស់ រួមមានគណនីមូលបត្ររបស់សមាជិក ឬអតិថិជនត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធ Ledger (ledger system) របស់ **ផ.ម.ក.** ដែលផ្ទុកផងដែរនូវទិន្នន័យលម្អិតនៃប្រតិបត្តិការរបស់សមាជិក និងអតិថិជន ព្រមទាំងទិន្នន័យលម្អិតនៃបញ្ជីភាគហ៊ុនិក។[54]

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** បុគ្គលដែលដាក់ផ្ញើត្រូវផ្តល់ព័ត៌មានដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារបញ្ជិកាមូលបត្រដូចខាងក្រោម៖

- ឈ្មោះមូលបត្រដែលដាក់ផ្ញើ
- ប្រភេទមូលបត្រដែលដាក់ផ្ញើ
- ថ្លៃមូលបត្រដែលដាក់ផ្ញើ
- ចំនួនមូលបត្រដែលដាក់ផ្ញើ
- ចំនួនមូលបត្រដែលបានបោះផ្សាយ
- អក្សរកូដមូលបត្រដែលដាក់ផ្ញើ
- លេខកូដមូលបត្រដែលដាក់ផ្ញើ
- កាលបរិច្ឆេទបោះផ្សាយមូលបត្រដែលដាក់ផ្ញើ
- កាលបរិច្ឆេទចុះបញ្ជីមូលបត្រដែលដាក់ផ្ញើ
- ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពលើមូលបត្រដែលដាក់ផ្ញើ។

[54] http://csx.com.kh/operation/depository/listPosts.do?MNCD=3040 (ចូលទស្សនា ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២២)

## ៣.៣. និន្នាការទូទៅនៃការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិ

### ៣.៣.១. ចំនួនក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិពីឆ្នាំ២០១២ ដល់ឆ្នាំ ២០២១

យោងទៅតាមគេហទំព័ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចាប់តាំងពីឆ្នាំ ២០១២ រហូតមកដល់ត្រឹម ឆ្នាំ ២០២១ មានក្រុមហ៊ុនចំនួន ៨ ដែលបានបោះផ្សាយ និងចុះញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក. ដែលរួមមានដូច ខាងក្រោម៖

- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PWSA) (ចុះបញ្ជីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២)
- ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (GTI) (ចុះបញ្ជីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤)
- កំពង់ផែស្វយ័តភ្នំពេញ (PPAP)៖ ចុះបញ្ជីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥
- ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)៖ ចុះបញ្ជីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)៖ ចុះបញ្ជីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៧
- ធនាគារ អេស៊ីលីដា ភីអិលស៊ី (ABC)៖ ចុះបញ្ជីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០
- ក្រុមហ៊ុនផេសចិក (ខេមបូឌា) ម.ក (PEPC)៖ ចុះបញ្ជីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០
- ក្រុមហ៊ុនឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (DBDE)៖ ចុះបញ្ជីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១




**ក្រាហ្វិចទី ១៖ ចំនួនក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០២១**

**បកស្រាយ៖** តាមតារាងខាងលើ យើងសង្កេតឃើញថា នៅឆ្នាំ២០១២ ២០១៤ ២០១៥ ២០១៦ ២០១៧ និងឆ្នាំ ២០២១ មានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិតែមួយទេក្នុងឆ្នាំនីមួយៗ និងក្នុងឆ្នាំ ២០២០

មានក្រុមហ៊ុនចំនួនពីរ។ ចំណែកនៅឆ្នាំ ២០១៣ ២០១៨ និងឆ្នាំ ២០១៩ វិញ គឺមិនមានក្រុមហ៊ុបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិទេ។

### ៣.៣.២. តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង

| និមិត្តសញ្ញាហ៊ុន | តម្លៃបោះផ្សាយលក់ភាគហ៊ុន | ចំនួនហ៊ុនដែលបោះផ្សាយ |
|---|---|---|
| PWSA | ៦.៣០០រៀល | ១៣.០៤៥.៩៧៥ |
| GTI | ៩.៦៤០ រៀល | ៨.០០០.០០០ |
| PPAP | ៥.១២០ រៀល | ៤.១៣៦.៨៧៣ |
| PPSP | ២.៨៦០ រៀល | ១១.៥៧៥.០០០ |
| PAS | ៥.០៤០ រៀល | ២១.៤៤២.៩៩២ |
| ABC | ១៦.២០០ រៀល | ៤.៣៤៤.៨៦៥ |
| PEPC | ៣.១២០ រៀល | ៣.៩៤៥.០០០ |
| DBDE | ២.៣៨០ រៀល | ៦.៤៦១.៥៣៨ |

តារាង ៣.១០ ៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង




ក្រាហ្វិចទី ២៖ តម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង

**បកស្រាយ៖** តាមក្រាបខាងលើ យើងសង្កេតឃើញថា ធនាគារ អេស៊ីលីដា ភីអិលស៊ី មានតម្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងខ្ពស់ជាងគេ គឺមានតម្លៃ ១៦.២០០ រៀល ក្នុងមួយហ៊ុន។ ចំណែកឯក្រុមហ៊ុនដែលមានតម្លៃ IPO ទាបជាងគេគឺ ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក ដែលមានតម្លៃ ២.៣៨០រៀល ។ ម្យ៉ាងទៀត ចំពោះក្រុមហ៊ុនដែលបានធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈលើកដំបូងច្រើនហ៊ុនជាងគេ គឺ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលបានធ្វើការបោះផ្សាយចំនួន ២១.៤៤២.៩៩២ ហ៊ុន នៅពេលដែលក្រុមហ៊ុនដែលបានបោះលក់តិចជាងគេគឺ ក្រុមហ៊ុន ផេសចិក (ខេមបូឌា) ម.ក ដែលបានធ្វើការបោះផ្សាយមូលបត្រកម្មសិទ្ធិមានចំនួន ៣.៩៤៥.០០០ ហ៊ុន។

### ៣.៣.៣. ទិន្នន័យសំខាន់ៗនាក់ទងការជួញដូរមូលបត្រកម្មសិទ្ធិ

ទិន្នន័យសំខាន់ៗនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបានដកស្រង់មកតាមត្រីមាសនីមួយៗ ក្នុងឆ្នាំ ២០២១។ ទិន្នន័យទាំងនោះរួមមាន៖

- ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ
- ការជួញដូរតាមប្រភេទវិនិយោគិន (ក្នុងស្រុក និងបរទេស)
- ការជួញដូរតាមប្រភេទវិនិយោគិន (រូបវន្តបុគ្គល និងនីតិបុគ្គល)
- ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ។

#### ៣.៣.៣.១. ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ

**ក្រាហ្វិចទី ៣៖ ទំហំជួញដូរភាគហ៊ុន និងតម្លៃសរុបជាមធ្យមប្រចាំថ្ងៃ ឆ្នាំ២០២១**




**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស ឆ្នាំ២០២១ (មើលឧបសម្ព័ន្ធទី៨)**

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២១៖

- នៅត្រីមាសទី១៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៩០.៧២៤ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ១៤១.១៨២ ដុល្លារសហរដ្ឋអាមេរិច។

- នៅត្រីមាសទី២៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ១៣២.៥៨៥ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ២៥៧.៧០៣ ដុល្លារសហរដ្ឋអាមេរិច។
- នៅត្រីមាសទី៣៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ១១២.៩១១ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ២៥២.២៣០ ដុល្លារសហរដ្ឋអាមេរិច។
- នៅត្រីមាសទី៤៖ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួន ៦២៤.៤២៤ ភាគហ៊ុន ដែលមានតម្លៃប្រហែលនឹង ៤១៤.៤៧៣ ដុល្លារសហរដ្ឋអាមេរិច។

#### ៣.៣.៣.២. ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស)

**ក្រាហ្វិចទី ៤៖ ការជួញដូរតាមប្រភេទវិនិយោគិន(ក្នុងស្រុក និងបរទេស) ឆ្នាំ២០២១**




**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស ឆ្នាំ២០២១ (មើលឧបសម្ព័ន្ធទី៨)**

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២១៖

- នៅត្រីមាសទី១៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.១៣១ នាក់ ជាវិនិយោគិនក្នុងស្រុក និង ៣៦ នាក់ ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី២៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.០០០ នាក់ ជាវិនិយោគិនក្នុងស្រុក និង ៣០ នាក់ ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៣៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.៣០៥ នាក់ ជាវិនិយោគិនក្នុងស្រុក និង ៣០ នាក់ ជាវិនិយោគិនក្រៅស្រុក។
- នៅត្រីមាសទី៤៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៦១៥ នាក់ ជាវិនិយោគិនក្នុងស្រុក និង ៣០ នាក់ ជាវិនិយោគិនក្រៅស្រុក។

### ៣.៣.៣.៣. ការជួញដូរតាមប្រភេទវិនិយោគិន(រូបវ័ន្តបុគ្គល និងនីតិបុគ្គល)

**ក្រាហ្វិចទី ៥៖ការជួញដូរតាមប្រភេទវិនិយោគិន(រូបវ័ន្តបុគ្គល និងនីតិបុគ្គល) ឆ្នាំ២០២១**




**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស ឆ្នាំ២០២១ (មើលឧបសម្ព័ន្ធទី៨)**

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២១៖

- នៅត្រីមាសទី១៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.១៦៦ នាក់ ជារូបវ័ន្តបុគ្គល និង ១ នាក់ ជានីតិបុគ្គល។
- នៅត្រីមាសទី២៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.០២៧ នាក់ ជារូបវ័ន្តបុគ្គល និង ៣ នាក់ ជានីតិបុគ្គល។
- នៅត្រីមាសទី៣៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ១.៣៣២ នាក់ ជារូបវ័ន្តបុគ្គល និង ៣ នាក់ ជានីតិបុគ្គល។
- នៅត្រីមាសទី៤៖ ការជួញដូរតាមប្រភេទវិនិយោគិនមាន ៦៤៥ នាក់ ជារូបវ័ន្តបុគ្គល និង 0 នាក់ ជានីតិបុគ្គល។

### ៣.៣.៣.៤. ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ

**ក្រាហ្វិចទី ៦៖ចំនួនវិនិយោគិនមានសកម្មភាពជួញដូរមូលបត្រកម្មសិទ្ធិ ឆ្នាំ២០២១**




**ប្រភព៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស ឆ្នាំ២០២១ (មើលឧបសម្ព័ន្ធទី៨)**

យោងតាមក្រាបខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០២១៖

- នៅត្រីមាសទី១៖ វិនិយោគិនដែលមានសកម្មភាពដាក់បញ្ជាជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន PWSA មានចំនួន ៤៦៤ នាក់ GTI មានចំនួន ១៩៨ នាក់ PPSP មានចំនួន ៧៧៨ នាក់ PPAP មានចំនួន ២៨៨ នាក់ PAS មានចំនួន ៥៤១ នាក់ ABC មានចំនួន ១.០៦០ នាក់ និងក្រុមហ៊ុន PEPC មានចំនួន ៣២៤ នាក់។
- នៅត្រីមាសទី២៖ វិនិយោគិនដែលមានសកម្មភាពដាក់បញ្ជាជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន PWSA មានចំនួន ៥៤៤ នាក់ GTI មានចំនួន ៩៣ នាក់ PPSP មានចំនួន ១.០៦៧ នាក់ PPAP មានចំនួន ១១៦ នាក់ PAS មានចំនួន ២១២ នាក់ ABC មានចំនួន ៣.៥៤៥ នាក់ និងក្រុមហ៊ុន PEPC មានចំនួន ១១៥ នាក់។
- នៅត្រីមាសទី៣៖ វិនិយោគិនដែលមានសកម្មភាពដាក់បញ្ជាជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន PWSA មានចំនួន ១.០៤៧ នាក់ GTI មានចំនួន ៦៨៦ នាក់ PPSP មានចំនួន ១.៣២៧ នាក់ PPAP មានចំនួន ៤៨៣ នាក់ PAS មានចំនួន ១.០០០ នាក់ ABC មានចំនួន ៥.៥៨៦ នាក់ PEPC មានចំនួន ៦៧៤ នាក់ និងក្រុមហ៊ុន DBDE មានចំនួន ១.០៥៥ នាក់។

- នៅត្រីមាសទី៤៖ វិនិយោគិនដែលមានសកម្មភាពដាក់បញ្ជាជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក្រុមហ៊ុន PWSA មានចំនួន ៨១៤ នាក់ GTI មានចំនួន ៣៨១ នាក់ PPSP មានចំនួន ១.០៦៧ នាក់ PPAP មានចំនួន ៤២១ នាក់ PAS មានចំនួន ៧៩៦ នាក់ ABC មានចំនួន ៣.៩៣៩ នាក់ PEPC មានចំនួន ៤៥៧ នាក់ និងក្រុមហ៊ុន DBDE មានចំនួន ១.០៩៧ នាក់។

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទស្តីពី ដំណើរការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធិនៅកម្ពុជា រួចមក យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនដែលទាក់ទងនឹងវិស័យមូលបត្រ។ និយ័តករមូលបត្រកម្ពុជា គឺជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យមានការជួញដូរមូលបត្រប្រកបទៅដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវនៅក្នុងវិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែក **ផ.ម.ក.** ជាប្រតិបត្តិករទីផ្សារតែមួយគត់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីចម្បងក្នុងការធានាតម្លាភាព និងបង្កើតបរិយាកាសល្អប្រសើរដល់អ្នកចូលរួមក្នុងទីផ្សារ ជាពិសេសការជំរុញ និងការលើកទឹកចិត្តដល់វិនិយោគិន និងក្រុមហ៊ុនក្នុងស្រុក តាមរយៈការបង្កើតឲ្យមានសន្ទនីយភាពទីផ្សារ និងការការពារផលប្រយោជន៍របស់វិនិយោគិនជាតិ និងអន្តរជាតិផងដែរ។ គិតត្រឹមឆ្នាំ២០២១ មានក្រុមហ៊ុនបោះផ្សាយ និងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ចំនួន ៨ ក្រុមហ៊ុន។

ដើម្បីបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងបាន ក្រុមហ៊ុន ត្រូវត្រៀមរៀបចំនូវកិច្ចការមួយចំនួនរួមមាន៖ ការបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់ ពង្រឹងប្រព័ន្ធគណនេយ្យស្របតាមស្តង់ដាគណនេយ្យ រៀបចំអភិបាលកិច្ចសាជីវកម្ម រៀបចំផែនការសម្រាប់ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ រៀបចំឯកសារផ្តល់ព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ព្រមទាំងលក្ខខណ្ឌតម្រូវ និងឯកសារមួយចំនួនតាមការតម្រូវរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា ក្នុងនោះដែរក៏ត្រូវបង្កើតក្រុមការងារបោះផ្សាយ ព្រមទាំងស្វែងយល់ពីដំណើរការ និងយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ចំនួន១២ដំណាក់កាល។

ដោយឡែកចំពោះលក្ខខណ្ឌចាំបាច់ដើម្បីធ្វើការជួញដូរមូលបត្រកម្មសិទ្ធិនៅ **ផ.ម.ក.** បានវិនិយោគិនតម្រូវឱ្យមានលេខអត្តសញ្ញាណវិនិយោគិនពីន.ម.ក និងគណនីជួញដូរពីក្រុមហ៊ុនមូលបត្រ (SF) ណាមួយឬមួយចំនួនដែលខ្លួនពេញចិត្តជាមុនសិន។ ជាបន្ទាប់ វិនិយោគិនគ្រាន់តែស្វែងយល់បន្ថែមអំពីវិធានប្រតិបត្តិការទីផ្សារមូលបត្រ វិធានផាត់ទាត់និងទូទាត់មូលបត្រ និងវិធានរក្សាទុកមូលបត្រ របស់ **ផ.ម.ក.** ដោយផ្តោតសំខាន់លើ ពេលវេលាជួញដូរ វិធីសាស្ត្រជួញដូរ ប្រភេទបញ្ជា ព័ត៌មានលម្អិតពេលដាក់បញ្ជា ឯកតាគម្លាតថ្លៃជួញដូរ ដើម្បីធ្វើការដាក់បញ្ជាជួញដូរក្នុងប្រព័ន្ធរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ហើយត្រូវរង់ចាំការផាត់ទាត់និងទូទាត់របស់ប្រតិបត្តិករផាត់ទាត់និងទូទាត់មូលបត្រ ព្រមទាំងការរក្សាទុកមូលបត្រពីប្រតិបត្តិកររក្សាទុកមូលបត្រផងដែរ។

សរុបសេចក្ដីមក ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិមានលក្ខខណ្ឌតម្រូវ និងឯកសារដែលត្រូវបំពេញច្រើន ប៉ុន្តែក្រុមហ៊ុនអាចទទួលបានមកវិញនៅអត្ថប្រយោជន៍ជាច្រើន ដូចជាទទួលបានប្រភពហិរញ្ញប្បទានរយៈពេលវែង ការលើកទឹកចិត្តផ្នែកពន្ធ និរន្តរភាពអាជីវកម្មជាមួយអភិបាលកិច្ចសាជីវកម្ម ការធ្វើឲ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះ និងសក្តានុពលរបស់ក្រុមហ៊ុន ការបំពេញនូវកាតព្វកិច្ចច្បាប់បានត្រឹមត្រូវ។ ចំពោះប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានលក្ខណៈមិនសូវជាស្មុគស្មាញនោះទេសម្រាប់វិនិយោគិន ដោយវិនិយោគិនគ្រាន់តែស្វែងយល់ពីវិធានប្រតិបត្តិការទីផ្សារ និងចាប់ផ្ដើមរៀនវិនិយោគលើវិស័យនេះពីចំនួនតិចតួចទៅ។

## ២. ការផ្ដល់អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ យើងខ្ញុំយល់ឃើញថា ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ក៏ដូចជាប្រតិបត្តិការជួញដូរនៅផ្សារមូលបត្រកម្ពុជា កំពុងតែរីកចម្រើន ប៉ុន្តែចទន្ទឹមនឹងនេះដែរក៏បានឃើញនូវចំណុចអវិជ្ជមានមួយចំនួន ដែលនិយ័តករមូលបត្រ និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គប្បីតែធ្វើការពិចារណាផងដែរ។ ដើម្បីចូលរួមចំណែកក្នុងការជំរុញសកម្មភាពនៃការបោះផ្សាយ និងជួញដូរមូលបត្រកម្មសិទ្ធឲ្យប្រសើរឡើង យើងខ្ញុំសូមការអនុញ្ញាតផ្ដល់ជាគំនិត និងមតិយោបល់ដូចខាងក្រោម៖

- ដើម្បីជំរុញនូវការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជី និងការវិនិយោគនៅលើទីផ្សារកម្ពុជា និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គួរណាបង្កើតឱ្យមានរង្វាន់លើកទឹកចិត្តសម្រាប់ក្រុមហ៊ុនចុះបញ្ជីជាលើកដំបូង និងវិនិយោគិនដែលបានជួញដូរច្រើន។
- គួរតែលើកទឹកចិត្ត និងបន្តជំរុញបន្ថែមទៀតដល់គ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនឯកជនឲ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈឲ្យបានច្រើន ជាពិសេសបន្តជំរុញឱ្យក្រុមហ៊ុនសហគ្រាសធុនតូច និងមធ្យមតែម្ដង។
- បន្តផ្សព្វផ្សាយ និងបង្កើតជាវេទិកា កម្មវិធីសិក្ខាសាលា កម្មវិធីប្រកួតប្រជែងជួញដូរភាគហ៊ុន និងតាមរយៈកម្មវិធីផ្សេងទៀត ដើម្បីឲ្យក្រុមហ៊ុនបានស្វែងយល់ពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ និងវិនិយោគិនទទួលបានចំណេះដឹងកាន់តែច្បាស់លាស់ មុននឹងឈានចូលប្រឡូកក្នុងវិស័យមួយនេះ។
- អភិវឌ្ឍ App របស់កម្មវិធី Mobile Trading System (MTS) នៅលើទូរសព្ទដៃឱ្យកាន់តែមានភាពងាយស្រួលដល់វិនិយោគិនក្នុងការជួញដូរមូលបត្រកម្មសិទ្ធិ។

# ឯកសារយោង

# ឯកសារយោង

- ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/ រកម/ ១០០៧/ ០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧
- ឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងច្បាប់នេះ (២០០៧)
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ លេខ ០១៧/១៧ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ លេខ ០០៣/១៩ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ លេខ ០០២/២០ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់ លេខ ០១៨/១៧ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ លេខ ០១៩/១៧ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ លេខ ០០៤/២០ គ.ម.ក. / ប្រ.ក. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០
- ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ លេខ ០០៥/១៥ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥
- ប្រកាសស្ដីពីការផ្ដល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ លេខ ០០៩ គ.ម.ក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ២០០៩
- គោលការណ៍ណែនាំលេខ០០១ គ.ម.ក./គ.ណ.ន. ស្ដីពីការផ្ដល់លេខអត្តសញ្ញាណវិនិយោគិន ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២
- គោលការណ៍ណែនាំលេខ ០០២/២០ គ.ម.ក./គ.ណ.ន. ស្ដីពីការផ្ដល់លេខអត្តសញ្ញាណវិនិយោគិនតាមអនឡាញ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០
- គណៈកម្មការមូលបត្រកម្ពុជា មគ្គុទេសក៍ស្ដីពីការស្វែងយល់ពីហិរញ្ញប្បទានតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២០១៧
- និយ័តករមូលបត្រកម្ពុជា ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ ប្រចាំត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០២១

- គណៈកម្មការមូលបត្រកម្ពុជា ព្រឹត្តិបត្រមូលបត្រ ចេញផ្សាយលេខ២ ខែមករា ឆ្នាំ២០១៧
- សួន ចំរើន (២០១៧) ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- បៀន សាំង (២០១១) មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ទីផ្សារមូលបត្រ (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1)
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ (http://csx.com.kh/news/faq/listPosts.do?MNCD=7060#sec1_1)
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះក្រុមហ៊ុនបោះផ្សាយ

  (http://csx.com.kh/kh/product/blisting.jsp?MNCD=3010)
- អត្ថប្រយោជន៍នៃទីផ្សារមូលបត្រចំពោះសេដ្ឋកិច្ចជាតិ (http://www.secc.gov.kh/khmer/faq.php?pn=2)
- គុណវិបត្តិទីផ្សារមូលបត្រក្នុងវិស័យសេដ្ឋកិច្ច (http://www.secc.gov.kh/khmer/faq.php?pn=2)
- ទីស្នាក់ការរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m19.php?pn=1)
- ចក្ខុវិស័យ និងបេសកកម្ម (https://www.serc.gov.kh/khmer/m11.php?pn=1)
- គោលដៅនិងគោលបំណងទូទៅនៃនិយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/faq.php?pn=2)
- រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា (https://www.serc.gov.kh/khmer/m14.php?pn=1)
- ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (http://csx.com.kh/kh/about/profile.jsp?MNCD=10301)
- ក្រុមប្រឹក្សាភិបាលនៃផ.ម.ក (http://www.csx.com.kh/kh/about/director.jsp?MNCD=10303)
- និយ័តករមូលបត្រកម្ពុជា (http://www.csx.com.kh)
- ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ

  (http://www.secc.gov.kh/khmer/m52.php?pn=6)
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(PWSA)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000010004)
- ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណល(GTI)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000020003)
- កំពង់ផែស្វយ័តក្រុងភ្នំពេញ(PPAP)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000040001)
- ក្រុមហ៊ុនភ្នំពេញ អេសអ៊ីហ្សិត ភីអិលស៊ី (PPSP)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000050000)
- កំពង់ផែស្វយ័តក្រុងព្រះសីហនុ(PAS)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000060009)
- ធនាគារអេស៊ីលីដា ភីអិលស៊ី (ABC)

(http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000100003)

- ក្រុមហ៊ុន ផេកចិក (ខេមបូឌា) ម.ក.(PEPC)

  (http://csx.com.kh/jsp/data/lstcomkh_view.jsp?lang=kh&MNCD=5010&issueCode=KH1000140009)
- ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក (https://dbdengineering.com/)
- តួអង្គចូលរួមដទៃទៀត (http://www.secc.gov.kh/khmer/m59.php?pn=6)
- ការបើកគណនីជួញដូរមូលបត្រ គណនីសាច់ប្រាក់ និងគណនីមូលបត្រ

  https://www.serc.gov.kh/khmer/m52.php?pn=6
- ថ្ងៃ និងម៉ោងជួញដូរ http://csx.com.kh/operation/market/listPosts.do?MNCD=3020
- ប្រភេទបញ្ជា http://csx.com.kh/operation/market/listPosts.do?MNCD=30201
- ឯកតាគម្លាតថ្លៃ http://csx.com.kh/operation/stock/listPosts.do?MNCD=30202
- ការដាក់បញ្ជា និងនីតិវិធីក្នុងការជួញដូរ

  http://csx.com.kh/operation/market/listPosts.do?MNCD=30201
- ប្រតិបត្តិការនៃការរក្សាទុកមូលបត្រ http://csx.com.kh/operation/depository/listPosts.do?MNCD=3040

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ

ឧបសម្ព័ន្ធទី២៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារ

ឧបសម្ព័ន្ធទី៣៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តការកែប្រែវិធានប្រតិបត្តិការទីផ្សារ

ឧបសម្ព័ន្ធទី៤៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ

ឧបសម្ព័ន្ធទី៥៖ ប្រកាសស្តីពីការអនុវត្តវិធានការប្រតិបត្តិការរក្សាទុកមូលបត្រ

ឧបសម្ព័ន្ធទី៦៖ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

ឧបសម្ព័ន្ធទី៧៖ ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ

ឧបសម្ព័ន្ធទី៨៖ ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគប្រចាំត្រីមាស ឆ្នាំ២០២១

# ឧបសម្ព័ន្ធទី១៖

# ប្រកាស ស្តីពីការដាក់ឱ្យអនុវត្តវិធាន ប្រតិបត្តិការទីផ្សារមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ ០២៧/១៧ ......គ.ម.ក. /ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០៦/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ, ប្រកាសលេខ ០០១/១៣ គ.ម.ក.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ប្រកាសលេខ ០០៥/១៤ គ.ម.ក.ប្រក ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងប្រការ១ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៨ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ ០០១៣/១៧**
**ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧**

# ស្តីពី
# វិធានប្រតិបត្តិការទីផ្សារមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

វិធាននេះមានគោលបំណងកំណត់ពីវិធីសាស្ត្រ យន្តការ នីតិវិធី និងការគ្រប់គ្រងការជួញដូរមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រម ដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

**- សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា គ.ម.ក.) ហើយជាសមាជិកនៃប្រតិបត្តិករទីផ្សារមូលបត្រ របស់ **ផ.ម.ក.** និងមានសិទ្ធិប្រើប្រាស់នូវប្រព័ន្ធជួញដូរនិងប្រព័ន្ធកុំព្យូទ័រមួយចំនួនទៀតរបស់ **ផ.ម.ក.**។

- **បញ្ជា** សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដោយសមាជិក ដើម្បីធ្វើការជួញដូរមូលបត្រនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃជួញដូរ** សំដៅដល់ថ្ងៃដែលទទួលបានពីការផ្គូផ្គងបញ្ជានៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

- **ថ្ងៃចុងក្រោយ** សំដៅដល់ថ្ងៃជួញដូរចុងក្រោយ ឬថ្ងៃមូលដ្ឋាន ករណីគ្មានថ្ងៃជួញដូរនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃមូលដ្ឋាន** សំដៅដល់ថ្លៃគោលសម្រាប់គណនាដែនកំណត់ថ្លៃក្នុងការជួញដូរមូលបត្រប្រចាំថ្ងៃ។

- **ថ្លៃដុល** (Dirty Price) សំដៅដល់ថ្លៃនៃមូលបត្របំណុល ដែលគិតបញ្ចូលនូវការប្រាក់បង្គរ (Accrued Interest)។

- **ថ្លៃបើក** សំដៅដល់ថ្លៃជួញដូរដំបូងនៃមូលបត្រនៅថ្ងៃជួញដូរនីមួយៗ។

- **ថ្លៃបិទ** សំដៅដល់ថ្លៃដែលត្រូវបានកំណត់នៅពេលបិទទីផ្សារនៅថ្ងៃជួញដូរនីមួយៗ ដូចខាងក្រោម÷

១-ថ្លៃជួញដូរចុងក្រោយ ឬ

២-ថ្លៃពិសេស ឬ

៣-ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ក្នុងករណីគ្មានការជួញដូររហូតដល់ពេលបិទទីផ្សារ និងគ្មានថ្លៃពិសេស នៅថ្ងៃជួញដូរលើកដំបូង ឬ

៤-ថ្លៃមូលដ្ឋាន ក្នុងករណីគ្មានការជួញដូររហូតដល់ម៉ោងបិទទីផ្សារ និងគ្មានថ្លៃពិសេស។

- **ថ្លៃពិសេស** សំដៅដល់ថ្លៃដូចខាងក្រោម ក្នុងករណីមូលបត្រកម្មសិទ្ធិមិនត្រូវបានអនុវត្តការជួញដូររហូតដល់ម៉ោងបិទទីផ្សារ÷

១-ថ្លៃល្អបំផុតនៃសំណើលក់ (Best Ask) ដែលថ្លៃនៃសំណើលក់នេះទាបជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង ឬ

២-ថ្លៃល្អបំផុតនៃសំណើទិញ (Best Bid) ដែលថ្លៃនៃសំណើទិញនេះខ្ពស់ជាងថ្លៃមូលដ្ឋាន ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង សម្រាប់ថ្ងៃជួញដូរលើកដំបូង។

- **ថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង** (IPO Price) សំដៅដល់ថ្លៃមូលបត្រកម្មសិទ្ធិដែលបានកំណត់នៅក្នុងឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាត និងចុះបញ្ជីជាស្ថាពរនៅ **គ.ម.ក.**។

- **មូលបត្រចុះបញ្ជីលក់លើកដំបូង** (Initially Listed Securities) សំដៅដល់មូលបត្រដែលត្រូវបានចុះបញ្ជីសម្រាប់ជួញដូរជាផ្លូវការនៅ **ផ.ម.ក.** បន្ទាប់ពីត្រូវបានបោះផ្សាយលក់ជាសាធារណៈលើកដំបូង។

- **ថ្លៃរំពឹងទុក** (Expected Price) សំដៅដល់ថ្លៃជួញដូររំពឹងទុកដែលទទួលបានពីការផ្គូផ្គងបញ្ជាជាបន្តបន្ទាប់នៅក្នុងអំឡុងវគ្គបើក និងវគ្គបិទ ដោយប្រើវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ។

- **បរិមាណរំពឹងទុក** (Expected Volume) សំដៅដល់បរិមាណមូលបត្រដែលអាចផ្គូផ្គងបានដោយឈរលើមូលដ្ឋាននៃថ្លៃរំពឹងទុក។

- **ប្រតិបត្តិការគណនីអតិថិជន** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្របន្ទាប់ពីបានទទួលការបញ្ជាពីអតិថិជន។

- **ប្រតិបត្តិការគណនីសមាជិក** សំដៅដល់ប្រតិបត្តិការទិញ ឬលក់មូលបត្រសម្រាប់គណនីផ្ទាល់របស់សមាជិក។

- **ប្រព័ន្ធកុំព្យូទ័ររបស់ ផ.ម.ក.** សំដៅដល់ប្រព័ន្ធកុំព្យូទ័រ ដែលប្រតិបត្តិដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. ក្នុងគោលបំណងធ្វើជាអន្តរការីនៃការជួញដូរមូលបត្រ។

- **ប្រព័ន្ធកុំព្យូទ័រសមាជិក** សំដៅដល់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិក ដែលត្រូវបានអនុញ្ញាតឱ្យបញ្ជូនបញ្ជាទៅកាន់ប្រព័ន្ធកុំព្យូទ័ររបស់ **ផ.ម.ក.**។

- **ការជួញដូរមិនប្រក្រតី** សំដៅដល់ការជួញដូរទាំងឡាយដែលក្នុងនោះថ្លៃ ឬបរិមាណនៃការជួញដូរមូលបត្រមានការប្រែប្រួលខុសប្រក្រតីនៅក្នុងទីផ្សារ។

- **ការជួញដូរមិនស្មោះត្រង់** សំដៅដល់ការជួញដូរដែលធ្វើឱ្យថ្លៃទីផ្សារមានការប្រែប្រួលដោយមធ្យោបាយមិនស្មោះត្រង់ដូចជា÷ ការប្រើប្រាស់ព័ត៌មានផ្ទៃក្នុង ការប្រើឧបាយកលក្នុងទីផ្សារ ឬការប្រើប្រាស់ព័ត៌មានដែលមានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស។

- **ការឃ្លាំមើលទីផ្សារ** (Market Watch) សំដៅដល់ការតាមដានសភាពការណ៍ទីផ្សារ តាមរយៈការវិភាគអំពីប្រតិបត្តិការជួញដូរមូលបត្រនៅលើទីផ្សារ ស្ថានភាពនៃបញ្ជា និងព័ត៌មាននានាដែលពាក់ព័ន្ធនឹងឯកសារផ្តល់ព័ត៌មាន ពាក្យចចាមអារ៉ាម និងព័ត៌មានដែលទទួលបានពីប្រភពផ្សេងទៀត ជាដើម។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលរាល់បញ្ជាទិញនិងបញ្ជាលក់ទាំងអស់ ត្រូវផ្គូផ្គងព្រមគ្នានិងជួញដូរនៅថ្លៃតែមួយ។

- **វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន** សំដៅដល់វិធីសាស្ត្រដេញថ្លៃដែលបញ្ជាទិញឬបញ្ជាលក់មួយត្រូវបានផ្គូផ្គង និងអាចជួញដូរនៅថ្លៃច្រើនផ្សេងៗគ្នា។

## ប្រការ ៣.- មូលបត្រដែលអាចជួញដូរបាន

មូលបត្រដែលចុះបញ្ជីលក់នៅ **ផ.ម.ក.** ត្រូវជួញដូរនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដោយគោរពតាមវិធាននេះ។

ការជួញដូរមូលបត្រក្នុងចំណោមសមាជិក ត្រូវបានធ្វើអន្តរការីកម្មដោយប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក.។

## ប្រការ ៤.- ប្រភេទនៃបញ្ជា

**ផ.ម.ក.** អនុញ្ញាតឱ្យមានប្រភេទបញ្ជាដូចខាងក្រោម÷

41

១-បញ្ជាដែនកំណត់ (Limit Order)÷ ជាបញ្ជាដែលមានថ្លៃជាក់លាក់មួយ ដើម្បីទិញឬលក់មូលបត្រនៅថ្លៃជាក់លាក់នោះ ឬនៅថ្លៃប្រសើរជាងថ្លៃជាក់លាក់នោះ។ ថ្លៃប្រសើរជាងថ្លៃជាក់លាក់ គឺជាថ្លៃទាបជាងថ្លៃជាក់លាក់នោះក្នុងករណីទិញ ឬជាថ្លៃខ្ពស់ជាងថ្លៃជាក់លាក់នោះក្នុងករណីលក់។

២-បញ្ជាទីផ្សារ (Market Order)÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រកម្មសិទ្ធិ នៅថ្លៃល្អបំផុតដែលមានក្នុងទីផ្សារ ដោយគោរពតាមប្រការ ១០, ១១ និង១២។ បញ្ជាទីផ្សារមិនត្រូវបានអនុញ្ញាតសម្រាប់ប្រតិបត្តិការផ្តល់សន្ទនីយភាពមូលបត្រ និងការជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។ នៅក្នុងវគ្គនិរន្តរ៍ បញ្ជាទីផ្សារអាចភ្ជាប់លក្ខខណ្ឌណាមួយ ដូចខាងក្រោម÷

ក- លក្ខខណ្ឌជួញដូរទាំងស្រុង ឬលុបចោល (Fill or Kill)÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។

ខ- លក្ខខណ្ឌជួញដូរ ហើយលុបចោល (Fill and Kill)÷ ជាលក្ខខណ្ឌដែលកំណត់ថាបញ្ជានឹងត្រូវលុបចោលភ្លាម ប្រសិនបើបរិមាណនៃបញ្ជានោះមិនត្រូវបានផ្គូផ្គងទាំងស្រុងឬមួយផ្នែកភ្លាមៗ បន្ទាប់ពីត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធជួញដូរ។ ក្នុងករណីដែលបរិមាណនៃបញ្ជានោះត្រូវបានផ្គូផ្គងមួយផ្នែក បញ្ជាដែលមានបរិមាណនៅសល់នោះ នឹងត្រូវលុបចោលភ្លាម។

៣- បញ្ជាតាមការចរចា (Negotiated Order)÷ ជាបញ្ជាដើម្បីទិញឬលក់មូលបត្រ តាមវិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

## ប្រការ ៥.- សុពលភាពនៃបញ្ជា

រាល់បញ្ជានីមួយៗ ត្រូវមានសុពលភាពចាប់ពីពេលដែលទទួលបាននៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ ផ.ម.ក. រហូតដល់ពេលដែលបញ្ជានោះត្រូវបានអនុវត្តការជួញដូរនៅអំឡុងវគ្គជួញដូរនៃថ្ងៃតែមួយ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ សុពលភាពនៃបញ្ជានៃមូលបត្រណាមួយត្រូវបានព្យួរក្នុងករណីដែលការជួញដូរមូលបត្រនោះត្រូវបានព្យួរក្នុងអំឡុងម៉ោងជួញដូរ។

## ប្រការ ៦.- ការកែប្រែ ឬលុបបញ្ជាដែលបានបញ្ជូន

ប្រសិនបើបញ្ជាមិនទាន់ត្រូវបានអនុវត្តការជួញដូរ សមាជិកអាច÷

១-កែប្រែឬលុប ថ្លៃឬបរិមាណនៃបញ្ជាដែនកំណត់។

២- លុបបញ្ជាទីផ្សារ និងបញ្ជាតាមការចរចា។

### ប្រការ ៧.- នីតិវិធីនៃការដាក់បញ្ជា

ក្នុងករណីដែលសមាជិកមួយដាក់បញ្ជាទៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** សមាជិកនោះត្រូវអនុវត្តនីតិវិធីដូចខាងក្រោម÷

១-ពិនិត្យមើលសាច់ប្រាក់ ឬមូលបត្រដែលអតិថិជនមាន ដើម្បីធានាការទូទាត់ ឬការជួញដូរដែលពាក់ព័ន្ធនឹងបញ្ជានោះ។

២-ពិនិត្យព័ត៌មានលម្អិតនៃបញ្ជាដូចមានចែងក្នុងប្រការ ៨ ។

៣-ដាក់បញ្ជាចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

### ប្រការ ៨.- ព័ត៌មានលម្អិតនៃបញ្ជា

បញ្ជាដែលដាក់ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ត្រូវមានព័ត៌មានលម្អិត ដូចខាងក្រោម÷

១-ឈ្មោះមូលបត្រ។

២-បរិមាណ។

៣-ថ្លៃ ករណីក្រៅពីបញ្ជាទីផ្សារ។

៤-លេខកូដជួញដូរតាមការចរចា ចំពោះបញ្ជាតាមការចរចា។

៥-ការបញ្ជាក់ពីបញ្ជា÷ បញ្ជាទិញ ឬបញ្ជាលក់។

៦-ប្រភេទនៃប្រតិបត្តិការ÷ ប្រតិបត្តិការគណនីអតិថិជន ឬប្រតិបត្តិការគណនីសមាជិក។

៧-លេខអត្តសញ្ញាណសមាជិក។

៨-លេខអត្តសញ្ញាណវិនិយោគិន។

៩-លេខបញ្ជា។

១០-លេខគណនីជួញដូរ។

១១-ក្នុងករណីលុបឬកែប្រែបញ្ជា ត្រូវបញ្ជាក់ថាជាការលុបឬជាការកែប្រែ ហើយត្រូវបញ្ជាក់លេខបញ្ជាដើមផងដែរ។

១២-លេខកូដវិនិយោគិន÷ ជារូបវន្តបុគ្គល ឬនីតិបុគ្គល។

១៣-លេខកូដប្រទេសរបស់វិនិយោគិន។

### ប្រការ ៩.- វិធីសាស្ត្រជួញដូរ

រាល់ការជួញដូរត្រូវធ្វើឡើងតាមវិធីសាស្ត្រ ដូចខាងក្រោម÷

១-វិធីសាស្ត្រដេញថ្លៃ (Auction Trading Method)។

២-វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method)។

### ប្រការ ១០.- វិធីសាស្ត្រដេញថ្លៃ

វិធីសាស្ត្រដេញថ្លៃ (Auction Trading Method) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាទិញនិងបញ្ជាលក់ដោយស្វ័យប្រវត្តិ តាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction) ឬវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

អាទិភាពនៃបញ្ជាតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវកំណត់ទៅតាមគោលការណ៍ដូចខាងក្រោម÷

១-បញ្ជាលក់ដែលមានថ្លៃទាបជាង មានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង ហើយបញ្ជាទិញដែលមានថ្លៃខ្ពស់ជាង មានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។

២-ក្នុងករណីបញ្ជាមានថ្លៃដូចគ្នា បញ្ជាដែលទទួលបានមុន មានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។

ទោះបីជាមានចែងក្នុងកថាខណ្ឌទី២នៃប្រការនេះក៏ដោយ អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់តាមរយៈវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវបានកំណត់ដោយឡែក ក្នុងករណីនៃបញ្ជាព្រមពេលគ្នា÷

១-ត្រូវបានចាត់ទុកថាជាបញ្ជាព្រមពេលគ្នា ចំពោះករណីដូចខាងក្រោម÷

ក-រាល់បញ្ជាទិញដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងលើ (ថ្លៃមូលដ្ឋាន +១០%)។

ខ-រាល់បញ្ជាលក់ដែលមានថ្លៃដែលត្រូវផ្គូផ្គងស្មើនឹងដែនកំណត់ថ្លៃខាងក្រោម (ថ្លៃមូលដ្ឋាន -១០%)។

២-ចំពោះបញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី១ នៃកថាខណ្ឌនេះ បញ្ជាសម្រាប់គណនីអតិថិជនមានអាទិភាពលើបញ្ជាសម្រាប់គណនីសមាជិក។ ក្នុងករណីនេះ បញ្ជាដែលមានបរិមាណច្រើនជាងមានអាទិភាពលើបញ្ជាដែលមានបរិមាណតិចជាង។ ក្នុងករណីបញ្ជាមានបរិមាណស្មើគ្នា បញ្ជាដែល **ផ.ម.ក.** ទទួលបានមុនតាមរយៈប្រព័ន្ធជួញដូរត្រូវមានអាទិភាព។

៣-ការបែងចែកបរិមាណមូលបត្រសម្រាប់បញ្ជាព្រមពេលគ្នា ដូចមានចែងនៅក្នុងចំណុចទី២ នៃកថាខណ្ឌនេះ ត្រូវអនុវត្តតាមលំដាប់លំដោយអាទិភាព ដូចខាងក្រោម÷

ក-១០០(មួយរយ) ដង នៃឯកតាជួញដូរ។

ខ-៥០០(ប្រាំរយ) ដង នៃឯកតាជួញដូរ។

គ-១០០០(មួយពាន់) ដង នៃឯកតាជួញដូរ។

ឃ-៥០ (ហាសិប) ភាគរយ នៃបរិមាណដែលនៅសល់។ ក្នុងករណីនេះ ប្រសិនបរិមាណនោះទាបជាងឯកតាជួញដូរ ត្រូវកំណត់យកត្រឹមឯកតាជួញដូរ។

ង-បរិមាណដែលនៅសល់ទាំងអស់ត្រូវផ្តល់ឱ្យតាមអាទិភាព។

**ប្រការ ១១.- វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ**

ថ្លៃដូចខាងក្រោមនេះ ត្រូវកំណត់យកដោយប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ (Single Price Auction)៖

១-ថ្លៃបើក។

២-ថ្លៃជួញដូរលើកដំបូងនៃមូលបត្រចុះបញ្ជីលក់លើកដំបូង។

៣-ថ្លៃបើកក្រោយពេលបើកទីផ្សារឡើងវិញ បន្ទាប់ពីបិទទីផ្សារបណ្តោះអាសន្ន ឬព្យួរការជួញដូររយៈពេលយូរ។

៤-ថ្លៃក្រោយពេលចាប់ផ្តើមការជួញដូរឡើងវិញ បន្ទាប់ពីផ្អាកការជួញដូរ។

៥-ថ្លៃនៅពេលបិទទីផ្សារ។

ករណីប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ បញ្ជាទីផ្សារដែលបានដាក់ត្រូវចាត់ទុកថាមានថ្លៃណាមួយ ដូចខាងក្រោម៖

១-ក្នុងករណីមានតែបញ្ជាទីផ្សារទិញ និងបញ្ជាទីផ្សារលក់ ថ្លៃត្រូវបានកំណត់ដូចខាងក្រោម៖

ក-ថ្លៃចុងក្រោយ ប្រសិនបើបរិមាណខាងទិញស្មើបរិមាណខាងលក់។

ខ-ថ្លៃចុងក្រោយបូកមួយឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ ប្រសិនបើបរិមាណខាងទិញច្រើនជាងបរិមាណខាងលក់។

គ-ថ្លៃចុងក្រោយដកមួយឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោម ប្រសិនបើបរិមាណខាងទិញតិចជាងបរិមាណខាងលក់។

២-ចំពោះករណីផ្សេងទៀតក្រៅពីចំណុចទី១នៃកថាខណ្ឌនេះ ថ្លៃនៃបញ្ជាទីផ្សារទិញគឺជាថ្លៃដែលខ្ពស់ជាងគេក្នុងចំណោមថ្លៃខាងក្រោម៖

ក-ថ្លៃចុងក្រោយ។

ខ-ថ្លៃដែលស្ថិតនៅមួយឯកតាគម្លាតថ្លៃខ្ពស់ជាងថ្លៃនៃបញ្ជាដែនកំណត់ទិញដែលខ្ពស់បំផុតដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ។

គ-ថ្លៃនៃបញ្ជាដែនកំណត់លក់ដែលខ្ពស់បំផុត។

៣-ចំពោះករណីផ្សេងទៀតក្រៅពីចំណុចទី១នៃកថាខណ្ឌនេះ ថ្លៃនៃបញ្ជាទីផ្សារលក់គឺជាថ្លៃដែលទាបជាងគេក្នុងចំណោមថ្លៃខាងក្រោម៖

ក-ថ្លៃចុងក្រោយ។

ខ-ថ្លៃដែលស្ថិតនៅមួយឯកតាគម្លាតថ្លៃទាបជាងថ្លៃនៃបញ្ជាដែនកំណត់លក់ដែលទាបបំផុត ដែលត្រូវ ស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោម។

គ-ថ្លៃនៃបញ្ជា ដែនកំណត់ទិញដែលទាបបំផុត។

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ត្រូវអនុវត្តតាមថ្លៃកំណត់មួយ ដែលហៅថា ថ្លៃជួញដូរ (Trading Price) ដែលត្រូវកំណត់ដូចខាងក្រោម÷

១-ក្នុងករណី "ថ្លៃផ្គូផ្គង" (Matching Price) មានតែមួយ ថ្លៃជួញដូរគឺជាថ្លៃផ្គូផ្គង ដែលនៅថ្លៃនោះ បរិមាណសរុបនៃបញ្ជាលក់ត្រូវបានផ្គូផ្គងនឹងបរិមាណសរុបនៃបញ្ជាទិញ ដោយអនុវត្តទៅតាមលំដាប់នៃ អាទិភាពដូចខាងក្រោម÷

ក-អាទិភាពទី ១÷ បរិមាណសរុបនៃបញ្ជាលក់ដែលមានថ្លៃទាបជាងថ្លៃផ្គូផ្គង និងបរិមាណសរុប នៃបញ្ជាទិញដែលមានថ្លៃខ្ពស់ជាងថ្លៃផ្គូផ្គង។

ខ-អាទិភាពទី ២÷ក្នុងករណីដែលបញ្ជាលក់ និងបញ្ជាទិញត្រូវបានដាក់នៅចំថ្លៃផ្គូផ្គង បរិមាណ មូលបត្រត្រូវបានផ្គូផ្គងដូចខាងក្រោម÷

-បរិមាណសរុបនៃបញ្ជាលក់ ឬបរិមាណសរុបនៃបញ្ជាទិញនោះ និង

-ចាប់ពី ១ (មួយ)ឯកតាមូលបត្រនៃបញ្ជាម្ខាងទៀត។

២-ក្នុងករណីដែលមានចំនួនថ្លៃផ្គូផ្គងលើសពី ១ (មួយ) ថ្លៃជួញដូរត្រូវបានជ្រើសរើសក្នុងចំណោម ថ្លៃដូចខាងក្រោម÷

ក-ថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅថ្ងៃជួញដូរដំបូង ប្រសិនបើមានថ្លៃផ្គូផ្គងណាមួយស្មើនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើក ដំបូងនេះ។

ខ-ថ្លៃដែលនៅកៀកជាងគេធៀបនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈ លើកដំបូងនៅថ្ងៃជួញដូរដំបូង ប្រសិនបើគ្មានថ្លៃផ្គូផ្គងណាដែលស្មើនឹងថ្លៃចុងក្រោយ ឬថ្លៃបោះផ្សាយលក់ មូលបត្រជាសាធារណៈលើកដំបូងនេះ។

## **ប្រការ ១២.- វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន**

ថ្លៃផ្សេងទៀតក្រៅពីថ្លៃដែលចែងនៅក្នុងកថាខណ្ឌទី១ នៃប្រការ១១ ត្រូវកំណត់តាមវិធីសាស្ត្រដេញ ថ្លៃដោយយកថ្លៃច្រើន (Multiple Price Auction)។

ក្នុងករណីដែលថ្លៃត្រូវបានកំណត់ស្របតាមកថាខណ្ឌទី១ បញ្ជាទីផ្សារដែលបានដាក់ត្រូវចាត់ទុកថាមានថ្លៃណាមួយដូចខាងក្រោម រហូតដល់បរិមាណបញ្ជាសរុបត្រូវបានផ្គូផ្គងអស់÷

១-ថ្លៃខ្ពស់ជាងគេក្នុងចំណោមថ្លៃខាងក្រោម ករណីបញ្ជាទីផ្សារទិញ÷

ក-ថ្លៃចុងក្រោយ នៅពេលគ្មានបញ្ជាដែនកំណត់ទិញ ឬថ្លៃបញ្ជាដែនកំណត់ទិញដែលខ្ពស់បំផុតបូក ១ (មួយ)ឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងលើ នៅពេលមានបញ្ជាដែនកំណត់ទិញ។

ខ-ថ្លៃនៃបញ្ជាដែនកំណត់លក់ដែលខ្ពស់បំផុត។

២-ថ្លៃទាបជាងគេក្នុងចំណោមថ្លៃខាងក្រោម ចំពោះករណីបញ្ជាទីផ្សារលក់÷

ក-ថ្លៃចុងក្រោយ នៅពេលគ្មានបញ្ជាដែនកំណត់លក់ ឬថ្លៃនៃបញ្ជាដែនកំណត់លក់ដែលទាបបំផុតដក ១ (មួយ)ឯកតាគម្លាតថ្លៃ ដែលត្រូវស្ថិតក្នុងដែនកំណត់ថ្លៃខាងក្រោម នៅពេលមានបញ្ជាដែនកំណត់លក់។

ខ-ថ្លៃនៃបញ្ជាដែនកំណត់ទិញដែលទាបបំផុត។

ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ត្រូវគោរពតាមអាទិភាពនៃបញ្ជាដូចដែលបានចែងនៅកថាខណ្ឌទី២ នៃប្រការ១០ ហើយការជួញដូរត្រូវអនុវត្តនៅថ្លៃនៃបញ្ជាដែលទទួលបានមុន នៅពេលដែលថ្លៃទិញខ្ពស់បំផុតផ្គូផ្គងជាមួយថ្លៃលក់ទាបបំផុត។

## ប្រការ ១៣.- វិធីសាស្ត្រជួញដូរតាមការចរចា

វិធីសាស្ត្រជួញដូរតាមការចរចា (Negotiated Trading Method) គឺជាវិធីសាស្ត្រផ្គូផ្គងបញ្ជាតាមការចរចាទិញនិងលក់មួយគូ បន្ទាប់ពីភាគីទាំងពីរបានចរចា និងព្រមព្រៀងលើលក្ខខណ្ឌទាំងឡាយនៃការជួញដូរ។

ការជួញដូរដែលបានព្រមព្រៀងដូចបានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ មានអានុភាពលុះត្រាតែបញ្ជាជួញដូរតាមការចរចាត្រូវបានដាក់មកប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** និងផ្គូផ្គងដោយជោគជ័យ។

បញ្ជាជួញដូរតាមការចរចាទាំងសងខាង ត្រូវមានព័ត៌មានលម្អិតដូចគ្នាទាំងស្រុងគឺ ឈ្មោះមូលបត្របរិមាណ ថ្លៃ និងលេខកូដជួញដូរតាមការចរចា។

## ប្រការ ១៤.- ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្តើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីការងារ។

ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ១១:៣០នាទី ព្រឹក ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម÷

| **វគ្គ** | **ម៉ោងទទួលបញ្ជា** | **ម៉ោងអនុវត្តការជួញដូរ** | **វិធីសាស្ត្រ** |
|---|---|---|---|
| វគ្គបើក | ៨:០០ - ៩:០០ | ៩:០០ | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ - ១១:០០ | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១១:០០ - ១១:៣០ | ១១:៣០ | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្ទៀងផ្ទាត់បញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្ទៀងផ្ទាត់នៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្តើមពីម៉ោង ៩:០០នាទី ព្រឹកដល់ម៉ោង ១១:៣០នាទី ព្រឹក។

## ជំពូកទី ២
## លក្ខខណ្ឌនៃការជួញដូរមូលបត្រកម្មសិទ្ធិ

### ប្រការ ១៥.- ឯកតាបញ្ជា បញ្ជាអប្បបរមា និងឯកតាគម្លាតថ្លៃ

ឯកតាបញ្ជាគឺ ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រដេញថ្លៃ ឯកតាគម្លាតថ្លៃត្រូវកំណត់ដូចខាងក្រោម÷

១- ១០ (ដប់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃទាបជាង ៤.០០០ (បួនពាន់)រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

២- ២០ (ម្ភៃ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤.០០០ (បួនពាន់) រៀល ប៉ុន្តែទាបជាង ២០.០០០(ពីរម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៣- ៥០ (ហាសិប) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ២០.០០០ (ពីរម៉ឺន) រៀល ប៉ុន្តែទាបជាង ៤០.០០០(បួនម៉ឺន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៤- ១០០ (មួយរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ៤០.០០០ (បួនម៉ឺន) រៀល ប៉ុន្តែទាបជាង ១០០.០០០(មួយសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៥- ២០០ (ពីររយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ១០០.០០០ (មួយសែន) រៀល ប៉ុន្តែទាបជាង ២០០.០០០(ពីរសែន) រៀល ក្នុង ១ (មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៦- ៥០០ (ប្រាំរយ) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើឬខ្ពស់ជាង ២០០.០០០ (ពីរសែន) រៀល ប៉ុន្តែទាបជាង ៤០០.០០០(បួនសែន) រៀល ក្នុង ១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

៧- ១.០០០ (មួយពាន់) រៀល ចំពោះមូលបត្រកម្មសិទ្ធិដែលមានថ្លៃស្មើ ឬខ្ពស់ជាង ៤០០.០០០ (បួនសែន) រៀល ក្នុង ១(មួយ) ឯកតាមូលបត្រកម្មសិទ្ធិ។

សម្រាប់ការជួញដូរមូលបត្រកម្មសិទ្ធិតាមវិធីសាស្ត្រជួញដូរតាមការចរចា បញ្ញាអប្បបរមាគឺ ៥០.០០០ (ប្រាំម៉ឺន) ឯកតាមូលបត្រកម្មសិទ្ធិ ឬ២០០.០០០.០០០ (ពីររយលាន) រៀល យកមួយណាដែលតូចជាង ហើយឯកតាគម្លាតថ្លៃ គឺ ១(មួយ)រៀល។

**ប្រការ ១៦.- ថ្លៃមូលដ្ឋាន**

ថ្លៃមូលដ្ឋានសម្រាប់ការជួញដូរមូលបត្រចុះបញ្ជីលក់លើកដំបូង សំដៅដល់ថ្លៃជួញដូរដំបូងដែលត្រូវបានកំណត់នៅចន្លោះពី ៩០% (កៅសិបភាគរយ) ទៅ ១៥០% (មួយរយហាសិបភាគរយ) នៃថ្លៃបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។

ថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ ត្រូវកំណត់ដូចខាងក្រោមលើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយ **គ.ម.ក.**÷

១-ក្រៅពីថ្លៃមូលដ្ឋានរបស់មូលបត្រកម្មសិទ្ធិដូចមានក្នុងចំនុច ២ ដល់ ៤ ខាងក្រោម ថ្លៃមូលដ្ឋាននៃមូលបត្រកម្មសិទ្ធិសម្រាប់ថ្ងៃជួញដូរនីមួយៗ គឺជាថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ។

២-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលបានចែកភាគលាភជាមូលបត្រកម្មសិទ្ធិ ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

| |
|---|
| **ចំណាំ**÷មូលធនូបនីយកម្មទីផ្សារមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ = ថ្លៃបិទ x ចំនួនមូលបត្រកម្មសិទ្ធិមុនបែងចែកភាគលាភជាមូលបត្រកម្មសិទ្ធិ |

៣-ក្នុងករណីមានការបង្កើនដើមទុនតាមរយៈការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| [មូលធនូបនីយកម្មទីផ្សារមុនបង្កើនដើមទុន + (ថ្លៃមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ x ចំនួនមូលបត្រកម្មសិទ្ធិដែលបានបោះផ្សាយលក់បន្ថែម)] / ចំនួនមូលបត្រកម្មសិទ្ធិបន្ទាប់ពីបង្កើនដើមទុន |

៤-ក្នុងករណីមូលបត្រកម្មសិទ្ធិដែលមានការបម្លែង (ការបំបែក ការបង្រួម ឬកាត់បន្ថយដើមទុនមូលបត្រកម្មសិទ្ធិ) ថ្លៃមូលដ្ឋានគឺជាថ្លៃដែលទទួលបានតាមរូបមន្តដូចខាងក្រោម÷

| |
|---|
| ថ្លៃបិទនៃថ្ងៃជួញដូរចុងក្រោយ x អនុបាតបម្លែង (Split Ratio) (អនុបាតបម្លែង = ចំនួនមូលបត្រកម្មសិទ្ធិមុនបម្លែង / ចំនួនមូលបត្រកម្មសិទ្ធិក្រោយបម្លែង) |

ក្នុងករណីថ្លៃមូលបត្រដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ទាបជាងឯកតាគម្លាតថ្លៃ នោះថ្លៃមូលដ្ឋានត្រូវកំណត់ស្មើនឹងឯកតាគម្លាតថ្លៃ។

## ប្រការ ១៧.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ដែនកំណត់ថ្លៃប្រចាំថ្ងៃ សម្រាប់មូលបត្រកម្មសិទ្ធិជួញដូរតាមវិធីសាស្ត្រដេញថ្លៃ ត្រូវស្មើនឹងថ្លៃមូលដ្ឋាន ±១០%(បូកឬដកដប់ភាគរយ) ដោយតម្លៃ ១០% នៃថ្លៃមូលដ្ឋានត្រូវបង្គត់ចុះតាមឯកតាគម្លាតថ្លៃមុននឹងយកទៅបូកឬដកថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០ (មួយរយ) រៀល ដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់ នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ **គ.ម.ក.** **ផ.ម.ក.** អាចកំណត់យកដែនកំណត់ថ្លៃប្រចាំថ្ងៃផ្សេងពីនេះក្នុងករណីដូចខាងក្រោម÷

១-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ។

២-ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣-ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់ថ្លៃប្រចាំថ្ងៃ។

ដែនកំណត់ថ្លៃប្រចាំថ្ងៃ មិនត្រូវអនុវត្តចំពោះវិធីសាស្ត្រជួញដូរតាមការចរចា។

## ប្រការ ១៨.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.**÷ ក្នុងករណីនេះ **ផ.ម.ក.** ត្រូវធ្វើការកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់ដែលបណ្តាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវធ្វើការកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្តីថ្លែងដែលបញ្ជាក់ពីមូលហេតុ ឬឯកសារភស្តុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់នៃថ្ងៃជួញដូរបន្ទាប់។

## ជំពូកទី ៣
## លក្ខខណ្ឌនៃការជួញដូរមូលបត្របំណុល

### ប្រការ ១៩.- វិធីសាស្ត្រកំណត់ថ្លៃជួញដូរមូលបត្របំណុល

ថ្លៃជួញដូរមូលបត្របំណុលត្រូវកំណត់តាមវិធីសាស្ត្រដេញថ្លៃ និងវិធីសាស្ត្រជួញដូរតាមការចរចាដូចមានចែងក្នុងជំពូកទី១នៃវិធាននេះ លើកលែងតែករណីមានថ្លៃផ្គូផ្គងចាប់ពីពីរឡើងនៅក្នុងការដេញថ្លៃដោយយកថ្លៃតែមួយ ថ្លៃជួញដូរគឺជាមធ្យមនព្វន្តនៃថ្លៃផ្គូផ្គងខ្ពស់បំផុតនិងថ្លៃផ្គូផ្គងទាបបំផុត។ ក្នុងករណីថ្លៃទទួលបានពីការគណនានេះមិនចំនឹងឯកតាគម្លាតថ្លៃ ថ្លៃជួញដូរត្រូវបង្គត់ឡើងតាមឯកតាគម្លាតថ្លៃ។

### ប្រការ ២០.- ឯកតាបញ្ជា បញ្ជាអតិបរមា ឯកតាគម្លាតថ្លៃ និងថ្លៃបញ្ជា

ឯកតាបញ្ជានៃមូលបត្របំណុលគឺ ១ (មួយ) ឯកតាមូលបត្របំណុល។

បញ្ជាអតិបរមាសម្រាប់ការជួញដូរតាមវិធីសាស្ត្រដេញថ្លៃគឺ ១០.០០០ (មួយម៉ឺន) ឯកតាមូលបត្របំណុល។

ឯកតាគម្លាតថ្លៃគឺ ១ (មួយ) រៀល។

សម្រាប់ការជួញដូរមូលបត្របំណុល ថ្លៃបញ្ជា និងថ្លៃជួញដូរគឺជាថ្លៃដុល។

### ប្រការ ២១.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ

ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវអនុវត្តចំពោះការជួញដូរមូលបត្របំណុល។

## ជំពូកទី ៤
## ការគ្រប់គ្រងទីផ្សារ

### ប្រការ ២២.- ការផ្សាយជាសាធារណៈនូវព័ត៌មានទីផ្សារ

ផ.ម.ក. ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យទីផ្សារដូចខាងក្រោម÷

១-ថ្លៃបើក និង ថ្លៃបិទ។

២-បរិមាណ និង តម្លៃសរុបនៃការជួញដូរ។

៣-ថ្លៃរំពឹងទុក និង បរិមាណរំពឹងទុក។

ផ.ម.ក. អាចធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានផ្សេងទៀតដែលមានប្រយោជន៍សម្រាប់ការសម្រេចចិត្តវិនិយោគ ដើម្បីការពារផលប្រយោជន៍វិនិយោគិន។

### ប្រការ ២៣.- ព័ត៌មានដែលត្រូវជូនដំណឹងទៅសមាជិក

ផ.ម.ក. ត្រូវជូនដំណឹងទៅសមាជិករបស់ខ្លួននូវព័ត៌មាននីមួយៗដូចខាងក្រោម÷

១-វិធានប្រតិបត្តិការរបស់ ផ.ម.ក. និងវិសោធនកម្មដែលអាចកើតមាន។

២-មូលបត្រចុះបញ្ជីលក់លើកដំបូង មូលបត្រចុះបញ្ជីលក់បន្ថែម មូលបត្រដកចេញពីការចុះបញ្ជីលក់ និងមូលបត្រដែលត្រូវបានព្យួរការជួញដូរ។

៣-ការបិទទីផ្សារជាបណ្តោះអាសន្ន ការផ្អាកដំណើរការទីផ្សារ និងការផ្លាស់ប្តូរម៉ោងជួញដូរ។

៤-សមាជិកដែលត្រូវបានអនុញ្ញាត ឬសមាជិកដែលបានដកខ្លួនពីសមាជិកភាព ឬត្រូវបានដកចេញពីសមាជិកភាព។

៥-សមាជិកដែលត្រូវបានព្យួរពីការជួញដូរ និងការអនុញ្ញាតឱ្យជួញដូរឡើងវិញ។

៦-ព័ត៌មានលម្អិតនៃការជួញដូររួមមាន÷ ឈ្មោះមូលបត្រ បរិមាណនិងថ្លៃជួញដូរ ប្រភេទបញ្ជាទិញ ឬលក់ប្រតិបត្តិការសម្រាប់គណនីសមាជិក ឬគណនីអតិថិជន។

ផ.ម.ក. ត្រូវរក្សាទុករាល់ព័ត៌មានទាក់ទងនឹងបញ្ជា ការកែតម្រូវកំហុសប្រតិបត្តិការ និងព័ត៌មានលម្អិតលើការជួញដូរសម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ។

### ប្រការ ២៤.- ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់សមាជិក

សមាជិកទាំងអស់ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យារបស់ខ្លួន ដោយអនុលោមទៅតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងវិធាននេះ។

### ប្រការ ២៥.- កាលបរិច្ឆេទអិចឌីវីដឹនដ៍ ឬអិចរាយថ៍

កាលបរិច្ឆេទអិចឌីវីដឹនដ៍ (Ex-Dividend) ឬអិចរាយថ៍ (Ex-Right) គឺកាលបរិច្ឆេទជួញដូរនៅរយៈកាល ១ (មួយ) ថ្ងៃ មុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលបានភាគលាភ ឬសិទ្ធិ (Record Date)។

### ប្រការ ២៦.- អ្នកតំណាងនៅក្នុងទីផ្សារ

សមាជិកនីមួយៗត្រូវតែងតាំងអ្នកតំណាងនៅក្នុងទីផ្សារយ៉ាងហោចណាស់ ១ (មួយ) រូប ដែលនឹងត្រូវបណ្តុះបណ្តាលដោយ **ផ.ម.ក.** ដើម្បីប្រើប្រាស់ប្រព័ន្ធជួញដូររបស់ប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** ដែលរៀបចំសម្រាប់សមាជិក។ **ផ.ម.ក.** អាចតម្រូវឱ្យអ្នកតំណាងនោះ មកធ្វើការនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.** ក្នុងករណីចាំបាច់។

សមាជិកនីមួយៗ ត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះអ្នកតំណាងនៅក្នុងទីផ្សាររបស់ខ្លួននៅ **ផ.ម.ក.**។ មានតែអ្នកតំណាងនៅក្នុងទីផ្សារទេ ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធកុំព្យូទ័ររបស់សមាជិកដែលស្ថិតនៅក្នុងបន្ទប់ជួញដូររបស់ **ផ.ម.ក.**។

### ប្រការ ២៧.- ថ្លៃសេវាជួញដូរមូលបត្រ

សមាជិកត្រូវបង់ថ្លៃសេវាប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងសេវាដែលបានផ្តល់ឱ្យស្របតាមវិធាននេះ។

របៀបគណនាប្រាក់ថ្លៃសេវាជួញដូរ អ្នកបង់ប្រាក់ និងពេលវេលាបង់ប្រាក់ត្រូវបានកំណត់ដូចខាងក្រោម÷

១-អត្រា÷ ប្រាក់ថ្លៃសេវាសម្រាប់ជួញដូរមូលបត្រ ត្រូវគណនាលើទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ (ប្រាក់ថ្លៃសេវាដែលគណនាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស) តាមអត្រា ៧,៥/១០.០០០ ឬ ០,០៧៥% (សូន្យក្បៀសសូន្យចិតសិបប្រាំភាគរយ) សម្រាប់មូលបត្រកម្មសិទ្ធិ និងតាមអត្រា ២,៥/១០.០០០ ឬ ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) សម្រាប់មូលបត្របំណុល។

២-អ្នកត្រូវបង់ប្រាក់÷ ក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ **ផ.ម.ក.**។

៣-ពេលវេលាបង់ប្រាក់÷ ម៉ោង ៨:៣០នាទី ព្រឹក នៃកាលបរិច្ឆេទទូទាត់។

## ជំពូកទី ៥
## ការតាមដានការជួញដូរមូលបត្រ

### ប្រការ ២៨.- យន្តការបង្ការរបស់ ន.ម.ក.

ដើម្បីធានាបាននូវបរិស្ថានជួញដូរដែលមានយុត្តិធម៌ និងការពារវិនិយោគិន ន.ម.ក. អាចដាក់ចេញនូវយន្តការបង្ការមួយចំនួនដើម្បីទប់ស្កាត់ការជួញដូរមូលបត្រមិនស្មោះត្រង់ ឬមិនប្រក្រតី។

### ប្រការ ២៩.- ការឃ្លាំមើលទីផ្សារ

ន.ម.ក. ធ្វើការឃ្លាំមើលទីផ្សារ ដើម្បីកំណត់អត្តសញ្ញាណមូលបត្រដែលជាប់សង្ស័យថាមានការជួញដូរមិនប្រក្រតី ដោយប្រើប្រាស់នូវព័ត៌មានមួយចំនួនដូចជា របៀបនៃការជួញដូរ បម្រែបម្រួលថ្លៃ ទំហំនៃការជួញដូរ ព្រមទាំងកម្រិតនៃទំនាក់ទំនងរវាងថ្លៃទីផ្សារនិងការជួញដូរ និងព័ត៌មានលម្អិតនៃពាក្យចចាមអារ៉ាម។

* * *

# ឧបសម្ព័ន្ធទី២៖

# ប្រកាស ស្ដីពីការដាក់ឱ្យអនុវត្តនូវ

# ការកែប្រែវិធានប្រតិបត្តិការទីផ្សារ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខៈ..០០៣/១៩...គ.ម.ក./ប្រ.ក.

## ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
E-mail : info@secc.gov.kh
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៤ ថ្មី និងប្រការ១៨ ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៤ និងប្រការ១៨ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..[illegible]...ខែ..[illegible]..ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ០០៣.១៩ / គ.ម.ក.**

**ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០១៩**

**ស្ដីពី**

**ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

---

### ប្រការ១៤ ថ្មី.- ថ្ងៃ និងម៉ោងជួញដូរ

ថ្ងៃជួញដូរចាប់ផ្ដើមពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ ដោយអនុលោមតាមច្បាប់ស្ដីពីការងារ។

ម៉ោងជួញដូរចាប់ផ្ដើមពីម៉ោង ៨:០០នាទី ព្រឹក រហូតដល់ម៉ោង ១៥:០០នាទី រសៀល ដែលបែងចែកជាបីវគ្គដោយឈរលើមូលដ្ឋាននៃវិធីសាស្ត្រនៃការដេញថ្លៃ ដូចខាងក្រោម÷

| វគ្គ | ម៉ោងទទួលបញ្ជា | ម៉ោងអនុវត្តការជួញដូរ | វិធីសាស្ត្រ |
|---|---|---|---|
| វគ្គបើក | ៨:០០ ព្រឹក - ៩:០០ ព្រឹក | ៩:០០ ព្រឹក | ដេញថ្លៃដោយយកថ្លៃតែមួយ |
| វគ្គនិរន្តរ៍ | ៩:០០ ព្រឹក - ១៤:៥០ រសៀល | | ដេញថ្លៃដោយយកថ្លៃច្រើន |
| វគ្គបិទ | ១៤:៥០ រសៀល - ១៥:០០ រសៀល | ១៥:០០ រសៀល | ដេញថ្លៃដោយយកថ្លៃតែមួយ |

ប្រសិនមិនមានការផ្គូផ្គងបញ្ជានៅម៉ោង ៩:០០នាទី ព្រឹក វគ្គបើកនឹងត្រូវពន្យាររហូតដល់មានការផ្គូផ្គងនៅក្នុងថ្ងៃដដែល។

ចំពោះវិធីសាស្ត្រជួញដូរតាមការចរចា÷ ម៉ោងជួញដូរចាប់ផ្ដើមពីម៉ោង ៩:០០នាទី ព្រឹក ដល់ម៉ោង ១៥:០០នាទី រសៀល។

### ប្រការ១៨ ថ្មី.- ការកែតម្រូវលើកំហុសប្រតិបត្តិការជួញដូរ

ក្នុងករណីដែល **ផ.ម.ក.** មានកំហុសឆ្គងក្នុងដំណើរការធ្វើអន្តរការីកម្មនៃការជួញដូរមូលបត្រកម្មសិទ្ធិ ឬក្នុងករណីដែលសមាជិកណាមួយមានកំហុសឆ្គងក្នុងដំណើរការដាក់បញ្ជាដែនកំណត់ ឬបញ្ជាទីផ្សារពាក់ព័ន្ធនឹងមូលបត្រកម្មសិទ្ធិ ព័ត៌មានលម្អិតអំពីការជួញដូរនេះអាចកែតម្រូវបាន។

កំហុសប្រតិបត្តិការត្រូវបានចាត់ថ្នាក់ជា÷ កំហុសរបស់ **ផ.ម.ក.** ឬកំហុសរបស់សមាជិក។

**ផ.ម.ក.** ត្រូវកែតម្រូវលើកំហុសប្រតិបត្តិការតាមវិធីសាស្ត្រដូចខាងក្រោម÷

១-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់ **ផ.ម.ក.**÷ ក្នុងករណីនេះ **ផ.ម.ក.** ត្រូវកែតម្រូវដោយយោងតាមព័ត៌មានដើមនៃបញ្ជា ហើយតម្រូវឱ្យសមាជិកដែលបានបញ្ជូនបញ្ជានោះទទួលយកការជួញដូរមូលបត្រដែលពាក់ព័ន្ធសម្រាប់គណនីផ្ទាល់របស់ខ្លួន។ ក្នុងករណីដែលមានការខាតបង់បណ្ដាលមកពីការកែតម្រូវនេះ **ផ.ម.ក.** ត្រូវធ្វើការប៉ះប៉ូវឱ្យសមាជិកនោះវិញ។

២-ក្នុងករណីជាកំហុសប្រតិបត្តិការរបស់សមាជិក÷ កំហុសឆ្គងត្រូវកែតម្រូវ បន្ទាប់ពីសមាជិកនោះទទួលយកការជួញដូរដែលមានកំហុសជាប្រតិបត្តិការផ្ទាល់របស់ខ្លួន។ ក្នុងករណីនេះ សមាជិកដែលពាក់ព័ន្ធត្រូវដាក់ពាក្យស្នើសុំកែតម្រូវលើកំហុសប្រតិបត្តិការ និងភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងដែលបញ្ជាក់ពីមូលហេតុឬឯកសារភស្ដុតាង ផ្ញើជូន **ផ.ម.ក.** ឱ្យបានមុនម៉ោង ១៥:៣០នាទីរសៀលនៃថ្ងៃជួញដូរបន្ទាប់។

* * *



4

# ឧបសម្ព័ន្ធទី៣៖

# ប្រកាស ស្តីពីការដាក់ឱ្យអនុវត្តការ

# កែប្រែវិធានប្រតិបត្តិការទីផ្សារ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:.....០០៧/២០.....គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្ដីពី
## ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
E-mail : info@secc.gov.kh
Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំអនុម័តលើវិសោធនកម្មនៃវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារ-មូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩។

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៧ ថ្មី នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រ-កម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៧ នៃវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៧/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្រ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្ដេច លោកជំទាវ ឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ..០០៧/២០២០ / ក្រ.ន.ក.**

**ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០២០**

**ស្តីពី**

**ការកែប្រែវិធានប្រតិបត្តិការទីផ្សារមូលបត្រ**

**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

**ប្រការ១៧ ថ្មី.- ដែនកំណត់ថ្លៃប្រចាំថ្ងៃ**

ដែនកំណត់ថ្លៃប្រចាំថ្ងៃ សម្រាប់មូលបត្រកម្មសិទ្ធិ ត្រូវស្មើនឹងថ្លៃមូលដ្ឋាន ±១០% (បូកឬដកដប់ភាគរយ) ដោយតម្លៃ១០% នៃថ្លៃមូលដ្ឋានត្រូវបង្គត់ចុះតាមឯកតាគម្លាតថ្លៃមុននឹងយកទៅបូកឬដកនឹងថ្លៃមូលដ្ឋាន។ ក្នុងករណីថ្លៃមូលដ្ឋានទាបជាង ១០០ (មួយរយ) រៀល ដែនកំណត់ថ្លៃប្រចាំថ្ងៃគឺស្មើនឹង ១០ (ដប់) រៀល។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ដែនកំណត់ថ្លៃប្រចាំថ្ងៃមិនត្រូវបានកំណត់ទេចំពោះមូលបត្រកម្មសិទ្ធិដែលត្រូវដកចេញពីការចុះបញ្ជីលក់មូលបត្រ (Delisting) ហើយត្រូវបានអនុញ្ញាតឱ្យជួញដូរក្នុងអំឡុងពេលមួយកំណត់ នៅមុនពេលដកចេញពីការចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើ បន្ទាប់ពីមានការឯកភាពពីអគ្គនាយកនៃ **គ.ម.ក.** **ផ.ម.ក.** អាចកំណត់យកដែនកំណត់ថ្លៃប្រចាំថ្ងៃផ្សេងពីនេះក្នុងករណីដូចខាងក្រោម÷

១- ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ។

២- ករណីមូលបត្រកម្មសិទ្ធិត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមជួញដូរឡើងវិញ បន្ទាប់ពីត្រូវបានព្យួរអស់មួយរយៈពេលវែង។

៣- ករណីផ្សេងទៀតមានការលំបាកខ្លាំងក្នុងការអនុវត្តដែនកំណត់ថ្លៃប្រចាំថ្ងៃ។

* * *

# ឧបសម្ព័ន្ធទី៤៖
# ប្រកាស ស្តីពីការដាក់ឱ្យអនុវត្តប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**

លេខ: ០២៥/១៧......គ.ម.ក./ប្រ.ក.

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុថ្ងៃះទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh Website : www.secc.gov.kh

- បានឃើញប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ
- យោងសំណើសុំវិសោធនកម្មប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

## សម្រេច

### ប្រការ ១.-

ដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ ២.-

ប្រកាសលេខ ០០៥/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ និងប្រការ ២ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

### ប្រការ ៣.-

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩ កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ ០១៤/១៣**
**ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៣**
**ស្ដីពី**
**វិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រ**
**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.-គោលបំណង

គោលបំណងនៃវិធានប្រតិបត្តិការផាត់ទាត់និងទូទាត់មូលបត្រនេះ គឺដើម្បីកំណត់នូវគោលការណ៍នានាដែលចាំបាច់សម្រាប់ការផាត់ទាត់និងទូទាត់មូលបត្រ នៅក្នុងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.-និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ច្បាប់ស្ដីពីមូលបត្ររដ្ឋ និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ បុគ្គលបោះផ្សាយលក់មូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

-**ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ** សំដៅដល់ធនាគារពាណិជ្ជដែលបានការទទួលស្គាល់ពី **គ.ម.ក.** ដូចមានចែងក្នុងប្រកាសស្ដីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ៣.-ប្រតិបត្តិការផាត់ទាត់និងទូទាត់**

ការជួញដូរមូលបត្រចុះបញ្ជី ត្រូវតែប្រតិបត្តិតាមការទូទាត់ធម្មតា។ ការទូទាត់ធម្មតា គឺជាការទូទាត់ដែលត្រូវធ្វើឡើងពីរថ្ងៃបន្ទាប់ពីថ្ងៃជួញដូរ (T+2)។

## ជំពូកទី២
## ការទូទាត់រវាងប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ និងសមាជិក ឬអ្នកចូលរួម

**ប្រការ ៤.-ភារកិច្ចទូទាត់របស់សមាជិក ឬអ្នកចូលរួម**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់លើប្រតិបត្តិការដែលបានជួញដូរឱ្យបាននៅកាលបរិច្ឆេទទូទាត់។

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** មិនអាចប្រគល់ភារកិច្ចទូទាត់ប្រតិបត្តិការរបស់ខ្លួនទៅឱ្យសមាជិក ឬអ្នកចូលរួមដទៃទៀតឡើយ។

**ប្រការ ៥.-កាលបរិច្ឆេទផាត់ទាត់និងទូទាត់រវាងសមាជិក ឬអ្នកចូលរួម**

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក.** ការទូទាត់ត្រូវធ្វើឡើងពីរថ្ងៃនៃថ្ងៃជួញដូរបន្ទាប់ពីថ្ងៃដែលមូលបត្រនោះត្រូវបានជួញដូរ (T+2)។ ថ្ងៃបិទទីផ្សារមិនត្រូវបានរាប់បញ្ចូលក្នុងចំនួនថ្ងៃអាជីវកម្មទេ។

**ប្រការ ៦.-ការជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវជ្រើសរើសភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** សម្រាប់បំពេញភារកិច្ចទូទាត់សាច់ប្រាក់។

**ប្រការ ៧.-ការបើកគណនីទូទាត់សម្រាប់ការទូទាត់សាច់ប្រាក់**

សមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីសាច់ប្រាក់ក្នុងនាមខ្លួនផ្ទាល់ នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចមានចែងក្នុងប្រការ ៦ នៃវិធាននេះ ដើម្បីបំពេញភារកិច្ចទូទាត់សាច់ប្រាក់។

បន្ទាប់ពីបានបើកគណនីសាច់ប្រាក់ ឬមានការផ្លាស់ប្តូរគណនីសាច់ប្រាក់ សមាជិក ឬអ្នកចូលរួមត្រូវរាយការណ៍អំពីឈ្មោះនៃភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្ររបស់ខ្លួន និងលេខគណនី ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** យ៉ាងហោចណាស់ ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមការជួញដូរ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់សាច់ប្រាក់នៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់សាច់ប្រាក់។

ការទូទាត់សាច់ប្រាក់ត្រូវបានធ្វើឡើង តាមរយៈការផ្ទេរសាច់ប្រាក់ពីគណនីសាច់ប្រាក់របស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់សាច់ប្រាក់របស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរសាច់ប្រាក់ដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួមដែលត្រូវទទួលបានការទូទាត់សាច់ប្រាក់។

## ប្រការ ៨.-ការបើកគណនីមូលបត្រសម្រាប់ការទូទាត់មូលបត្រ

សមាជិក ឬអ្នកចូលរួមត្រូវបើកគណនីមូលបត្រ ស្របតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រ នៃប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវបើកគណនីទូទាត់មូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីបំពេញកាតព្វកិច្ចទូទាត់មូលបត្រ។

ការទូទាត់មូលបត្រត្រូវធ្វើឡើង តាមរយៈការផ្ទេរក្នុងបញ្ជី (Book-EntryTransfer) ពីគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ទៅគណនីទូទាត់មូលបត្ររបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវផ្ទេរមូលបត្រដែលទទួលបាននេះ ទៅសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលបានការទូទាត់មូលបត្រ។

## ប្រការ ៩.-ការតម្កល់ធានាការជួញដូរ

មុនអនុវត្តបញ្ជាសម្រាប់គណនីអតិថិជន ឬសម្រាប់គណនីផ្ទាល់ខ្លួន សមាជិកត្រូវពិនិត្យការតម្កល់ធានាការជួញដូរមូលបត្រឱ្យបានត្រឹមត្រូវ ដូចតទៅ÷

១- សម្រាប់បញ្ជាទិញមូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាសាច់ប្រាក់។ ចំពោះបញ្ជាទិញមូលបត្រកម្មសិទ្ធិ សាច់ប្រាក់តម្កល់ធានាការជួញដូរនេះ អាចគិតបញ្ចូលផងដែរនូវសាច់ប្រាក់ត្រូវទទួលបានពីបញ្ជាលក់ដែលបានផ្គូផ្គងដោយជោគជ័យ។

២- សម្រាប់បញ្ជាលក់មូលបត្រ ត្រូវមានការតម្កល់ធានាការជួញដូរយ៉ាងតិច ១០០% (មួយរយភាគរយ) ជាមូលបត្រដែលត្រូវដាក់លក់នោះ។ ចំពោះបញ្ជាលក់មូលបត្រកម្មសិទ្ធិ មូលបត្រតម្កល់ធានាការជួញដូរអាចគិតបញ្ចូលផងដែរនូវមូលបត្រដូចគ្នាត្រូវទទួលបានពីបញ្ជាទិញដែលបានផ្គូផ្គងដោយជោគជ័យ។

សមាជិកត្រូវធានាឱ្យបានថា ការតម្កល់ធានាការជួញដូរត្រូវបានរក្សាទុក ឬបង្កកសម្រាប់ការទូទាត់ ឬរហូតដល់បញ្ជានោះអស់សុពលភាព។

## ប្រការ ១០.-នីតិវិធីនៃប្រតិបត្តិការផាត់ទាត់និងទូទាត់

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវគណនាចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ចុងក្រោយដោយសមាជិក ឬអ្នកចូលរួម ដោយធ្វើការបន្សុទ្ធ ឬកាត់កង (Netting) ចំនួនមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ក្នុងថ្ងៃដូចគ្នា របស់សមាជិក ឬអ្នកចូលរួម នីមួយៗ។

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវជូនដំណឹងអំពីព័ត៌មានដូចខាងក្រោមដល់សមាជិក ឬអ្នកចូលរួម នៅកាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់÷

១- កាលបរិច្ឆេទផាត់ទាត់ និងកាលបរិច្ឆេទទូទាត់។

២- បរិមាណនៃមូលបត្រនីមួយៗ ដែលត្រូវទូទាត់ដោយសមាជិកផ្ទាល់ ឬអ្នកចូលរួម ឬក្នុងនាមអតិថិជន។

៣- ទឹកប្រាក់ដែលត្រូវទូទាត់ដោយសមាជិក ឬអ្នកចូលរួមផ្ទាល់ ឬក្នុងនាមអតិថិជន។

បរិមាណមូលបត្រ និងចំនួនសាច់ប្រាក់ដែលនឹងត្រូវទូទាត់ ត្រូវគណនាស្របតាមវិធីសាស្ត្រនីមួយៗដូចខាងក្រោម÷

១- ចំពោះមូលបត្រ÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់បរិមាណលក់សរុប និងបរិមាណទិញសរុបនៃមូលបត្រនីមួយៗ សម្រាប់សមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធ។

២- ចំពោះសាច់ប្រាក់÷ ត្រូវបានគណនាដោយធ្វើការផាត់ទាត់តម្លៃទិញសរុប និងតម្លៃលក់សរុប សម្រាប់សមាជិក ឬអ្នកចូលរួម នីមួយៗដែលពាក់ព័ន្ធ។

សមាជិក ឬអ្នកចូលរួម ត្រូវផ្ទេរមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ ទៅគណនីរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. នៅមុនម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់ (Settlement Date) ហើយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវធ្វើការទូទាត់មូលបត្រនិងសាច់ប្រាក់បន្តទៅឱ្យសមាជិក ឬអ្នកចូលរួម ដែលត្រូវទទួលការទូទាត់ បន្ទាប់ពីម៉ោង ៨:៣០ ព្រឹក នៅថ្ងៃដដែលនៅកាលបរិច្ឆេទទូទាត់។

## ប្រការ ១១.-ការប្រគល់ឯកសារទូទាត់

ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ ផ.ម.ក. ត្រូវផ្តល់នូវឯកសារបង្គាប់ទូទាត់ ដែលរួមមានព័ត៌មានលម្អិតលើមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ជូនដល់សមាជិក ឬអ្នកចូលរួម ក្រោយការបិទទីផ្សារ តាមរយៈប្រព័ន្ធកុំព្យូទ័រ។

សមាជិក ឬអ្នកចូលរួម ត្រូវពិនិត្យអំពីមូលបត្រ និងសាច់ប្រាក់ដែលត្រូវទូទាត់ នៅលើឯកសារបង្គាប់ទូទាត់ និងត្រូវធ្វើការទូទាត់ទៅតាមពេលវេលាកំណត់។

សមាជិក ឬអ្នកចូលរួម ត្រូវប្រគល់ឯកសារទូទាត់ ដែលមានព័ត៌មានលម្អិត និងពេលវេលានៃការទូទាត់ជាដើម ជូនដល់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ក្រោយពីការទូទាត់។

**ប្រការ ១២.-វិធានការវិន័យចំពោះការបរាជ័យនៃការទូទាត់**

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមណាមួយគ្មានលទ្ធភាពធ្វើការទូទាត់ការជួញដូររបស់ខ្លួន ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** អាចលុបចោលនូវការជួញដូរដែលបានប្រតិបត្តិហើយទាំងស្រុង ឬមួយផ្នែកនៅក្នុងប្រតិបត្តិករទីផ្សារនៃ **ផ.ម.ក.** ឬ/និងព្យួរការជួញដូររបស់សមាជិក ឬអ្នកចូលរួមនោះក្នុងរយៈពេលកំណត់មួយ។

ក្នុងករណីដែលមានកង្វះខាតសាច់ប្រាក់ក្នុងការទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** អាចប្រើប្រាស់មធ្យោបាយផ្សេងៗ ដើម្បីធានាការទូទាត់ លើកលែងតែមានការកំណត់ផ្សេងទៀត។

ក្នុងករណីដែលមានកង្វះខាតមូលបត្រសម្រាប់ទូទាត់ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** ត្រូវធ្វើការទូទាត់ ដោយសុំខ្ចីនូវមូលបត្រប្រភេទដូចគ្នាពីសមាជិក ឬអ្នកចូលរួមផ្សេងទៀត។ ប្រសិនបើការសុំខ្ចី និងការឱ្យខ្ចីមិនអាចធ្វើទៅបាន ការទូទាត់នឹងត្រូវលុបចោល។

ប្រសិនបើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** មិនអាចរកមធ្យោបាយដើម្បីធ្វើការទូទាត់ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងទី ៣ ខាងលើ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** អាចចាត់វិធានការ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ១៣.- អ្នកតំណាងទូទាត់**

សមាជិក ឬអ្នកចូលរួមនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងទូទាត់យ៉ាងហោចណាស់ ១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពីប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** និងដែលមានសិទ្ធិធ្វើប្រតិបត្តិការទូទាត់ឱ្យសមាជិក ឬអ្នកចូលរួមនោះ ជាមួយប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

អ្នកតំណាងទូទាត់របស់សមាជិកនោះ អាចជាអ្នកតំណាងទីផ្សារដែលត្រូវបានតែងតាំងដោយសមាជិកស្របតាមវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ **ផ.ម.ក.**។

## ជំពូកទី ៣
## ថ្លៃសេវាផាត់ទាត់និងទូទាត់

**ប្រការ ១៤.-ថ្លៃសេវាផាត់ទាត់និងទូទាត់មូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ថ្លៃសេវាផាត់ទាត់និងទូទាត់ ជូនប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.** តាមអត្រា និងពេលវេលាដូចខាងក្រោម÷

១-ថ្លៃសេវាសម្រាប់សេវាផាត់ទាត់និងទូទាត់មូលបត្រ ត្រូវយកលើតម្លៃជួញដូរដែលត្រូវបានទូទាត់ (ប្រាក់សេវាត្រូវកាត់កៀសមកត្រឹមមួយខ្ទង់) តាមអត្រា ២,៥/១០.០០០ (ពីរក្បៀសប្រាំភាគមួយម៉ឺន) ឬ០,០២៥% (សូន្យក្បៀសសូន្យម្ភៃប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង ១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ ០,០១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល។

២-អ្នកបង់ថ្លៃសេវា គឺសមាជិក ឬអ្នកចូលរួមនៃប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

៣-ពេលវេលានៃការបង់ថ្លៃសេវា គឺនៅម៉ោង ៨:៣០ ព្រឹក នៃកាលបរិច្ឆេទទូទាត់។

* * *

# ឧបសម្ព័ន្ធទី៥៖

# ប្រកាស ស្តីពីការអនុវត្តវិធានការ

# ប្រតិបត្តិការរក្សាទុកមូលបត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០១៩/១៧ គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ

* * * * *

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹតលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការផ្ដល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្ដីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០២/១១ គ.ម.ក.ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- យោងតាមសំណើសុំវិសោធនកម្មប្រកាសលេខ ០០២/១១ គ.ម.ក. ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៧
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសលេខ ០០២/១១ គ.ម.ក./ប្រក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ និងប្រការ៣ នៃប្រកាសលេខ ០០៣/១៧ គ.ម.ក. ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ ស្ដីពីការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារ

មូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ...........ខែ........ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦... ខែ........ ឆ្នាំ២០១៧..

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣

"ដើម្បីអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធប្រកាសលេខ...០១៩/១៧...........**
**ចុះថ្ងៃទី ...២៦........ខែ.....ធ្នូ.......ឆ្នាំ២០១៧...**

# ស្ដីពី
# វិធានប្រតិបត្តិការរក្សាទុកមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីលក្ខខណ្ឌចាំបាច់នានា សម្រាប់ការរក្សាទុក និងការផ្ទេរមូលបត្រ នៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) ស្របតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងវិធាននេះ ត្រូវបានកំណត់នៅក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ច្បាប់ស្ដីពីមូលបត្ររដ្ឋ អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

-**សមាជិក** សំដៅដល់ក្រុមហ៊ុនមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (សរសេរកាត់ថា **គ.ម.ក.**) ដោយមានសិទ្ធិប្រើប្រាស់ទាំងស្រុងនូវប្រព័ន្ធរបស់ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.**។

-**អ្នកចូលរួម** សំដៅដល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ បុគ្គលបោះផ្សាយលក់មូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រជាដើម ដែលមានសិទ្ធិប្រើប្រាស់តែមួយផ្នែកនូវប្រព័ន្ធរបស់ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.**។

**ប្រការ ៣.- ម៉ោងអាជីវកម្ម**

អាជីវកម្មស្របតាមវិធាននេះ គឺចាប់ផ្ដើមពីម៉ោង ៨:០០ ព្រឹក ដល់ម៉ោង ៥:០០ ល្ងាច រៀងរាល់ថ្ងៃធ្វើការ។

**ប្រការ ៤.- ការដាក់ផ្ញើ ឬការដកចេញពីការដាក់ផ្ញើមូលបត្រ**

មូលបត្រដែលអាចដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** មានដូចខាងក្រោម លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយ អគ្គនាយកនៃ **គ.ម.ក.**÷

១-មូលបត្រដែលចុះបញ្ជីលក់នៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.**។

២-មូលបត្រដែលបោះផ្សាយបន្ថែមដោយបុគ្គលចុះបញ្ជីលក់មូលបត្រ។

៣-មូលបត្រដែលកំពុងស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ។

៤-មូលបត្រដែលមានស្រាប់របស់បុគ្គល ដែលកំពុងស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៥- មូលបត្ររដ្ឋ។

៦-មូលបត្រដែលជាកម្មវត្ថុនៃសំណើលក់ជាឯកជន។

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.**អាចដកមូលបត្រចេញពីការដាក់ផ្ញើ ករណីដែលមូលបត្រនោះត្រូវបានដកចេញពីបញ្ជីលក់មូលបត្រនៅប្រតិបត្តិករទីផ្សារមូលបត្រនៃ **ផ.ម.ក.** និងត្រូវដកមូលបត្រចេញពីការដាក់ផ្ញើ ចំពោះមូលបត្របំណុលដែលប្រាក់ដើមត្រូវបានទូទាត់រួចរាល់។

ក្នុងករណីមានការដកចេញពីការដាក់ផ្ញើមូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** ត្រូវជូនដំណឹងជាមុនដល់សមាជិក និងអ្នកចូលរួមដែលដាក់ផ្ញើមូលបត្រអំពីការដកចេញនេះ។

**ប្រការ ៥.- ព័ត៌មានពាក់ព័ន្ធនឹងមូលបត្រដែលដាក់ផ្ញើ**

ដើម្បីដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** សមាជិក និងអ្នកចូលរួម ដែលដាក់ផ្ញើត្រូវផ្ដល់ព័ត៌មានដោយផ្ទាល់ ឬតាមរយៈភ្នាក់ងារបញ្ជិកាមូលបត្រដូចខាងក្រោម÷

១-ឈ្មោះមូលបត្រដែលដាក់ផ្ញើ។

២-ប្រភេទមូលបត្រដែលដាក់ផ្ញើ។

៣-ថ្លៃមូលបត្រដែលដាក់ផ្ញើ។

៤-ចំនួនមូលបត្រដែលដាក់ផ្ញើ។

៥-ចំនួនមូលបត្រដែលបានបោះផ្សាយ។



41

៦-អក្សរកូដមូលបត្រដែលដាក់ផ្ញើ។

៧-លេខកូដមូលបត្រដែលដាក់ផ្ញើ។

៨-កាលបរិច្ឆេទបោះផ្សាយមូលបត្រដែលដាក់ផ្ញើ។

៩-កាលបរិច្ឆេទចុះបញ្ជីមូលបត្រដែលដាក់ផ្ញើ។

១០-ចំពោះមូលបត្របំណុលត្រូវមានកាលបរិច្ឆេទឥណប្រតិទាន (Maturity Date) អត្រាគូប៉ុង (Coupon Rate) កាលបរិច្ឆេទត្រូវបង់ការប្រាក់ និងលក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀត។

១១-ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងកម្មសិទ្ធិភាពលើមូលបត្រដែលបានដាក់ផ្ញើ។

## ជំពូកទី ២
## គណនីមូលបត្រ

### ប្រការ ៦.- ការបើកគណនីមូលបត្រ

បុគ្គលដែលអាចបើកគណនីមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** រួមមានដូចខាងក្រោម÷

១-ក្រុមហ៊ុនមូលបត្រ។

២-បុគ្គលបោះផ្សាយលក់មូលបត្រ។

៣-បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ប្រតិបត្តិកររក្សាទុកមូលបត្របរទេស។

៥-ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ។

៦-វិនិយោគិនស្ថាប័ន។

បុគ្គលដែលមានបំណងបើកគណនីមូលបត្រ ត្រូវបំពេញបែបបទនៅ **ផ.ម.ក.**។

### ប្រការ ៧.- សៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម

ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** ត្រូវរក្សាសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួមនីមួយៗ ដែលត្រូវមានព័ត៌មាន ព្រមទាំងសេចក្ដីលម្អិតនៃប្រតិបត្តិការលើមូលបត្រ ដែលធ្វើដោយសមាជិក និងអ្នកចូលរួម។ លើកលែងតែមានការកំណត់បន្ថែមផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** ព័ត៌មានលម្អិតរួមមាន÷

១-ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលស្នើបើកគណនីមូលបត្រ។

២-ឈ្មោះ ប្រភេទ បរិមាណ អក្សរកូដ និងលេខកូដនៃមូលបត្រដែលដាក់ផ្ញើ។

៣-ហេតុផលនៃឥណទាន ឬឥណពន្ធនៃមូលបត្រដែលដាក់ផ្ញើ។

៤-ករណីដែលមូលបត្រដាក់ផ្ញើជាកម្មវត្ថុនៃការបញ្ចាំ ត្រូវបញ្ជាក់ឈ្មោះ និងអាសយដ្ឋាននៃភ្នាក់ងារទទួលបញ្ចាំមូលបត្រ។

៥-ក្នុងករណីមូលបត្រដែលបានដាក់ផ្ញើ ជាកម្មវត្ថុនៃការដាក់កំហិតលក់ត្រូវមានព័ត៌មានអំពីការដាក់កំហិតនោះ។

ការដាក់ផ្ញើមូលបត្រដែលជាកម្មសិទ្ធិរបស់សមាជិក ត្រូវកត់ត្រាដាច់ដោយឡែកពីការដាក់ផ្ញើមូលបត្រដែលជាកម្មសិទ្ធិរបស់អតិថិជន។

សៀវភៅគណនីមូលបត្ររបស់សមាជិកនិងអ្នកចូលរួមត្រូវរក្សាទុកសម្រាប់រយៈពេល១០(ដប់)ឆ្នាំ។

ក្នុងករណីដែលសមាជិក ឬអ្នកចូលរួមមានបំណងកែប្រែឈ្មោះ អាសយដ្ឋាន លេខចុះបញ្ជីពាណិជ្ជកម្ម ឬការបោះពុម្ពត្រាសម្គាល់ សមាជិក ឬអ្នកចូលរួម ត្រូវជូនដំណឹងដល់ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក** នូវការកែប្រែទាំងនោះ ដោយបំពេញបែបបទស្នើសុំឱ្យបានត្រឹមត្រូវ។

## ប្រការ ៨.- សៀវភៅគណនីមូលបត្ររបស់អតិថិជន

សៀវភៅគណនីមូលបត្ររបស់អតិថិជនត្រូវមានព័ត៌មានលម្អិតដូចខាងក្រោម÷

១-ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជន។

២-ឈ្មោះ ប្រភេទ បរិមាណ អក្សរកូដ និងលេខកូដនៃមូលបត្រដែលដាក់ផ្ញើ។

៣-ព័ត៌មាននៃប្រតិបត្តិការលើមូលបត្រដាក់ផ្ញើ។

៤-ព័ត៌មានអំពីអតិថិជននីមួយៗ ។

សៀវភៅគណនីមូលបត្ររបស់អតិថិជនត្រូវរក្សាទុកសម្រាប់រយៈពេល ១០(ដប់) ឆ្នាំ។

## ប្រការ ៩.- កាលបរិច្ឆេទសុពលភាពនៃការដាក់ផ្ញើ

ការដាក់ផ្ញើ ការដក ឬការបង្វិលទៅវិញ និងការផ្ទេរមូលបត្ររវាងគណនី ដែលធ្វើឡើងស្របតាមវិធាននេះ ត្រូវមានសុពលភាពចាប់ពីពេលដែលព័ត៌មានពាក់ព័ន្ធ ត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅគណនីមូលបត្ររបស់សមាជិក និងអ្នកចូលរួម។

## ប្រការ ១០.- ការបិទគណនីមូលបត្រ

លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.ម.ក** ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** អាចបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួមក្នុងករណីណាមួយដូចខាងក្រោម÷

១-សមាជិក ឬអ្នកចូលរួមស្នើសុំបិទគណនីមូលបត្រ។

២-សមាជិក ឬអ្នកចូលរួមមិនបានប្រើប្រាស់គណនីរបស់ខ្លួនក្នុងរយៈពេល ២ (ពីរ) ឆ្នាំ។

មុននឹងបិទគណនីមូលបត្ររបស់សមាជិក ឬអ្នកចូលរួម ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** ត្រូវផ្តល់ជូននូវសមតុល្យនៃការដាក់ផ្ញើនៅក្នុងគណនីមូលបត្រដែលត្រូវបិទទៅសមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធ។

## ជំពូកទី ៣

## បទប្បញ្ញត្តិបន្ថែម

### ប្រការ ១១.- អ្នកតំណាងរក្សាទុកមូលបត្រ

សមាជិក និងអ្នកចូលរួមនីមួយៗ ត្រូវតែងតាំង និងចុះឈ្មោះអ្នកតំណាងរក្សាទុកមូលបត្ររបស់ខ្លួនយ៉ាងហោចណាស់ចំនួន ១ (មួយ) រូប ដែលត្រូវទទួលការបណ្តុះបណ្តាលពី **ផ.ម.ក.** និងដែលត្រូវមានសិទ្ធិធ្វើប្រតិបត្តិការរក្សាទុកមូលបត្រឱ្យសមាជិក និងអ្នកចូលរួមនោះ។

អ្នកតំណាងរក្សាទុកមូលបត្ររបស់សមាជិក និងអ្នកចូលរួមនេះ អាចជាអ្នកតំណាងទូទាត់ដែលត្រូវបានតែងតាំងដោយសមាជិក និងអ្នកចូលរួម ស្របតាមវិធានប្រតិបត្តិការជាត់ទាត់ និងទូទាត់មូលបត្រនៃ **ផ.ម.ក.**។

### ប្រការ ១២.- ការជូនដំណឹងអំពីសមតុល្យ

ប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** ត្រូវជូនដំណឹងដល់សមាជិក និងអ្នកចូលរួម អំពីសមតុល្យនៃគណនីមូលបត្រ ដែលបានដាក់ផ្ញើនៅរៀងរាល់ចុងខែនីមួយៗ។ ការជូនដំណឹងអំពីសមតុល្យគណនីនេះ អាចត្រូវបានជំនួស ដោយការដាក់ជូននូវសេចក្តីចម្លងនៃសៀវភៅគណនីមូលបត្ររបស់សមាជិក ឬរបស់អ្នកចូលរួម។

### ប្រការ ១៣.- ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ

សមាជិក ឬអ្នកចូលរួមត្រូវបង់ប្រាក់ថ្លៃសេវាជូន **ផ.ម.ក.** ដូចខាងក្រោម ÷

១-ថ្លៃសេវារក្សាទុកមូលបត្រ÷ ជាថ្លៃសម្រាប់ការដាក់ផ្ញើមូលបត្រ ដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈនិងមូលបត្រដែលជាកម្មវត្ថុនៃសំណើលក់ជាឯកជន។ ថ្លៃសេវារក្សាទុកមូលបត្រប្រចាំខែត្រូវបង់នៅថ្ងៃទី ១០ នៃខែបន្ទាប់ពីខែដែលថ្លៃសេវានោះបានកើតឡើងតាមលក្ខខណ្ឌដូចខាងក្រោម ÷

ក-អត្រា២០ (ម្ភៃ) រៀល លើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះថ្លៃសេវាត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ ថ្លៃនេះមិនត្រូវលើសពី ១២០.០០០ (មួយរយម្ភៃពាន់) រៀល ក្នុងមួយថ្ងៃឡើយ។

ខ-អ្នកត្រូវបង់ប្រាក់ជាសមាជិក ឬអ្នកចូលរួមដែលស្នើសុំដាក់ផ្ញើ។

២-ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee)÷

ក-ថ្លៃសេវាការផ្ទេរមូលបត្ររវាងគណនី÷ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរដែលបានទូទាត់តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង ១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ០,០១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល ហើយទឹកប្រាក់ថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ-អ្នកត្រូវបង់ថ្លៃសេវាជាសមាជិក ឬអ្នកចូលរួម ដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរមូលបត្រដែលដាក់ផ្ញើ។

គ-ពេលវេលាបង់ថ្លៃសេវានៅម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣-ថ្លៃសេវាផ្សេងៗ÷

ក-ថ្លៃសេវានៃការផ្ទេរមូលបត្រដែលដាក់ផ្ញើ តែមិនត្រូវបានជួញដូរគឺ ១០០.០០០ (មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ។ សមាជិក ឬអ្នកចូលរួមដែលដាក់ផ្ញើមូលបត្រត្រូវបង់ថ្លៃសេវានេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** នៅពេលស្នើសុំផ្ទេរមូលបត្រ ។

ខ-ថ្លៃសេវានៃការដកមូលបត្រដែលដាក់ផ្ញើគឺ ២០០.០០០ (ពីររយពាន់) រៀលក្នុងមួយប្រតិបត្តិការ។ សមាជិក ឬអ្នកចូលរួមដែលដាក់ផ្ញើមូលបត្រត្រូវបង់សេវាថ្លៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ **ផ.ម.ក.** នៅពេលស្នើសុំដកមូលបត្រ ។

* * * * *

# ឧបសម្ព័ន្ធទី៦៖

# ប្រកាស ស្ដីពីការដាក់ឱ្យអនុវត្តការកែប្រែ

# វិធានប្រតិបត្តិការរក្សាទុកមូលបត្រ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខ:.....006/20.....គ.ម.ក. /ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តនូវការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

- បានឃើញប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ
- យោងតាមសំណើសុំអនុម័តលើការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩

## សម្រេច

**ប្រការ១.-**

ដាក់ឱ្យអនុវត្តនូវប្រការ១៣ ថ្មី នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ជំនួសប្រការ១៣ នៃវិធានប្រតិបត្តិការរក្សាទុកមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០១៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តវិធានប្រតិបត្តិការរក្សាទុកមូលបត្រ។

**ប្រការ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត ប្រធាននាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១ រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យសម្តេច លោកជំទាវ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"
- ដូចប្រការ ២

"ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ០០៤/២០/ គ.ម.ក.
ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២០
**ការកែប្រែវិធានប្រតិបត្តិការរក្សាទុកមូលបត្រ**
**របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

**ប្រការ១៣.ថ្មី.- ថ្លៃសេវាប្រតិបត្តិការរក្សាទុកមូលបត្រ**

សមាជិក ឬអ្នកចូលរួមត្រូវបង់ប្រាក់ថ្លៃសេវាជូន ផ.ម.ក. ដូចខាងក្រោម ÷

១-ថ្លៃសេវារក្សាទុកមូលបត្រ÷ ជាថ្លៃសម្រាប់ការដាក់ផ្ញើមូលបត្រដែលស្ថិតក្នុងនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមូលបត្រដែលជាកម្មវត្ថុនៃសំណើលក់ជាឯកជន។ ថ្លៃសេវារក្សាទុកមូលបត្រប្រចាំខែ ត្រូវបង់នៅថ្ងៃទី១០ នៃខែបន្ទាប់ពីខែដែលថ្លៃសេវានោះបានកើតឡើងតាមលក្ខខណ្ឌដូចខាងក្រោម ÷

ក-អត្រា២០ (ម្ភៃ) រៀលលើមូលដ្ឋាននៃទឹកប្រាក់ ១០.០០០.០០០ (ដប់លាន) រៀល។ ក្នុងករណីនេះ ថ្លៃសេវាត្រូវកំណត់យកលើមូលដ្ឋានសមតុល្យប្រចាំថ្ងៃ ដែលបង្ហាញជូននៅក្នុងសៀវភៅគណនីមូលបត្រ។ ថ្លៃនេះមិនត្រូវលើសពី ១២០.០០០ (មួយរយម្ភៃពាន់) រៀលក្នុងមួយថ្ងៃឡើយ។

ខ-អ្នកត្រូវបង់ប្រាក់ជាសមាជិក ឬអ្នកចូលរួមដែលស្នើសុំដាក់ផ្ញើ។

២-ថ្លៃសេវាផ្ទេរមូលបត្ររវាងគណនី (Book Entry Fee) :

ក-ថ្លៃសេវាការផ្ទេរមូលបត្ររវាងគណនី ត្រូវគណនាលើមូលដ្ឋានទឹកប្រាក់នៃការជួញដូរដែលបានទូទាត់ តាមអត្រា ៥/១០.០០០ (ប្រាំភាគមួយម៉ឺន) ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ចំពោះមូលបត្រកម្មសិទ្ធិ និង១,២៥/១០.០០០ (មួយក្បៀសម្ភៃប្រាំភាគមួយម៉ឺន) ឬ០,០១២៥% (សូន្យក្បៀសសូន្យមួយរយម្ភៃប្រាំភាគរយ) ចំពោះមូលបត្របំណុល ហើយទឹកប្រាក់ថ្លៃសេវាត្រូវកាត់យកមួយខ្ទង់ក្រោយក្បៀស។

ខ-អ្នកត្រូវបង់ថ្លៃសេវាជាសមាជិក ឬអ្នកចូលរួមដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរមូលបត្រដែលដាក់ផ្ញើ។

គ-ពេលវេលាបង់ថ្លៃសេវានៅម៉ោង ៨:៣០ ព្រឹក នៅកាលបរិច្ឆេទទូទាត់។

៣-ថ្លៃសេវាផ្សេងៗ :

ក-ថ្លៃសេវានៃការផ្ទេរមូលបត្រដែលដាក់ផ្ញើ មិនកើតចេញពីការជួញដូររួមមាន÷

- ការផ្ទេរមូលបត្រពីគណនីមួយទៅគណនីមួយទៀតរបស់បុគ្គលតែម្នាក់÷ថ្លៃសេវានៃការផ្ទេរគឺស្មើនឹង ១០០.០០០(មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ ។
- ការផ្ទេរមូលបត្រដោយមូលហេតុសន្តតិកម្ម ប្រទានកម្មរវាងឪពុកម្តាយ ប្តីប្រពន្ធ កូន និងចៅដោយមានមូលហេតុត្រឹមត្រូវ ឬសេចក្តីសម្រេចរបស់តុលាការ÷ ថ្លៃសេវាត្រូវគណនាលើមូលដ្ឋានថ្លៃទីផ្សារនៃមូលបត្រ សរុបក្នុងថ្ងៃប្រតិបត្តិការផ្ទេរតាមអត្រា ៥/១០.០០០(ប្រាំភាគមួយម៉ឺន)ឬ០,០៥% (សូន្យក្បៀសសូន្យប្រាំភាគរយ) ក្នុងមួយប្រតិបត្តិការដែលថ្លៃសេវានេះមិនត្រូវលើសពី ២០.០០០.០០០(ម្ភៃលាន) រៀល និងទាបបំផុតត្រឹម ១០០.០០០(មួយរយពាន់) រៀលក្នុងមួយប្រតិបត្តិការ។
- សមាជិក ឬអ្នកចូលរួម ដែលដាក់ផ្ញើមូលបត្រត្រូវបង់ថ្លៃសេវានេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក នៅពេលស្នើសុំផ្ទេរមូលបត្រ ។

ខ-ថ្លៃសេវានៃការដកមូលបត្រដែលដាក់ផ្ញើគឺ ២០០.០០០(ពីររយពាន់) រៀលក្នុងមួយប្រតិបត្តិការ។ សមាជិកឬអ្នកចូលរួមដែលដាក់ផ្ញើមូលបត្រ ត្រូវបង់សេវាថ្លៃនេះជូនប្រតិបត្តិកររក្សាទុកមូលបត្រនៃ ផ.ម.ក. នៅពេលស្នើសុំដកមូលបត្រ ។

* * * * *

# ឧបសម្ព័ន្ធទី៧៖

# ប្រកាស ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ: ០០៥/១៥ គ.ម.ក/ប្រ.ក

# ប្រកាស
# ស្តីពី
# ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ច្បាប់ សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ក្រុមហ៊ុនសក្តានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥-ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦-ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០-ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូល-បត្រកម្មសិទ្ធិជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវវាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១-ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២-ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣-ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុត្រីមាស។

៤-ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥-ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១(មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្តើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០(ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០(ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០(ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១-ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២-ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣-សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤-ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១-លទ្ធផលប្រតិបត្តិការ។

២-សន្ទនីយភាព និងប្រភពទុន។

៣-ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤-ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មប្រើរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១-ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មប្រើរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មប្រើទាំងនោះ។

២-សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មប្រើរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មប្រើទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មប្រើ។

៣-ការវាយតម្លៃលើអចលកម្មប្រើរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្តីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញ រួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦-សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុន ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្តល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម÷

១-ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២-របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម÷

១-បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២-ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣-ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤-ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់-ព័ន្ធ ដូចខាងក្រោម÷

១-អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះ-ផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២-បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣- សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤- បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥- បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥- ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១- កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២- ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣- ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤- ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជិរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧-ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្ដីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្ដល់ឯកសារផ្ដល់ព័ត៌មានបន្ថែម ឬឯកសារផ្ដល់ព័ត៌មានជំនួស ឬសេចក្ដីបញ្ជាក់ ឬសេចក្ដីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨-នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ-មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១-បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២-បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣-បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤ "ខ" នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

## ប្រការ ៣៥.-

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

## ប្រការ ៣៦.-

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១- ២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២- ៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

## ប្រការ ៣៧.-

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្លៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខស៊េរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្វូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១- ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២- ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣- ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤- កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥- សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦- សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧- កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្តើម។

៨- សេចក្តីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯក-សារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១- ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨**.-

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាស នេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៨៖
# ព្រឹត្តិបត្រវិនិយោគិន និងការវិនិយោគ
# ប្រចាំត្រីមាស ឆ្នាំ២០២១

# ផ្នែកទី២. ទិន្នន័យទីផ្សារមូលបត្រ

## ២.១. និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ

| និន្នាការទូទៅនៃទីផ្សារ | ត្រីមាសទី១ ២០២១ | ត្រីមាសទី២ ២០២១ | បម្រែបម្រួលត្រី.២ ២០២១ ធៀបនឹង | |
|---|---|---|---|---|
| | | | ត្រី.១ ២០២១ | ត្រី.២ ២០២០ |
| ថ្ងៃជួញដូរ | 61 | 58 | -5% | -3% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 813.41 | 813.41 | 0% | 10% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 9,697,096 | 8,405,558 | -13% | -18% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 2,397.30 | 2,062.71 | | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 20.55 | 18.01 | -12% | 96% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 18.08 | 19.73 | 9% | 93% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 5.53 | 7.69 | 39% | 107% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 90,724 | 132,585 | 46% | 115% |
| តម្លៃជួញដូរ (លានរៀល) | 34,835.91 | 60,908.11 | 75% | -8% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 8.61 | 14.95 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 571.08 | 1,050.14 | 84% | -5% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 141,182 | 257,703 | | |
| សន្ទស្សន៍ ផ.ម.ក. (សន្ទស្សន៍បិទ) | 639.36 | 554.21 | -13% | -20% |
| ចំនួនវិនិយោគិន (នាក់) | 1,960 | 5,119 | 161% | 80% |

*តារាង ១ និន្នាការទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី២ ឆ្នាំ២០២១*

ទំហំមូលធនូបនីយកម្មទីផ្សារសរុបនៃទីផ្សារមូលបត្រកម្មសិទ្ធិ នៅចុងត្រីមាសទី២ ឆ្នាំ២០២១ មានតម្លៃប្រហែល ៨,៤១ ទ្រីលានរៀល (ប្រហែល២,០៦ ប៊ីលានដុល្លារអាមេរិក) និងសន្ទស្សន៍ ផ.ម.ក. មានចំនួន ៥៥៤,២១ ពិន្ទុ។ ក្នុងត្រីមាសទី២ ឆ្នាំ២០២១ នេះ ទំហំជួញដូរភាគហ៊ុនសរុបមានចំនួន ៧.៦៨៩.៩០៣ ភាគហ៊ុន បានកើនឡើងប្រហែល ៣៩% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ និងកើនឡើង ១០៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ចំណែកឯតម្លៃជួញដូរមូលបត្រសរុបមានតម្លៃប្រហែល ៦០,៩១ ប៊ីលានរៀល (ប្រហែល ១៤,៩៥ លានដុល្លារអាមេរិក) បានកើនឡើងប្រហែល ៧៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ ប៉ុន្តែបានថយចុះប្រមាណ ៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ចំពោះ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួនប្រហែល ១៣២.៥៨៥ ភាគហ៊ុន ខណៈដែលមានតម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃមានតម្លៃប្រហែល ១,០៥០.១៤ លានរៀល (ប្រហែល ២៥៧,៧០ ពាន់ដុល្លារអាមេរិក)។ ចំណែកឯបញ្ជាទិញសរុបមានចំនួនប្រហែល ១៨,០១ លានភាគហ៊ុន ខណៈដែលបញ្ជាលក់សរុបមានចំនួនប្រហែល ១៩,៧៣ លានភាគហ៊ុន។

# ផ្នែកទី២. ទិន្នន័យទីផ្សារមូលបត្រ

## ២.១. ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិ

| ទិដ្ឋភាពទូទៅនៃទីផ្សារ | ត្រីមាសទី៣ ២០២១ | ត្រីមាសទី៤ ២០២១ | បម្រែបម្រួលត្រី.៤ ២០២១ ធៀបនឹង | |
|---|---|---|---|---|
| | | | ត្រី.៣ ២០២១ | ត្រី.៤ ២០២០ |
| ថ្ងៃជួញដូរ | 65 | 58 | -11% | -5% |
| ចំនួនភាគហ៊ុនចុះបញ្ជីសរុប (លានភាគហ៊ុន) | 819.87 | 819.87 | 0% | 1% |
| មូលធនូបនីយកម្មទីផ្សារ (លានរៀល) | 7,448,012 | 7,194,730 | -3% | -27% |
| មូលធនូបនីយកម្មទីផ្សារ (លានដុល្លារអាមេរិក) | 1,825.94 | 1,766.01 | | |
| បរិមាណបញ្ជាទិញ (លានភាគហ៊ុន) | 17.93 | 42.08 | 135% | 299% |
| បរិមាណបញ្ជាលក់ (លានភាគហ៊ុន) | 23.92 | 48.13 | 101% | 258% |
| ទំហំជួញដូរ (លានភាគហ៊ុន) | 7.34 | 36.22 | 393% | 891% |
| ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃ (ភាគហ៊ុន) | 112,911 | 624,424 | 453% | 942% |
| តម្លៃជួញដូរ (លានរៀល) | 66,875.13 | 97,936.73 | 46% | 609% |
| តម្លៃជួញដូរ (លានដុល្លារអាមេរិក) | 16.39 | 24.04 | | |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (លានរៀល) | 1028.85 | 1688.56 | 64% | 646% |
| តម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 252,230 | 414,473 | | |
| សន្ទស្សន៍ ផមក (សន្ទស្សន៍បិទ) | 490.11 | 473.39 | -3% | -27% |
| ចំនួនវិនិយោគិន (នាក់) | 6,146 | 4,538 | -26% | 141% |

*តារាង 1 ទិដ្ឋភាពទូទៅនៃការជួញដូរមូលបត្រកម្មសិទ្ធិក្នុងត្រីមាសទី៤ ឆ្នាំ២០២១*

ទំហំមូលធនូបនីយកម្មទីផ្សារសរុបនៃទីផ្សារមូលបត្រកម្មសិទ្ធិ នៅចុងត្រីមាសទី៤ ឆ្នាំ២០២១ មានតម្លៃប្រហែល ៧,១៩ ទ្រីលានរៀល (ប្រហែល ១,៧៧ ប៊ីលានដុល្លារអាមេរិក) និងសន្ទស្សន៍ ផមក មានចំនួន ៤៧៣,៣៩ ពិន្ទុ។ ក្នុងត្រីមាសទី៤ ឆ្នាំ២០២១ នេះ ទំហំជួញដូរភាគហ៊ុនសរុបមានចំនួន៣៦.២១៦.៦២០ ភាគហ៊ុន បានកើនឡើងប្រហែល ៣៩៣% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២១ និងបានកើនឡើង ៨៩១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ចំណែកឯ តម្លៃជួញដូរមូលបត្រសរុបមានតម្លៃប្រហែល ៩៧,៩៤ ប៊ីលានរៀល (ប្រហែល ២៤,០៤ លានដុល្លារអាមេរិក) បានកើនឡើងប្រហែល ៤៦% ធៀបនឹងត្រីមាសទី៣ ឆ្នាំ២០២១ និងបានកើនឡើងប្រមាណ ៦០៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ ចំពោះ ទំហំជួញដូរជាមធ្យមប្រចាំថ្ងៃមានចំនួនប្រហែល ៦២៤.៤២៤ ភាគហ៊ុន ខណៈដែលមានតម្លៃជួញដូរជាមធ្យមប្រចាំថ្ងៃ មាន